ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

# គោលការណ៍ណែនាំស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

អង្គការពលកម្មអន្តរជាតិ

សំណៅទី ១ ខែ មិថុនា ឆ្នាំ ២០១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

# គោលការណ៍ណែនាំស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

**អង្គការពលកម្មអន្តរជាតិ (ILO)**

**ការិយាល័យប្រចាំអនុតំបន់ និងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO/SRO/BFC)**

ជូន បូរ៉ា ទីប្រឹក្សា

រីឆាដ ហូវើដ (Richard Howard) ជំនាញការជាន់ខ្ពស់ផ្នែកមេរោគអេដស៍ និងជម្ងឺអេដស៍
នៃការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំអនុតំបន់អាស៊ីខាងកើត

អេរិក ស្តិននើ ខាលសុន (Eric Stener Carlson) អតីតជំនាញការបច្ចេកទេសរបស់អង្គការពលកម្មអន្តរជាតិ
ផ្នែកមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារសម្រាប់អាស៊ីខាងកើត អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក

សំណៅទី ១ ខែ មិថុនា ឆ្នាំ ២០១០

# អារម្ភកថា

មេរោគអេដស៍ និងជម្ងឺអេដស៍ គឺជាបញ្ហាមួយនៅកន្លែងធ្វើការដែលយើងទាំងអស់គ្នាត្រូវផ្តោតការយកចិត្តទុកដាក់ ដោយសារតែវាមានសក្តានុពលធ្វើឱ្យផលិតភាព និងកំណើនសេដ្ឋកិច្ចថយចុះ។ វីរុសនេះអាចដាក់បន្ទុកផ្នែកហិរញ្ញវត្ថុ និងសង្គមកិច្ចយ៉ាងធ្ងន់ធ្ងរទៅលើក្រុមគ្រួសារដោយសារតែចំណូលរបស់ពួកគេមានការថយចុះ ហើយជារឿយៗចាំបាច់ត្រូវរ៉ាប់រងចំណាយលើការព្យាបាលជាច្រើន។ កម្មករនិយោជិត និងគ្រួសាររបស់ពួកគេក៏ត្រូវប្រឈមនឹងការមាក់ងាយ និងការរើសអើងជាច្រើនផងដែរ ដោយសារតែវីរុសនេះអាចធ្វើឱ្យពួកគេបាត់បង់ការងារ និងប្រឈមនឹងការរើសអើងដទៃទៀតនៅក្នុងសហគមន៍ ។

បើទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ កន្លែងធ្វើការគឺជាកន្លែងដែលមានប្រសិទ្ធភាពខ្ពស់មួយ ដើម្បីបង្កើតគោលនយោបាយ និងកម្មវិធី សំដៅកាត់បន្ថយការរើសអើង ពង្រីកការបង្ការដល់ក្រុមងាយរងគ្រោះ និងធានាឱ្យមានការថែទាំ និងព្យាបាលប្រកបដោយគុណភាពសម្រាប់អ្នកដែលមានតម្រូវការ។

នៅក្នុងប្រទេសកម្ពុជា មេរោគអេដស៍មានផលប៉ះពាល់ភាគច្រើនដល់ក្រុមមនុស្សពេញវ័យ ដែលជាវ័យនៃកម្លាំងពលកម្មប្រកបដោយថាមពល។ កម្មករនិយោជិត គឺជាសសរស្តម្ភដ៏សំខាន់មួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ហើយចាំបាច់ត្រូវតែចាត់វិធានការជាបន្តបន្ទាប់ដើម្បីការពារសុខភាព និងសុខុមាលភាពរបស់ពួកគេ។

អង្គការពលកម្មអន្តរជាតិ (ILO) បានចូលរួមចំណែកដ៏ធំធេង នៅក្នុងការដោះស្រាយបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ តាមរយៈការបង្កើតគោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ ដែលបង្ហាញពីគោលការណ៍ឆ្លើយតបនៅកន្លែងធ្វើការដោយផ្អែកលើសិទ្ធិមនុស្ស។ នៅក្នុងឆ្នាំ ២០០៣ អង្គការពលកម្មអន្តរជាតិ បានចាប់ផ្តើមអនុវត្តកម្មវិធីអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ក្រោមការឧបត្ថម្ភហិរញ្ញវត្ថុពីក្រសួងការងារសហរដ្ឋអាមេរិក (ILO/AIDS/USDOL)។ មុនពេលដែលគម្រោងនេះបញ្ចប់ នៅក្នុងឆ្នាំ២០០៧ គម្រោងបានផ្តល់ការអប់រំដល់មនុស្សចំនួន ១២៧០០ នាក់ ដែលធ្វើការងារនៅក្នុងឧស្សាហកម្ម កាត់ដេរ សណ្ឋាគារ សំណង់ និងប្រេងឥន្ធនៈ ក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប។ គំរោង ILO/AIDS/USDOL បានគាំទ្រដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតយន្តការគ្រប់គ្រងតាមរយៈ ប្រកាសស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការនៅក្នុងឆ្នាំ ២០០៦។ អង្គការពលកម្មអន្តរជាតិ តាមរយៈការិយាល័យអនុតំបន់អាស៊ីខាងកើតប្រចាំទីក្រុងបាងកក បាននិងកំពុងផ្តល់ការគាំទ្រដល់ដៃគូត្រីភាគីរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា ដូចជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ សហជីព និងសមាគមនិយោជក ដើម្បីអនុវត្ត គោលការណ៍អនុវត្តនេះ។HS.

ជាពិសេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអង្គការពលកម្មអន្តរជាតិបាន និងកំពុងផ្តល់ការគាំទ្របច្ចេកទេសដើម្បីជួយដៃគូរបស់ខ្លួនអនុវត្ត តាមប្រកាសលេខ ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ។ ប្រកាសលេខ ០៨៦ នេះ តម្រូវឱ្យមានការបង្កើតក្រុមការងារអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតពី ៨ ដល់ ៥០ នាក់ និង តម្រូវឱ្យមានការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចាប់ពី ៥១នាក់ឡើងទៅ។ ដូច្នេះគ្រប់សហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងប្រទេសកម្ពុជា ដែលមានកម្មករនិយោជិត ចាប់ពី ៨ នាក់ឡើងទៅ ត្រូវបង្កើតយន្តការមួយដើម្បីបង្ការទប់ស្កាត់មេរោគអេដស៍ និងលើកកម្ពស់សិទ្ធិរបស់កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ អនុលោមទៅតាម *គោលការណ៍អនុវត្ត ស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ* របស់អង្គការពលកម្មអន្តរជាតិ។

បន្ថែមពីលើការគាំទ្រដល់ដៃគូត្រីភាគីនៅក្នុងប្រទេសកម្ពុជា អង្គការពលកម្មអន្តរជាតិបានគ្រប់គ្រងគម្រោងមូលនិធិពន្លឿនការអនុវត្តគម្រោង (PAF) មួយរបស់ UNAIDS នៅក្នុងឆ្នាំ ២០០៩-២០១០ ដែលមានឈ្មោះថា "ការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ទៅក្នុងកម្មវិធីសុខភាព និងសុវត្ថិភាពការងារ របស់រោងចក្រកាត់ដេរ រួមមាន ការផ្តល់ចំណេះដឹង ចលនាធនធាន និងការគ្រប់គ្រងនៅកន្លែងធ្វើការ "។ គម្រោងនេះ គឺជាគម្រោងបំពេញបន្ថែមដល់គម្រោងមួយរបស់អង្គការពលកម្មអន្តរជាតិ ដែលកំពុងបន្តអនុវត្តការងាររបស់ខ្លួន ដែលមានឈ្មោះថា "រោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC)"។ រោងចក្រកាន់តែប្រសើរនៅកម្ពុជា គឺជាគម្រោងចម្បងមួយរបស់ អង្គការពលកម្មអន្តរជាតិ នៅក្នុងប្រទេសកម្ពុជា ដែលអនុវត្តនៅក្នុងរោងចក្រកាត់ដេររាប់រយ ក្នុងគោលបំណងកែលំអលក្ខខណ្ឌការងារ និង បង្កើនផលិតភាព។

សូមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ និងសង្ឃឹមថាគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់នឹងអនុវត្តតាមគោលការណ៍ណែនាំស្តីពីមេរោគអេដស៍ និង ជម្ងឺអេដស៍នៅកន្លែងធ្វើការប្រកបដោយប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ HS.

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សុត**

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្ដម វង សូត រដ្ឋមន្ត្រី**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំពោះការដឹកនាំ និងការគាំទ្ររបស់ឯកឧត្ដម ដល់កម្មវិធីអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះគ្រប់ដៃគូទាំងអស់របស់អង្គការពលកម្មអន្តរជាតិ មានដូចជា នាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គណៈកម្មការសម្របសម្រួលត្រីភាគី ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ជាពិសេស **ឯកឧត្ដម វេជ្ជបណ្ឌិត ហ៊ុយ ហានសុង** រដ្ឋលេខាធិការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មការនេះ ព្រមទាំងសមាជិក សមាជិកាទាំងអស់ រួមទាំងតំណាងនិយោជក និងសហជីព ដែលបានផ្ដល់ជាគំនិតយោបល់ល្អៗ ក្នុងការងារនេះ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណ ដល់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការពលកម្មអន្តរជាតិ ដែលបានសហការ និងផ្ដល់ការគាំទ្រផ្នែកភ័ស្ដុភារកន្លងមក។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះការចូលរួមចំណែកផ្នែកបច្ចេកទេសដ៏ច្រើនរបស់អ្នកជំនាញការដូចជាៈ លោក ជុន បូរ៉ា ទីប្រឹក្សា លោក អេរិក ស្ដិននើ ខាលសុន (Eric Stener Carlson) អតីតជំនាញការបច្ចេកទេសរបស់អង្គការពលកម្មអន្តរជាតិ ផ្នែកមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារប្រចាំអនុតំបន់អាស៊ីខាងកើត អាស៊ីអាគ្នេយ៍ និងអាស៊ីប៉ាស៊ីហ្វិក លោក រីឆាដ ហូវើដ (Richard Howard) ជំនាញការជាន់ខ្ពស់ផ្នែកមេរោគអេដស៍ និងជម្ងឺអេដស៍របស់អង្គការពលកម្មអន្តរជាតិប្រចាំអនុតំបន់អាស៊ីខាងកើត, លោក ទូម៉ូ ប៉ូទីអៃណិន (Tuomo Poutiainen) ប្រធានទីប្រឹក្សាបច្ចេកទេស និងលោកស្រី ខេតធើរីន វេឡានខត ឡាផ្លេម (Catherine Vaillancourt-Laflamme) អ្នកឯកទេសផ្នែកបណ្ដុះបណ្ដាលរបស់ គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងលោកស្រី ប៉ោ ជួង មន្ត្រីបង្គោលថ្នាក់ជាតិផ្នែកមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ អង្គការពលកម្មអន្តរជាតិ និងក្រុមការងារនៃកម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធនឹងមេរោគអេដស៍ (UNAIDS) នៅក្នុងប្រទេសកម្ពុជា។

ចុងក្រោយ យើងខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងខ្លាំងដល់ UNAIDS ដែលបានបន្តផ្ដល់ការណែនាំ និងការគាំទ្រថវិកាដល់គម្រោងមូលនិធិពន្លឿនការអនុវត្តគម្រោង（PAF）ដែលបានគាំទ្រដល់ការបង្កើតនូវគោលការណ៍ណែនាំទាំងនេះ។

ទីក្រុងបាងកក ខែ ឧសភា ឆ្នាំ ២០១០

Bill Salter
**នាយក**
**ការិយាល័យប្រចាំអនុតំបន់អាស៊ីខាងកើត**
**អង្គការពលកម្មអន្តរជាតិ**

# មាតិកា

**អក្សរកាត់** ....................................................................................................................១

**អំពីគោលការណ៍ណែនាំនេះ**...................................................................................................៣

តើគោលការណ៍ណែនាំនេះនិយាយអំពីអ្វី?..................................................................................៣

របៀបប្រើប្រាស់គោលការណ៍ណែនាំនេះ ..................................................................................៣

តើគោលការណ៍ណែនាំនេះអាចយកទៅអនុវត្តបានក្នុងវិស័យណាខ្លះ?.............................................៤

**មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ** .....................................................................៥

ហេតុអ្វីបានជាមេរោគអេដស៍ និងជម្ងឺអេដស៍គឺជាបញ្ហានៅកន្លែងធ្វើការ?...................................៥

ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ និងការឆ្លើយតបពីកន្លែងធ្វើការៈ......................៦

ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការៈ..............................................៦

និយោជក និងកម្មករនិយោជិតធ្វើការឆ្លើយតបនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ព្រោះពួកគេៈ......................៦

ដោយសហការជាមួយសហជីព តើសហគ្រាសមួយអាចឆ្លើយតបចំពោះមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ដោយអស់ចំណាយតិច ឬមិនចាំបាច់ចំណាយបន្ថែមអ្វីសោះដោយរបៀបណា? ......................................៧

**គណៈកម្មការអេដស៍** .........................................................................................................៩

អ្វីទៅជាគណៈកម្មការអេដស៍?.................................................................................................៩

ហេតុអ្វីចាំបាច់ត្រូវបង្កើតគណៈកម្មការអេដស៍ នៅកន្លែងធ្វើការ? ..............................................៩

ដំណើរការនៃការបង្កើតគណៈកម្មការអេដស៍ នៅក្នុងសហគ្រាស ...............................................១០

តួនាទី និង ការទទួលខុសត្រូវរបស់គណៈកម្មការអេដស៍ .............................................................១០

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិ ...........................................................១១

អ្វីទៅជាគណៈកម្មការសុខភាព និងសុវត្ថិភាពការងារ?...........................................................១២

ការអនុវត្តសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាព និងសុវត្ថិភាពការងាររួមគ្នានៅកម្រិតសហគ្រាស.........................................................................................................................១៣

អត្ថប្រយោជន៍នៃការអនុវត្តសកម្មភាពអប់រំមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាព និងសុវត្ថិភាពការងាររួមគ្នា ................................................................................................................................១៣

បញ្ហាប្រឈមនៃការអនុវត្តសកម្មភាពអប់រំមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាព និងសុវត្ថិភាពការងាររួមគ្នា ..........១៥
សកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ រួមជាមួយនឹងសុខភាព និងសុវត្ថិភាពការងារ ..........១៦
ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ..........១៦
គោលការណ៍ណែនាំស្តីពីសុខភាព និងសុវត្ថិភាពការងាររបស់អាស៊ាន ..........១៧
ឧទាហរណ៍នៃសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ រួមជាមួយនឹងសុខភាព និងសុវត្ថិភាពការងារនៅក្នុងប្រទេសកម្ពុជា ..........១៧
ដំណើរការនៃការបញ្ចូលបញ្ហាអេដស៍ទៅក្នុងសកម្មភាពសុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ ........ ១៩

**គោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ**..........២០
អ្វីទៅជាគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ? ..........២០
ហេតុអ្វីបានជាសហគ្រាសមួយគួរបង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ?...២០
តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ? ..........២១
ជំហានសម្រាប់បង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ..........២១
ជោគជ័យនៃការបង្កើត និងអនុវត្តគោលនយោបាយ ..........២២

**ការអប់រំ និងសេវាទាក់ទងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍**..........២៣
តើព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍អ្វីខ្លះ ដែលគួរផ្តល់ទៅឱ្យកម្មករនិយោជិត? ..........២៣
តើជនបង្គោលអេដស៍ ឬគណៈកម្មការអេដស៍អាចធ្វើអ្វីខ្លះ ដើម្បីបង្កើនការយល់ដឹង ឬផ្សព្វផ្សាយព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ដល់កម្មករនិយោជិត?..........២៣
សកម្មភាពពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ដែលអាចអនុវត្តបាន ដទៃទៀត ដើម្បីផ្តល់ភាពអង់អាចឱ្យកម្មករនិយោជិតមានឥរិយាបថប្រកបដោយការទទួលខុសត្រូវ..........២៤
ឧទាហរណ៍អំពីប្រធានបទសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងជម្ងឺកាមរោគ..........២៥
អ្វីទៅជាមេរោគអេដស៍?.......... ២៥
អ្វីទៅជាជម្ងឺអេដស៍? ..........២៥

តើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ខុសគ្នាដូចម្ដេច? ....... ២៥
តើមេរោគអេដស៍ឆ្លងតាមរបៀបណា? ....... ២៦
តើមេរោគអេដស៍មិនអាចឆ្លងតាមរបៀបណា? ....... ២៦
របៀបបង្ការមេរោគអេដស៍? ....... ២៧
ជម្ងឺកាមរោគ ....... ២៨
របៀបបង្ការជម្ងឺកាមរោគ? ....... ២៨
អ្នកដែលសកម្មនឹងការរួមភេទគួរៈ ....... ២៩
អ្នកដែលធ្វើរោគវិនិច្ឆ័យថាមានជម្ងឺកាមរោគគួរៈ ....... ២៩
រោគសញ្ញារបស់ជម្ងឺកាមរោគ ....... ២៩
ស្រោមអនាម័យ ....... ៣០
ការផ្ដល់ប្រឹក្សាធ្វើតេស្ដឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ....... ៣១
ការព្យាបាល និងការថែទាំ ....... ៣២

**ការរាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃ** ....... ៣៥
ការរាយការណ៍ ....... ៣៥
ការពិនិត្យតាមដាន និងវាយតម្លៃ ....... ៣៥
ឧទាហរណ៍នៃទម្រង់ពិនិត្យតាមដាននៅកន្លែងធ្វើការ ....... ៣៥

**ឯកសារយោង** ....... ៣៨

**ឧបសម្ព័ន្ធ** ....... ៣៩

ឧបសម្ព័ន្ធទី ១ៈ គោលការណ៍សំខាន់៧នៃគោលការណ៍អនុវត្តស្ដីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងាររបស់អង្គការពលកម្មអន្តរជាតិ ....... ៤០
ឧបសម្ព័ន្ធទី ២ៈ ប្រកាស (លេខ ០៨៦) ស្ដីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ....... ៤២
ឧបសម្ព័ន្ធទី ៣ៈ មាត្រាពាក់ព័ន្ធមួយចំនួននៃច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់មេរោគអេដស៍និងជម្ងឺអេដស៍ ....... ៥២

ឧបសម្ព័ន្ធទី ៤:  គោលនយោបាយទូទៅស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ......................៥៧
ឧបសម្ព័ន្ធទី ៥:   បញ្ជីអ្នកផ្តល់សេវាប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងអ្នកផ្តល់សេវាព្យាបាលជម្ងឺកាមរោគ និងព័ត៌មានតាមមូលដ្ឋាន ..........................................................៦១

## អក្សរកាត់

| | |
|---|---|
| AIDS | ជម្ងឺអេដស៍-ចង្កោមរោគសញ្ញាដែលកើតមានឡើងក្រោយពេលប្រព័ន្ធភាពស៊ាំការពារសពាង្គកាយចុះខ្សោយ |
| ARV | ថ្នាំប្រឆាំងមេរោគអេដស៍ |
| BFC | គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា |
| CAMFEBA | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| CBCA | សម្ព័ន្ធពាណិជ្ជកម្មកម្ពុជា ប្រយុទ្ធនឹងជម្ងឺអេដស៍ |
| CCTU | សហភាពសហព័ន្ធសហជីពជាតិកម្ពុជា |
| CLC | សហភាពការងារកម្ពុជា |
| CTA | ប្រធានទីប្រឹក្សាបច្ចេកទេស |
| DOSH | នាយកដ្ឋានពេទ្យការងារ |
| GM | អ្នកចាត់ការទូទៅ |
| GMAC | សមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| HIV | មេរោគអេដស៍- វីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំការពារសពាង្គកាយរបស់មនុស្សចុះខ្សោយ |
| IEC | ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង |
| ILO | អង្គការពលកម្មអន្តរជាតិ |
| MoH | ក្រសួងសុខាភិបាល |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MTCT | ការចម្លងពីម្តាយទៅកូន |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ |
| NACC | សភាសម្ព័ន្ធសហជីពជាតិកម្ពុជា |
| NCHADS | មជ្ឈមណ្ឌលជាតិ ប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| OD | ស្រុកប្រតិបត្តិ |
| OSH | សុខភាព និងសុវត្ថិភាពការងារ |
| PAO | ការិយាល័យអេដស៍ខេត្ត |

| | |
|---|---|
| PAF | មូលនិធិពន្លឿនការអនុវត្តគម្រោង |
| PE | អ្នកអប់រំមិត្ត |
| PLWHA | អ្នករស់នៅជាមួយមេរោគអេដស៍-ជម្ងឺអេដស៍ |
| RHAC | សមាគមថែទាំសុខភាពគ្រួសារកម្ពុជា រ៉ាក់ |
| STI | ជម្ងឺកាមរោគ |
| TCC | គណៈកម្មការសម្របសម្រួលត្រីភាគី ដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ |
| TOR | ការបែងចែកតួនាទី ភារៈកិច្ច |
| TOT | ការបណ្តុះបណ្តាលគ្រូបង្គោល |
| UNAIDS | កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិប្រយុទ្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ |
| USDOL | ក្រសួងការងារនៃសហរដ្ឋអាមេរិក |
| VCCT | ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ |

## អំពីគោលការណ៍ណែនាំនេះ

### តើគោលការណ៍ណែនាំនិយាយអំពីអ្វី?

គោលការណ៍ណែនាំនេះ គឺជាឧបករណ៍បង្ហាញពីរបៀបអនុវត្ត ដែលផ្តល់ការណែនាំជាក់ស្តែងអំពីរបៀបបង្កើតកម្មវិធី និងគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ។ គោលការណ៍ណែនាំនេះគ្របដណ្តប់លើប្រធានបទសំខាន់ៗដូចខាងក្រោមៈ

- ហេតុអ្វីមេរោគអេដស៍ និងជម្ងឺអេដស៍ គឺជាបញ្ហានៅកន្លែងធ្វើការ និងរបៀបដែលសហគ្រាស គ្រឹះស្ថានមួយអាចឆ្លើយតបទៅនឹងបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ដោយចំណាយអស់តិចតួច ឬមិនចំណាយសោះ
- ការបង្កើតគណៈកម្មការអេដស៍ដែលអាចដំណើរការបានល្អ ឬ ការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងកម្មវិធីសុខភាព និងសុវត្ថិភាពការងារដែលមានស្រាប់របស់សហគ្រាសគ្រឹះស្ថាន
- តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការអេដស៍
- របៀបបង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ និង
- របៀបរៀបចំសកម្មភាពបណ្តុះបណ្តាល និង អប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ សម្រាប់កម្មករនិយោជិត។

### របៀបប្រើប្រាស់គោលការណ៍ណែនាំនេះ

នេះគឺជាឧបករណ៍ជាមូលដ្ឋានមួយ ដែលគ្រប់កន្លែងធ្វើការទាំងអស់អាចប្រើប្រាស់ក្នុងការគ្រប់គ្រងបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ នៅតាមសហគ្រាស គ្រឹះស្ថាន របស់ពួកគេ និងអាចប្រើជាមួយសកម្មភាព ដែលមានស្រាប់នៅកន្លែងធ្វើការ ដូចជា សកម្មភាពសុខភាព និងសុវត្ថិភាពការងារ (OSH) ជាដើម។ កន្លែងធ្វើការនីមួយៗ អាចកែសម្រួលគោលការណ៍ណែនាំនេះឱ្យស្របទៅនឹងបរិបទនៅកន្លែងធ្វើការរបស់ខ្លួន។ សហគ្រាស គ្រឹះស្ថានមួយ ចំនួនប្រហែលជាចាំបាច់ត្រូវកែសម្រួលស្ទើរតែគ្រប់ចំណុចទាំងអស់នៅក្នុងគោលការណ៍ណែនាំនេះ។ ប៉ុន្តែសហគ្រាស គ្រឹះស្ថានដទៃទៀតប្រហែលជាចាំបាច់ត្រូវកែសម្រួលតែចំណុចមួយចំនួនតូចប៉ុណ្ណោះ ដើម្បីដាក់បញ្ចូលទៅក្នុងការងារដែលពួកគេកំពុងធ្វើរួចទៅហើយ។

ឧទាហរណ៍ សហគ្រាស គ្រឹះស្ថាន **ក** ប្រហែលជាមិនដែលគិតអំពីការរៀបចំឱ្យមានសកម្មភាព បង្កើនការយល់ដឹងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការរបស់ខ្លួនឡើយ។ ដូច្នេះគោលការណ៍ណែនាំនេះ អាចជួយសហគ្រាស គ្រឹះស្ថាននោះឱ្យៈ

- បង្កើតគណៈកម្មការអេដស៍
- បង្កើតផែនការ ការងារអេដស៍
- រៀបចំវគ្គបង្កើនការយល់ដឹងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ សម្រាប់កម្មករនិយោជិតរបស់ខ្លួន
- ផ្សព្វផ្សាយព័ត៌មានអំពីសេវាបញ្ជូនពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ដល់កម្មករនិយោជិត និង
- បង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

ម្យ៉ាងវិញទៀត សហគ្រាស គ្រឹះស្ថាន **ខ** ប្រហែលជាបានបង្កើតគណៈកម្មការអេដស៍ ដោយមានផែនការការងារអេដស៍ បានលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងបានដាក់បញ្ចូលប្រធានបទមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងព្រឹត្តិការណ៍ពិសេសៗក្នុងរោងចក្ររួចទៅហើយ។ ដូច្នេះ សហគ្រាស **ខ** អាចយកគោលការណ៍ណែនាំនេះ ទៅប្រើប្រាស់ដើម្បីបង្កើត គោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ តែប៉ុណ្ណោះ។

តម្រូវការមានការប្រែប្រួលពីសហគ្រាសមួយ ទៅសហគ្រាសមួយទៀត ដូច្នេះ គេអាចកែសម្រួលគោលការណ៍នេះបានច្រើនបែបច្រើនយ៉ាង ដើម្បីសម្របទៅនឹងតម្រូវការរបស់កន្លែងធ្វើការនីមួយៗ។

### តើគោលការណ៍ណែនាំនេះអាចយកទៅអនុវត្តបានក្នុងវិស័យណាខ្លះ?

គោលការណ៍ណែនាំនេះ ផ្តោតសំខាន់លើវិស័យកាត់ដេរ ប៉ុន្តែវាក៏ជាគោលការណ៍ណែនាំទូទៅដែលអាចយកទៅប្រើប្រាស់បានក្នុងវិស័យដទៃទៀត ដូចជាវិស័យសេវាកម្ម (សណ្ឋាគារ ភោជនីយដ្ឋាន...) និងក្លឹបកម្សាន្តសប្បាយ វិស័យរ៉ែ វិស័យសំណង់ និង វិស័យជាច្រើនផ្សេងទៀត។

មូលដ្ឋាននៃការអន្តរាគមន៍ប្រយុទ្ធនឹងមេរោគអេដស៍នៅកន្លែងធ្វើការ គឺការអនុវត្តគោលការណ៍ទាំង១០ នៃ*គោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ* របស់អង្គការពលកម្មអន្តរជាតិ (ដែលនឹងមានបញ្ជាក់នៅផ្នែកខាងក្រោយក្នុងគោលការណ៍ណែនាំនេះនៅក្នុង***ឧបសម្ព័ន្ធទី ១***)។ ដរាបណាកន្លែងធ្វើការមួយចាប់ផ្តើមប្រើប្រាស់គោលការណ៍ទាំង១០ នេះធ្វើជាមូលដ្ឋានកន្លែងធ្វើការទាំងនោះ អាចកែសម្រួលឯកសារនេះ ទៅតាមលក្ខណៈរបស់សហគ្រាស គ្រឹះស្ថាន និងតម្រូវការពិសេសរបស់ខ្លួនបាន។

## មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

មេរោគអេដស៍ (វីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំការពារសពិង្គកាយរបស់មនុស្សចុះខ្សោយ) វាយប្រហារប្រព័ន្ធភាពស៊ាំរបស់សពិង្គកាយ ធ្វើឱ្យសមត្ថភាពរបស់រាងកាយក្នុងការប្រយុទ្ធនឹងជម្ងឺថយចុះបន្តិចម្តងៗ។ ប្រព័ន្ធភាពស៊ាំ អាចការពារសពិង្គកាយទប់ទល់នឹងការឆ្លងរោគ និងជម្ងឺនានា ប៉ុន្តែមិនអាចការពារសពិង្គកាយ ពីមេរោគអេដស៍បានឡើយ។

ជម្ងឺអេដស៍ (ចង្កោមរោគសញ្ញាដែលកើតមានឡើង ក្រោយពេលដែលប្រព័ន្ធភាពស៊ាំ ការពារសពិង្គកាយចុះខ្សោយ) កើតឡើងនៅពេលដែលប្រព័ន្ធភាពស៊ាំចុះខ្សោយខ្លាំង ធ្វើឱ្យកើតជម្ងឺផ្សេងៗ ដែលអាចបណ្តាលឱ្យស្លាប់បាន។

### ហេតុអ្វីបានជាមេរោគអេដស៍ និងជម្ងឺអេដស៍គឺជាបញ្ហានៅកន្លែងធ្វើការ?

មេរោគអេដស៍ និងជម្ងឺអេដស៍ គឺជាបញ្ហានៅកន្លែងធ្វើការ ព្រោះវាប៉ះពាល់ដល់កម្លាំងពលកម្ម និងផលិតភាព។ កម្មករនិយោជិត និងនិយោជកអាចដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការទប់ស្កាត់ការរាលដាលជម្ងឺនេះ និងលុបបំបាត់ការមាក់ងាយ និងការរើសអើង ដែលពាក់ព័ន្ធនឹងមេរោគអេដស៍។

- មានមនុស្សជាង ៣៣ លាននាក់កំពុងរស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ នៅទូទាំងពិភពលោក។ អ្នកផ្ទុកមេរោគអេដស៍ ៩ នាក់ ក្នុងចំណោម ១០ នាក់ គឺជាមនុស្សពេញវ័យ ដែលស្ថិតក្នុងវ័យកំពុងមានផលិតភាព និងវ័យបន្តពូជ[១]។
- មេរោគអេដស៍ និងជម្ងឺអេដស៍បង្កការគម្រាមកំហែងដល់ជីវភាពរបស់កម្មករនិយោជិតជាច្រើននាក់ និង របស់អ្នកដែលពឹងអាស្រ័យលើពួកគេ ដូចជា គ្រួសារ សហគមន៍ និងសហគ្រាស។ ដូច្នេះ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់អាចធ្វើឱ្យសេដ្ឋកិច្ចជាតិចុះខ្សោយ។
- ការរើសអើង និងការមាក់ងាយអ្នកផ្ទុកមេរោគអេដស៍ គឺជាការគម្រាមកំហែងដល់គោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ និងធ្វើឱ្យអន្តរាយដល់ការខិតខំប្រឹងប្រែងបង្ការ និងផ្តល់ការថែទាំនានា។

---

[១] ILO/AIDS (http://www.ilo.org/public/english/protection/trav/aids/indexmore.htm)

- នៅពុំទាន់មានថ្នាំព្យាបាលមេរោគអេដស៍ និងជម្ងឺអេដស៍នៅឡើយទេ ប៉ុន្តែ ការបង្ការមានប្រសិទ្ធភាព ហើយកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ អាចរស់នៅក្នុងជីវិតប្រកបដោយសេចក្ដីថ្លៃថ្នូរ និង ផលិតភាព នៅ ពេលដែលពួកគេទទួលបានការគាំទ្រពីកន្លែងធ្វើការរបស់ពួកគេ។

នៅក្នុងប្រទេសកម្ពុជា មេរោគអេដស៍មានផលប៉ះពាល់ភាគច្រើនលើក្រុមមនុស្សពេញវ័យ ដែលកំពុងសកម្មនៅក្នុងទីផ្សារការងារ។ កម្មករនិយោជិតទាំងនេះគឺជាផ្នែកមួយដ៏សំខាន់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ប្រទេស។ កន្លែងធ្វើការមានសក្ដានុពលយ៉ាងធំធេង សម្រាប់ការបង្ការមេរោគអេដស៍ តាមរយៈការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន។ វិគ្គលើកកម្ពស់ការយល់ដឹងអាចរៀបចំឡើងយ៉ាងមានប្រសិទ្ធភាព ប្រសិនបើនិយោជក និងកម្មករនិយោជិតធ្វើការងារជាមួយគ្នា។

**ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ និងការឆ្លើយតបពីកន្លែងធ្វើការ :**

**ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ:**

- ធ្វើឱ្យផលិតភាពថយចុះ និងជះឥទ្ធិពលអវិជ្ជមានមកលើការរីកចម្រើនរបស់សេដ្ឋកិច្ច
- កាត់បន្ថយការផ្គត់ផ្គង់កម្លាំងពលកម្ម
- បាត់បង់កម្មករនិយោជិត ដែលមានជំនាញ និងបទពិសោធន៍
- បង្កើនចំណាយលើកម្លាំងពលកម្មសម្រាប់និយោជក (ការធានារ៉ាប់រងសុខភាព)
- បង្កើនអវត្តមាន និងការឆាប់ចូលនិវត្តន៍
- ការមាក់ងាយ និងការរើសអើសចំពោះកម្មករនិយោជិត ដែលមានមេរោគអេដស៍
- ការគម្រាមកំហែងដល់សន្តិសុខស្បៀង ដោយសារតែមានកម្មករនិយោជិតនៅតាមទីជនបទកាន់តែច្រើននាក់ដែលរងផលប៉ះពាល់
- បង្កើនសម្ពាធមកលើសេវាសាធារណៈ និងការផ្គត់ផ្គង់សំខាន់ៗ
- ផលប៉ះពាល់មកលើកម្រិតចំណូលគ្រួសារ របស់កម្មករនិយោជិត
- បង្កើនភាពក្រីក្រ ដោយសារការបាត់បង់ចំណូល និងផលិតភាពគ្រួសារ

**និយោជក និងកម្មករនិយោជិតធ្វើការឆ្លើយតបនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ព្រោះពួកគេះ**

- យកចិត្តទុកដាក់ចំពោះសុខភាព និងសុខុមាលភាពរបស់កម្លាំងពលកម្មរបស់ពួកគេ
- ឱ្យតម្លៃដល់ជំនាញ និងបទពិសោធន៍របស់កម្លាំងពលកម្មរបស់ពួកគេ

- ចង់កាត់បន្ថយចំណាយ និងការរំខាន ដែលពាក់ព័ន្ធជាមួយនឹងជម្ងឺនេះ ប្រសិនបើមិនមានការអនុវត្តសកម្មភាពអ្វីសោះ
- យល់ថាមេរោគអេដស៍ និងជម្ងឺអេដស៍តម្រូវឱ្យមានការឆ្លើយតបពហុវិស័យ ដែលក្នុងនោះមានការចូលរួមពីវិស័យឯកជនផងដែរ
- យល់ថាការឆាប់វិនិយោគលើយុទ្ធនាការអប់រំ បង្ការ និងលើការផ្តល់ការថែទាំសុខភាពអាចចំណាយច្រើននៅពេលដំបូង ប៉ុន្តែនឹងមានអត្ថប្រយោជន៍លើចំណាយរយៈពេលវែង។ ប៉ុន្តែ ការមិនអនុវត្តសកម្មភាពសោះនឹងបង្កើនចំណាយផលិតកម្ម ពាក់ព័ន្ធនឹងកំណើនអត្រាមេរោគអេដស៍ ការរីករាលដាលនូវការមាក់ងាយ និងការរើសអើង ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ និងទំនាក់ទំនងមិនល្អរវាងកម្មករនិយោជិត និងអ្នកគ្រប់គ្រង។

**ដោយសហការជាមួយសហជីព តើសហគ្រាសមួយអាចឆ្លើយតបចំពោះមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ដោយចំណាយអស់តិច ឬមិនចាំបាច់ចំណាយបន្ថែមអ្វីសោះដោយរបៀបណា?**

ដោយមានការសហការគ្នារវាងនិយោជក និងតំណាងកម្មករនិយោជិត កន្លែងធ្វើការនីមួយៗអាចអនុវត្តសកម្មភាពខាងក្រោម ដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ដោយចំណាយតិចតួច ឬមិនចាំបាច់ចំណាយបន្ថែមទាល់តែសោះ:

- ពិនិត្យឡើងវិញលើធនធាន ដែលមានស្រាប់: ស្វែងយល់ថាតើសម្ភារៈអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ ប្រភេទអ្វីខ្លះ ដែលមានរួចហើយ។ សម្ភារៈទាំងនេះអាចរួមមានខិតប័ណ្ណ ឬ កូនសៀវភៅពីក្រសួងសុខាភិបាល អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ UNAIDS និង ឬ អង្គការមិនមែនរដ្ឋាភិបាលនានា។
- បង្កើតគណៈកម្មការអេដស៍ ដែលមានសមាសភាពតំណាងអ្នកគ្រប់គ្រង និងតំណាងកម្មករ និយោជិត ដែលស្របទៅនឹងការអនុវត្តច្បាប់ ប្រកាសស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាម សហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ (ប្រកាសលេខ ០៨៦) ***ដូចក្នុងឧបសម្ព័ន្ធទី២*** ។ កន្លែងធ្វើការក៏អាចបញ្ចូលបញ្ហាអេដស៍ ទៅក្នុងកម្មវិធីដែលមានស្រាប់ផងដែរ ដូចជា កម្មវិធីសុខភាព និងសុវត្ថិភាពការងារជាដើម។

- ចាត់ឱ្យមានមន្ត្រីបង្គោលផ្នែកអេដស៍ម្នាក់ ដែលទទួលខុសត្រូវលើបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ និង បំពេញតួនាទីជាលេខារបស់គណៈកម្មការអេដស៍ ។
- បង្កើតភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាល និង ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយបណ្ដុះបណ្ដាលអ្នកគ្រប់គ្រង និងកម្មករនិយោជិត ។
- បណ្ដុះបណ្ដាលគ្រូបង្គោល និងមិត្តអប់រំមិត្ត (ដោយមានការគាំទ្រពីនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ) ដែលជាអ្នកបន្តអប់រំកម្មករនិយោជិតដទៃទៀត ។
- លើកកម្ពស់ការយល់ដឹង និងអប់រំអំពីការបង្ការមេរោគអេដស៍ (និយោជកគួរតម្រូវ និងលើកទឹកចិត្តកម្មករនិយោជិតនៅគ្រប់កម្រិតទាំងអស់ ឱ្យចូលរួមនៅក្នុងការអប់រំអំពីការបង្ការមេរោគអេដស៍ និងជម្ងឺអេដស៍ជាទៀងទាត់) ។
- រក្សាលំហូរព័ត៌មានជាប្រចាំដល់និយោជិត អំពីរបៀបដែលពួកគេអាចការពារខ្លួនពីមេរោគអេដស៍ និងកន្លែងដែលពួកគេអាចទទួលការព្យាបាលជម្ងឺកាមរោគ និងទទួលការប្រឹក្សា ធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការ សម្ងាត់ ។
- បង្កើតគោលនយោបាយស្ដីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ។
- ធានាយ៉ាងណាឱ្យនិយោជិតទាំងអស់មានគោលនយោបាយស្ដីពីមេរោគអេដស៍ និងជម្ងឺអេដស៍ របស់ក្រុមហ៊ុនម្នាក់មួយច្បាប់ ។
- ឱ្យតំណាងរបស់កម្មករនិយោជិត ចូលរួមប្រមូលព័ត៌មានអំពីការព្រួយបារម្ភ និងសំណួរដែលកម្មករនិយោជិតមានពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ ។
- ជូនដំណឹងដល់កម្មករនិយោជិតថា ក្រុមហ៊ុននឹងជួយកម្មករនិយោជិត គាំទ្រក្រុមកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ ឬបញ្ជូនកម្មករនិយោជិតទៅកាន់សេវាមេរោគអេដស៍ និងជម្ងឺអេដស៍ ។
- ពង្រីកការបង្ការទៅក្រុមហ៊ុនដទៃទៀតនៅក្នុងចង្វាក់ផ្គត់ផ្គង់តែមួយ និង ឬទៅក្នុងសហគមន៍ ។

## គណៈកម្មការអេដស៍

### អ្វីទៅជាគណៈកម្មការអេដស៍?

គណៈកម្មការអេដស៍ គឺជាក្រុម តំណាងនិយោជក និងកម្មករនិយោជិត ដែលធ្វើការងារដោះស្រាយបញ្ហាពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ។ តួនាទីសំខាន់របស់ក្រុមនេះ គឺត្រូវធានាយ៉ាងណាឱ្យគ្រប់គ្នានៅកន្លែងធ្វើការ ទទួលបានព័ត៌មានគ្រប់គ្រាន់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ទៅនឹងមេរោគអេដស៍របស់ពួកគេ និងធានាយ៉ាងណាមិនឱ្យមានការមាក់ងាយ និងការរើសអើង ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ ។

### ហេតុអ្វីចាំបាច់ត្រូវបង្កើតគណៈកម្មការអេដស៍ នៅកន្លែងធ្វើការ?

ប្រកាសលេខ ០៨៦ ត្រូវបានបង្កើតឡើង ដោយមានការគាំទ្រពីសមាគមនិយោជក (ឧ. សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA) សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)) និងសហជីព[២] ។ ប្រកាសនេះបានទទួលការអនុម័តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ប្រកាសលេខ ០៨៦ តម្រូវឱ្យគ្រប់កន្លែងធ្វើការទាំងអស់ នៅក្នុងប្រទេសកម្ពុជា ដែលមានកម្មករនិយោជិត ចាប់ពី ៨ ដល់ ៥០ នាក់ បង្កើតក្រុមការងារអេដស៍មួយ ។

សហគ្រាស គ្រឹះស្ថាន ដែលជួលកម្មករនិយោជិតចាប់ពី ៥១ នាក់ឡើងទៅ ត្រូវបង្កើត គណៈកម្មការអេដស៍មួយ ។ កន្លែងធ្វើការ ដែលបង្កើតគណៈកម្មការអេដស៍ មិនមែនត្រឹមតែអនុលោមទៅតាមច្បាប់ជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបញ្ជូនសារដ៏មានឥទ្ធិពលមួយ បង្ហាញថាពួកគេយកចិត្តទុកដាក់ចំពោះសុខុមាលភាព និងសុខភាពនៃកម្មករនិយោជិតរបស់ពួកគេ ។ ការបង្ហាញពីជំនឿរបស់ពួកគេលើកន្លែងធ្វើការ ដែលផ្តល់នូវសុខភាពល្អ កន្លែងធ្វើការដែលមានសុវត្ថិភាព និងកន្លែងធ្វើការដែលគ្មានការមាក់ងាយ និងការរើសអើង បង្ហាញពីសុច្ឆន្ទៈល្អរបស់ម្ចាស់រោងចក្រ សហគ្រាសទាំងនោះ ។

គណៈកម្មការអេដស៍ នឹងមិនបង្កើតនូវការចំណាយបន្ថែម ក្រៅតែពីការចំណាយពេលវេលារបស់បុគ្គលិក និងការចូលរួមរបស់អ្នកគ្រប់គ្រង ។

---

[២] សហភាពការងារកម្ពុជា (CLC), សភាសម្ព័ន្ធសហជីពជាតិកម្ពុជា (NACC), និង សហភាពសហព័ន្ធសហជីពជាតិកម្ពុជា (CCTU).

## ដំណើរការនៃការបង្កើតគណៈកម្មការអេដស៍ នៅក្នុងសហគ្រាស

- អ្នកចាត់ការទូទៅ (GM) ឬតំណាង រៀបចំកិច្ចប្រជុំ ដើម្បីបង្កើតគណៈកម្មការ អេដស៍ ដោយមានការចូលរួមពីសហជីព ឬតំណាងកម្មករនិយោជិត
- ជ្រើសរើសសមាជិកជាតំណាងនិយោជកផង និងតំណាងកម្មករនិយោជិតផង ( ប្រកាសលេខ ០៨៦)
- សរសេរសំណើសមាសភាពរបស់គណៈកម្មការអេដស៍ និងពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយអ្នកគ្រប់គ្រង និងសហជីព
- ប្រសិនបើមានការព្រមព្រៀងពីភាគីទាំងសងខាង សមាសភាពរបស់គណៈកម្មការនេះ គួរមានការចុះហត្ថលេខាពីអ្នកគ្រប់គ្រងទូទៅ រួចផ្សព្វផ្សាយទៅគ្រប់សមាជិកទាំងអស់ និងបិទផ្សាយលើក្តារខៀន ព័ត៌មានរបស់កម្មករនិយោជិត
- ផ្ញើបញ្ជីឈ្មោះសមាជិកគណៈកម្មការអេដស៍មួយច្បាប់ទៅកាន់នាយកដ្ឋានពេទ្យការងារ (DOSH) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចដែលបានកំណត់នៅក្នុងប្រកាសលេខ ០៨៦
- រៀបចំកិច្ចប្រជុំរបស់គណៈកម្មការនេះ
- រៀបចំសិក្ខាសាលាណែនាំ ឬបណ្តុះបណ្តាលអំពីការបង្កើតគោលនយោបាយស្តីពី មេរោគអេដស៍ និងជម្ងឺអេដស៍ សម្រាប់គ្រប់សមាជិកទាំងអស់របស់គណៈកម្មការ ( ដោយមានការគាំទ្រពីនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្ព័ន្ធពាណិជ្ជកម្មកម្ពុជាប្រយុទ្ធនឹងជម្ងឺអេដស៍ (CBCA) ឬ អង្គការមិនមែនរដ្ឋាភិបាល)

## តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការអេដស៍

តាមប្រកាសលេខ ០៨៦ គណៈកម្មការអេដស៍ត្រូវមានការទទួលខុសត្រូវសំខាន់ៗដូចខាងក្រោមៈ

- ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់របស់ខ្លួន ឱ្យបានយល់ជ្រួតជ្រាបអំពីការបង្កើតគណៈកម្មការអេដស៍ សមាសភាព និងគោលបំណងរបស់គណៈកម្មការនេះ។
- ប្រជុំគ្នាតាមពេលវេលាដែលអាចធ្វើបាន ដើម្បីពិគ្រោះពិភាក្សារៀបចំកម្មវិធី សម្រាប់អប់រំកម្មករនិយោជិត អំពីការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍ និងការប្រយុទ្ធទប់ស្កាត់ការចម្លងមេរោគអេដស៍ និងជម្ងឺអេដស៍

- លើកសំណើទៅនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើរស្បែក និងកាមរោគ (NCHADS) ឬអង្គការមិនមែនរដ្ឋាភិបាល[៣] ដើម្បីសុំជំនួយបច្ចេកទេស ឯកសារ ឬវិធីសាស្ត្រផ្សេងៗ សម្រាប់អប់រំ និងជួយកម្មករនិយោជិតឱ្យយល់ជ្រួតជ្រាបអំពី ការបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ។
- យកចិត្តទុកដាក់អប់រំថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក មេការ ប្រធានផ្នែក ប្រធានក្រុម និងបង្កឱកាសដល់អ្នកទាំងនោះធ្វើការអប់រំបន្តដល់កម្មករនិយោជិតទូទៅ តាមពេលវេលា និងលទ្ធភាពជាក់ស្តែង ប្រកបដោយភាពយោគយល់គ្នា រវាងនិយោជក និងតំណាងកម្មករនិយោជិត ។
- អប់រំកម្មករនិយោជិតទាំងអស់ អំពីយុទ្ធសាស្ត្រនៃការកាត់បន្ថយគ្រោះថ្នាក់ ដោយផ្តល់នូវព័ត៌មានដែលទាក់ទាញការចាប់អារម្មណ៍ហើយច្បាស់លាស់ និងសមស្របទៅនឹងកាលវេលា ។ ក្នុងករណីចាំបាច់ ត្រូវធ្វើយ៉ាងណាឱ្យបុរស និងស្ត្រី ងាយរកបាននូវស្រោមអនាម័យនៅពេលត្រូវការប្រើប្រាស់ ។
- លើកទឹកចិត្តឱ្យឆាប់ធ្វើតេស្ត និង ជួយដល់កម្មករនិយោជិត ដែលមានផ្ទុកមេរោគអេដស៍ ឬ រងផលប៉ះពាល់ដោយសារមេរោគអេដស៍ ឱ្យទទួលបាននូវសេវាសុខាភាព និងការព្យាបាល ក៏ដូចជាព័ត៌មានអំពីវិធានការបង្ការ ដើម្បីកាត់បន្ថយការរីករាលដាលមេរោគអេដស៍ ។ លើកទឹកចិត្តពួកគេឱ្យមានសេចក្តីសង្ឃឹមក្នុងជីវិត និងបន្តការងារជាធម្មតា ។
- ផ្តល់ព័ត៌មានដល់កម្មករនិយោជិតអំពីសេវាថែទាំ និងគាំទ្រ ដែលមានសម្រាប់អ្នកផ្ទុកមេរោគអេដស៍ ។

***ព័ត៌មានលំអិតអំពីដំណើរការនៃការបង្កើតគណៈកម្មការអេដស៍ នៅក្នុងសហគ្រាស និងគ្រឹះស្ថាន និងតួនាទីរបស់គេ សូមមើលប្រកាសលេខ ០៨៦ ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ទី២ ។***

## ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិ

*គោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ* របស់អង្គការពលកម្មអន្តរជាតិ គឺជាគោលការណ៍ណែនាំ ដែលត្រូវបានអនុម័តដោយដៃគូត្រីភាគី ពោលគឺតំណាងនិយោជក

---

[៣] ស្ថាប័នទាំងនេះមិនត្រូវបានលើកឡើងនៅក្នុងប្រកាសលេខ ០៨៦ ឡើយ ប៉ុន្តែជាការល្អ ដែលត្រូវទាក់ទង NCHADS និងអង្គការមិនមែនរដ្ឋាភិបាល ដោយសារតែពួកគេអាចផ្តល់ជំនួយជាការអប់រំ និងការបណ្តុះបណ្តាលអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ដល់កម្មករនិយោជិតបាន

កម្មករនិយោជិត និងរដ្ឋាភិបាល។ គោលការណ៍នេះផ្តល់នូវក្របខ័ណ្ឌដ៏រឹងមាំមួយ ដើម្បីបង្កើត និងអនុវត្ត កម្មវិធី និងគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ។

នៅពេលបោះពុម្ពផ្សាយឯកសារនេះ អង្គការពលកម្មអន្តរជាតិបានបង្កើតបទដ្ឋានការងារអន្តរជាតិ មួយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ ដែលនឹងអនុម័តនៅក្នុងឆ្នាំ ២០១០។ បទដ្ឋាននេះនឹងបន្តគាំទ្រដល់ អនុសាសន៍នានា ដើម្បីបង្កើតគោលនយោបាយ និងគណៈកម្មការនៅកន្លែងធ្វើការ ដូចដែលបានកំណត់នៅក្នុង *គោលការណ៍អនុវត្តនេះ* ។

នៅក្នុងប្រទេសកម្ពុជាវិញ "ច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជម្ងឺអេដស៍" ត្រូវបានអនុម័តដោយរដ្ឋសភា នៅក្នុងឆ្នាំ ២០០២ ដូចក្នុង***ឧបសម្ព័ន្ធទី ៣ ស្តីពីមាត្រាពាក់ព័ន្ធមួយចំនួននៃច្បាប់អេដស៍នេះ***។ ច្បាប់នេះតម្រូវឱ្យគ្រប់សហគ្រាសទាំងអស់បង្កើត និង អនុវត្តកម្មវិធីអេដស៍ ក្នុងសហគ្រាស និងគ្រឹះស្ថានរបស់ខ្លួន ដោយរួមសហការជាមួយស្ថាប័នដែលពាក់ព័ន្ធ របស់ រាជរដ្ឋាភិបាល ដូចជាអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ និង ក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ ២០០៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញនូវ ប្រកាសលេខ ០៨៦ ស្តីពី "ការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការ ទប់ស្កាត់មេរោគអេដស៍និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ"។ ប្រកាសនេះគឺជាការណែនាំដល់សហគ្រាស ទាំងអស់អំពីការទទួលខុសត្រូវរបស់ពួកគេ នៅក្នុងការបង្កើតគណៈកម្មាការអេដស៍ និងអនុវត្តសកម្មភាព បង្ការមេរោគនេះ។

## អ្វីទៅជាគណៈកម្មការសុខភាព និងសុវត្ថិភាពការងារ?

គណៈកម្មការសុខភាព និងសុវត្ថិភាពការងារ (OSH) និង តំណាងរបស់គណៈកម្មការនេះ គឺជា យន្តការចម្បងមួយ សម្រាប់ឱ្យនិយោជក និងកម្មករនិយោជិតធ្វើការសហការគ្នា ដើម្បីកំណត់ និងដោះស្រាយ ការព្រួយបារម្ភអំពីបញ្ហាសុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ។

នៅពេលអនាគតយ៉ាងខ្លីខាងមុខ យើងនឹងគិតគូរពី លទ្ធភាពបង្កើតគណៈកម្មការសុខភាព និង សុវត្ថិភាពការងារ ដែលនៅពេលនោះយើងនឹងរៀបរាប់លំអិតអំពី របៀបបង្កើត និងកំណត់អំពីតួនាទី និងភារកិច្ច របស់គណៈកម្មការនោះ ។

## ការអនុវត្តសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាព និងសុវត្ថិភាពការងាររួមគ្នានៅកម្រិតសហគ្រាស

ដើម្បីចៀសវាងការបង្កើតរចនាសម្ព័ន្ធច្រើន សហគ្រាសគ្រឹះស្ថានណា ដែលមានកម្មវិធីសុខភាព និងសុវត្ថិភាពការងារ ឬកម្មវិធីដ៏ទៃទៀត គួរតែដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងសកម្មភាពកម្មវិធីដែលមានស្រាប់នោះ។ តាមរយៈការដាក់បញ្ចូលបែបនេះ សហគ្រាស គ្រឹះស្ថានអាចទទួលបានអត្ថប្រយោជន៍ជាច្រើន។ ប៉ុន្តែចាំបាច់ត្រូវមានការធានាគុណភាព និងការគ្រប់ដណ្តប់នៃសេវាពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍។

### អត្ថប្រយោជន៍នៃការអនុវត្តសកម្មភាពអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និង សុខភាព និងសុវត្ថិភាពការងាររួមគ្នា

- ***បង្ការការខាតបង់ពេលវេលា:*** "ពេលវេលាជាមាសប្រាក់"។ តាមរយៈការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងកម្មវិធីដែលមានស្រាប់ ដូចជា កម្មវិធីសុខភាព និងសុវត្ថិភាពការងារជាដើម អ្នកគ្រប់គ្រងចំណាយពេលតិចជាងមុន ក្នុងការគ្រប់គ្រង ឬដឹកនាំការខិតខំប្រឹងប្រែងរបស់កម្មវិធីច្រើនផ្សេងគ្នា។ ដោយសារតែសមាជិកក្នុងកម្មវិធីទាំងនោះ អាចជាមនុស្សតែមួយ កិច្ចប្រជុំមួយអាចបញ្ចូលបញ្ហា សុខភាព និងសុវត្ថិភាពការងារផង និងបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ផង ទៅក្នុងរបៀបវារៈតែមួយ។ ការធ្វើបែបនេះអាចប្រើពេលវេលារបស់បុគ្គលិកអស់ពីលទ្ធភាព ដែលជាការសន្សំប្រាក់កាសរបស់ក្រុមហ៊ុន។

- ***កាត់បន្ថយចំណាយសម្រាប់ការបណ្តុះបណ្តាល:*** អ្នកគ្រប់គ្រងអាចសន្សំសំចៃពេលវេលា និងប្រាក់កាស ដោយមិនចាំបាច់បណ្តុះបណ្តាលមនុស្សពីរក្រុមផ្សេងគ្នា។ តាមរយៈការធ្វើដូច្នេះ សហគ្រាសអាចប្រើប្រាស់ធនធានរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព ដោយមិនចាំបាច់ចំណាយដល់ទៅ ២ ដងសម្រាប់អាហារសម្រន់ និងសេវាផ្សេងៗ សម្រាប់កិច្ចប្រជុំ។

- ***ភាពសាមញ្ញនៃរចនាសម្ព័ន្ធ :*** រចនាសម្ព័ន្ធការងារមួយនៅក្នុងសហគ្រាស គ្រឹះស្ថាន មានភាពសាមញ្ញជាងរចនាសម្ព័ន្ធការងារច្រើន និងធ្វើឱ្យការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាពខ្ពស់។ ដោយសារតែធនធានកម្រ គណៈកម្មការតែមួយអាចធ្វើឱ្យការប្រើប្រាស់ធនធានកាន់តែប្រសើរ (ដូចជា ការ

រៀបចំព្រឹត្តិការណ៍ និងការបោះពុម្ពសម្ភារៈអប់រំនានា)។ ភាពសាមញ្ញបែបនេះក៏ជួយដល់ កម្មករ និយោជិតផងដែរ។ ប្រសិនបើពួកគេមានបញ្ហាពាក់ព័ន្ធជាមួយនឹងការកំណត់ពី របៀបធ្វើការងារ ឬ ភ្លើងបំភ្លឺ ឬ មេរោគអេដស៍ និង ជម្ងឺអេដស៍ ពួកគេអាចលើកបញ្ហាទាំងនេះជាមួយតែគណៈកម្មការមួយបាន។

- ***បង្កើន និងធ្វើឱ្យប្រសើរនូវការសម្របសម្រួលព័ត៌មានពាក់ព័ន្ធជាមួយនឹងសុខភាព និងសុវត្ថិភាពការងារ និងមេរោគអេដស៍ និងជម្ងឺអេដស៍:*** ធានាយ៉ាងណាឱ្យការផ្សព្វផ្សាយសារអំពីមេរោគអេដស៍ និងជម្ងឺអេដស៍មានភាពស៊ីសង្វាក់គ្នា។

- ***និរន្តរភាព:*** ការដាក់បញ្ចូលបញ្ហាទាំង ២ (សុខភាព និងសុវត្ថិភាពការងារ និងមេរោគអេដស៍) នេះ មិនត្រឹមតែជួយកាត់បន្ថយចំណាយ និងបង្កើនទិន្នផលការងារប៉ុណ្ណោះទេ ថែមទាំងបង្កើតឱ្យមានការឆ្លើយតបប្រកបដោយនិរន្តរភាពចំពោះបញ្ហាសុខភាព និងសុវត្ថិភាពការងារ និង មេរោគអេដស៍ និងជម្ងឺអេដស៍ផងដែរ។ នៅពេលមានរចនាសម្ព័ន្ធកាន់តែច្រើន ឱកាសបរាជ័យក៏មានកាន់តែច្រើន ធ្វើឱ្យអ្នកគ្រប់គ្រង និងបុគ្គលិកមិនសូវយកចិត្តទុកដាក់បានជិតដល់ចំពោះបញ្ហាសំខាន់ៗ ដូចជាបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ជាដើម។

- ***ការបញ្ជ្រាបៈ*** គោលបំណងសំខាន់ចុងក្រោយ គឺបញ្ជ្រាបបញ្ហាមេរោគអេដស៍ចូលទៅក្នុង " ការងារពាណិជ្ជកម្មជាធម្មតា" ដែលងាយឱ្យយើងសំរេចជោគជ័យបានតាមរយៈការបញ្ចូលបញ្ហាអេដស៍ទៅក្នុងកម្មវិធីសុខភាព និង សុវត្ថិភាពការងារ។ ប៉ុន្តែដោយសារតែការមាក់ងាយ និង ការរើសអើងពាក់ព័ន្ធនឹងមេរោគអេដស៍ ទើបកន្លែងធ្វើការជាច្រើនចាត់ទុកមេរោគអេដស៍ជាបញ្ហាដោយឡែក។ ជាការពិត ដោយសារតែប្រកាសលេខ០៨៦ តម្រូវឱ្យមានការបង្កើតគណៈកម្មការអេដស៍នៅកន្លែងធ្វើការ សហគ្រាស និងគ្រឹះស្ថាន អាចជ្រើសរើសបង្កើតគណៈកម្មការមួយដោយឡែក។ ការធ្វើដូច្នេះមិនមានបញ្ហាអ្វីឡើយ និងមានលក្ខណៈស្របទៅនឹងគោលបំណងរបស់ជាតិ។ ប៉ុន្តែ ជាការល្អដែលអាចមានជម្រើសបញ្ចូលការងារអេដស៍ ទៅក្នុងកម្មវិធីដែលមានស្រាប់ ដើម្បីចៀសវាងបង្កើតរចនាសម្ព័ន្ធច្រើន។

នៅពេលដែលការមាក់ងាយ និងការរើសអើងត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព នៅកន្លែងធ្វើការ ហើយនៅពេលដែលសេវាព្យាបាលអ្នកផ្ទុកមេរោគអេដស៍កាន់តែងាយរកបានស្រួល គេគួរចាត់

ទុកមេរោគអេដស៍ថាជាជម្ងឺរ៉ាំរ៉ៃមួយ ដូចជម្ងឺលើសឈាម ឬទឹកនោមផ្អែមដែរ។ ប៉ុន្តែ ដើម្បីធ្វើឱ្យសម្រេចបាន ការលុបបំបាត់ការមាក់ងាយ និងការរើសអើងពាក់ព័ន្ធនឹងមេរោគអេដស៍ពីកន្លែងធ្វើការ ត្រូវការការបន្ត ការខិតខំប្រឹងប្រែងរយៈពេលវែង។

**បញ្ហាប្រឈមនៃការអនុវត្តសកម្មភាពអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងសុខភាព និងសុវត្ថិភាពការងាររួមគ្នា**

- ***មិនមានបទពិសោធន៍ជាមួយការតស៊ូមតិ និងការផ្លាស់ប្តូរការប្រព្រឹត្តិ:*** វិធីសាស្ត្រឆ្លើយតបនឹងបញ្ហាសុខភាព និង សុវត្ថិភាពការងារនៅក្នុងរោងចក្រ សហគ្រាស អាចមានភាពខុសគ្នាពីវិធីសាស្ត្រឆ្លើយតបនឹងមេរោគអេដស៍។ ការបង្កើតបញ្ជី ផ្ទៀងផ្ទាត់ថា តើមានបំពង់ពន្លត់អគ្គិភ័យ និងមួកសុវត្ថិភាពឬអត់ នៅកន្លែងធ្វើការ គឺខុសគ្នាឆ្ងាយពីការពិភាក្សាអំពីការរួមភេទ និងការលើកទឹកចិត្តឱ្យកម្មករនិយោជិតប្រើស្រោមអនាម័យ និងកាត់បន្ថយចំនួនដៃគូរួមភេទ។ ប៉ុន្តែវិធីសាស្ត្រឆ្លើយតបនឹងបញ្ហាសុខភាព និងសុវត្ថិភាពការងារដែលល្អ ត្រូវមានការតស៊ូមតិ និងការយកចិត្តទុកដាក់ចំពោះឥរិយាបថរបស់កម្មករនិយោជិត ពោលគឺស្រដៀងគ្នានឹងវិធីសាស្ត្រឆ្លើយតបនឹងមេរោគអេដស៍ នៅក្នុងក្រុមហ៊ុនផងដែរ។ ដោយសារតែវិធីសាស្ត្រទាំង ២ មានលក្ខណៈស្រដៀងគ្នា សំខាន់ត្រូវភ្ជាប់ទំនាក់ទំនងកិច្ចខំប្រឹងប្រែងរួមទាំង ២ នេះ ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់ និង និរន្តរភាពនៃការអនុវត្តកម្មវិធី។
- ***ការយល់ច្រឡំថាកម្មករនិយោជិត ដែលផ្ទុកមេរោគអេដស៍ គឺជា "ការគម្រាមកំហែង":*** ការផ្តោតជាប្រពៃណីរបស់សុខភាព និង សុវត្ថិភាពការងារ លើការការពារកម្មករនិយោជិតពីការគម្រាមកំហែងនានា ត្រូវបានគេបកស្រាយខុសថា ជាការការពារកម្មករនិយោជិត ពីកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍។ ដោយសារតែការបកស្រាយខុសនេះហើយ កម្មករនិយោជិត និងនិយោជកអាចគិតពីដំបូងថាការតម្រូវឱ្យធ្វើតេស្តរកមេរោគអេដស៍ គឺជាដំណោះស្រាយមួយ ដើម្បីកុំឱ្យមានបេក្ខជនដែលផ្ទុកមេរោគអេដស៍ដាក់ពាក្យធ្វើការ ដែលធ្វើឱ្យកន្លែងធ្វើការ "មានសុវត្ថិភាព"។ ដើម្បីឱ្យវិធីសាស្ត្រសុខភាព និងសុវត្ថិភាពការងារ និងមេរោគអេដស៍អាចដំណើរការទៅបាន គ្រប់គ្នានៅកន្លែងធ្វើការត្រូវយល់ថា កម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ មិនមែនជាការគម្រាមកំហែងនោះឡើយ ហើយគ្រប់ទម្រង់នៃការរើសអើងទាំងអស់ ដូចជាការតម្រូវឱ្យធ្វើតេស្តរកមេរោគអេដស៍ជាដើម

គឺមិនអាចទទួលយកបានឡើយ។ គ្រប់ដំណោះស្រាយចំពោះបញ្ហាមេរោគអេដស៍ និង សុខភាព និងសុវត្ថិភាពការងារ ដែលមានលក្ខណៈស្ថាបនា គឺជាដំណោះស្រាយដែលលើកកម្ពស់សុខភាពរបស់កម្មករនិយោជិតទាំងអស់ និងអាចជួយការពារសិទ្ធិរបស់ពួកគេផងដែរ។

បញ្ហាប្រឈមទាំងឡាយ ដែលបានលើកឡើងខាងលើ អាចជំនះបាន ដោយប្រើប្រាស់វិធីសាស្ត្រគោរពសិទ្ធិមនុស្ស។ កន្លែងធ្វើការត្រូវធានាសុខភាព និងសុវត្ថិភាពការងារ ដល់កម្មករនិយោជិតរបស់ខ្លួនឱ្យបានល្អបំផុត តាមច្បាប់ស្តីពីការងារ និងប្រកាសរួមលេខ ១៣៩ សកបយ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីលក្ខខណ្ឌ និង បេសកកម្មសេវាពេទ្យសហគ្រាស។ គ្រូពេទ្យសហគ្រាសមានតួនាទីសំខាន់ណាស់នៅក្នុងការងារគណៈកម្មការអេដស៍។

ប៉ុន្តែមិនថាវេទិកាបែបណានោះទេ តំណាងរបស់គណៈកម្មការត្រូវផ្តល់តម្លៃ និងមិនត្រូវបដិសេធបេក្ខជន និង កម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ចេញនោះទេ ដោយធ្វើការតស៊ូមតិ និងរក្សាកិច្ចសន្ទនាស្ថិតស្ថេររវាងកម្មករនិយោជិត និងនិយោជក។

## សកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ រួមជាមួយនឹងសុខភាព និងសុវត្ថិភាពការងារ

### ក្របខ័ណ្ឌច្បាប់និងគោលនយោបាយ

**គោលការណ៍អនុវត្តស្តីពីមេរោគអេដស៍និងជម្ងឺអេដស៍ និង ពិភពការងាររបស់អង្គការពលកម្មអន្តរជាតិ:** គោលការណ៍មួយក្នុងចំណោមគោលការណ៍សំខាន់ៗទាំង ១០ នៃគោលការណ៍អនុវត្តនេះស្នើឱ្យមានការដាក់បញ្ចូលមេរោគអេដស៍ និងជម្ងឺអេដស៍ ចូលទៅក្នុងសកម្មភាព និងកម្មវិធីសុខភាព និង សុវត្ថិភាពការងារ។គោលការណ៍សំខាន់ទី ៤ នៃគោលការណ៍អនុវត្តនេះអំពាវនាវឱ្យមាន *"បរិយាកាសការងារដែលមានសុខភាពល្អ* : បរិយាកាសការងារគួរធ្វើឱ្យមានសុខភាពល្អ និងមានសុវត្ថិភាពដែលអាចអនុវត្តទៅបានសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបង្ការការចម្លងមេរោគអេដស៍ ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃអនុសញ្ញា លេខ១៥៥ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ១៩៨១។ បរិយាកាសការងារដែលធ្វើឱ្យមានសុខភាពល្អ សម្របសម្រួលឱ្យមានសុខភាពរាងកាយ និងផ្លូវចិត្តបានល្អបំផុត ក្នុងទំនាក់ទំនងជាមួយការងារ និងការសម្របការងារឱ្យស្របទៅនឹងសមត្ថភាពរបស់កម្មករនិយោជិត ដោយគិតគូរពិចារណាអំពីសុខភាពរាងកាយ និងផ្លូវចិត្តរបស់ពួកគេ។"

បន្ថែមពីលើគោលការណ៍សំខាន់ខាងលើ ចំណុចទី ៦ របស់គោលការណ៍អនុវត្ត ដែលនិយាយអំពីការបង្ការតាមរយៈព័ត៌មាន និងការអប់រំចែងថា "បើអាចធ្វើទៅបាន កម្មវិធីព័ត៌មាន វគ្គបណ្តុះបណ្តាល និងយុទ្ធនាការនានាគួរដាក់បញ្ចូលទៅក្នុងគោលនយោបាយ និងកម្មវិធីអប់រំ និងបណ្តុះបណ្តាលធនធានមនុស្សដែលមានស្រាប់ រួមទាំងបញ្ហាសុខភាព និងសុវត្ថិភាពការងារផងដែរ ។"

គោលការណ៍អនុវត្តរបស់អង្គការពលកម្មអន្តរជាតិ ក៏បានលើកឡើងពីសារៈសំខាន់នៃការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ ទៅក្នុងការបណ្តុះបណ្តាលសម្រាប់អធិការពេទ្យការងារ និងអធិការការងារផងដែរ ។ អធិការទាំងអស់ គួររៀបចំខ្លួនពង្រឹងការអនុវត្តគោលនយោបាយជាតិ ស្តីពីសិទ្ធិការងារសម្រាប់អ្នកដែលមានមេរោគអេដស៍ និង គោលនយោបាយដទៃទៀតដែលពាក់ព័ន្ធជាមួយនឹងការបង្ការ និងការថែទាំនៅកន្លែងធ្វើការ ។ ដើម្បីសម្រេចគោលដៅនេះបាន ពួកគេគួរទទួលបានការបណ្តុះបណ្តាលឯកទេសអំពីយុទ្ធសាស្ត្របង្ការ និង ការពារមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ។

### គោលការណ៍ណែនាំស្តីពី សុខភាព និងសុវត្ថិភាពការងាររបស់អាស៊ាន

អាស៊ានក៏បានស្នើឱ្យមានការអនុវត្តនូវសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍រួមគ្នាផងដែរ ។ "របាយការណ៍ស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារអាស៊ានចែងថា ក្រសួងការងារគួរតម្រូវឱ្យនិយោជកអនុវត្តសកម្មភាពបង្ការ និងថែទាំមេរោគអេដស៍ និងជម្ងឺអេដស៍ នៅតាមកន្លែងធ្វើការរបស់ពួកគេ អាចជាផ្នែកមួយនៃកម្មវិធីសុខភាព និងសុវត្ថិភាពការងារ ឬ ជាកម្មវិធីដោយឡែក"។ (របាយការណ៍ស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារនៅអាស៊ាន ទំព័រទី ៥៦) ។

### ឧទាហរណ៍នៃសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ រួមជាមួយនឹងសុខភាព និងសុវត្ថិភាពការងារ នៅក្នុងប្រទេសកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់បញ្ចូលមេរោគអេដស៍ និងជម្ងឺអេដស៍ជាអាទិភាពមួយក្នុងចំណោមសកម្មភាពជាអាទិភាពចំនួន ៦ នៅក្នុង "ផែនការមេលើកទី ១ ស្តីពីសុខភាព និងសុវត្ថិភាពការងារ ឆ្នាំ ២០០៩-២០១៣" របស់ខ្លួន។ ផែនការនេះចែងថា *"សកម្មភាពទី ៦: ជំរុញការអនុវត្តច្បាប់ និងសកម្មភាពរួមសហការជាមួយ..... និងគម្រោងបង្ការមេរោគអេដស៍ និងជម្ងឺអេដស៍*។ ផែនការនេះគូសបញ្ជាក់នៅក្នុងសកម្មភាពតូចៗចំនួន ២ ថា *៦-២ " ជំរុញការអនុវត្តប្រកាសលេខ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍*

*នៅកន្លែងធ្វើការ"* និង *៦-៣ " ធ្វើកិច្ចសហប្រតិបត្តិការជាមួយសកម្មភាពគម្រោងស្តីពីបង្ការមេរោគអេដស៍ និង ជម្ងឺអេដស៍ផ្សេងៗដទៃទៀត និងគម្រោងស្តីពីសុខភាព និងសុវត្ថិភាពការងារ "*។ ផែនការមេនេះ ក៏បាន លើកឡើងនៅក្នុងយុទ្ធសាស្ត្រមួយរបស់ខ្លួនឱ្យ " ពិនិត្យមើលឡើងវិញរួមគ្នាលើសកម្មភាពផ្នែកសុខភាព និង សុវត្ថិភាពការងារ និងមេរោគអេដស៍ និងជម្ងឺអេដស៍ដែលមានស្រាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង បង្កើតផែនការសកម្មភាពរួមគ្នា"។ ជាការឆ្លើយតបទៅនឹងសកម្មភាពជាយុទ្ធសាស្ត្រទាំងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយគម្រោងអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ របស់អង្គការពលកម្មអន្តរជាតិ បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអធិការសុខភាព និងសុវត្ថិភាពការងារ ទាំងអស់ និងអធិការការងារមួយចំនួនអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ។ សកម្មភាពដែល ពាក់ព័ន្ធក្នុងផែនការនេះ ជួយលើកកម្ពស់ការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងកម្មវិធី សុខភាព និងសុវត្ថិភាពការងារ និងការដាក់បញ្ចូលកម្មវិធីសុខភាព និងសុវត្ថិភាពការងារ ទៅក្នុងកម្មវិធី មេរោគអេដស៍ និងជម្ងឺអេដស៍វិញផងដែរ។

សេចក្តីពិពណ៌នាខាងលើផ្តល់នូវការគាំទ្រយ៉ាងរឹងមាំផ្នែកច្បាប់ និងបច្ចេកទេសសម្រាប់សហគ្រាស ដែលអនុវត្តសកម្មភាពមេរោគអេដស៍ និងជម្ងឺអេដស៍ រួមជាមួយនឹងសកម្មភាពសុខភាព និងសុវត្ថិភាពការងារ នៅក្នុងកម្មវិធី និងគោលនយោបាយរបស់ខ្លួន។

## ដំណើរការនៃការបញ្ចូលបញ្ហាអេដស៍ទៅក្នុងសកម្មភាពសុខភាព និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ

ជំហាន ដើម្បីដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ចូលទៅក្នុងកម្មវិធីសុខភាព និង សុវត្ថិភាពការងារដែលមានស្រាប់ គឺ ស្រដៀងគ្នានឹងជំហានសម្រាប់បង្កើតគណៈកម្មការអេដស៍ខាងលើដែរ:

- ពិភាក្សាអំពីលទ្ធភាពនៃដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ចូលទៅក្នុងកម្មវិធីសុខភាព និងសុវត្ថិភាពការងារ
- បង្ហាញដល់សមាជិកទាំងអស់អំពីសមាសភាពគណៈកម្មការអេដស៍ ដែលពួកគេភាគច្រើន គឺជាមនុស្ស តែមួយ ទៅនឹងសមាជិករបស់កម្មវិធីសុខភាព និងសុវត្ថិភាពការងារ
- បង្ហាញដល់សមាជិកកម្មវិធីសុខភាព និងសុវត្ថិភាពការងារ អំពីតួនាទី និងការទទួលខុសត្រូវដែល ពាក់ព័ន្ធនឹងការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងកម្មវិធីសុខភាព និងសុវត្ថិភាព ការងារ (សកម្មភាពផ្ទៃក្នុង)
- ពិភាក្សាអំពីអត្ថប្រយោជន៍នៃការដាក់បញ្ចូលបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ ទៅក្នុងកម្មវិធី សុខភាព និងសុវត្ថិភាពការងារ (ដូចដែលបានលើកឡើងនៅក្នុង ចំនុចខាងលើ)
- បង្ហាញពីការងារពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ឱ្យបានច្បាស់លាស់ នៅក្នុងតួនាទី និង ការទទួលខុសត្រូវរបស់សមាជិកកម្មវិធីសុខភាព និងសុវត្ថិភាពការងារ ... ។ល។
- ជាការសំខាន់ អ្នកដែលកំពុងធ្វើការងារពាក់ព័ន្ធនឹងមេរោគអេដស៍ ចាប់ផ្តើមដាក់បញ្ចូលបញ្ហាមេរោគ អេដស៍ទៅក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។ ការងារនេះងាយស្រួលធ្វើ និងមិនត្រូវការចំណាយបន្ថែម អ្វីទាំងអស់។

# គោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ

## អ្វីទៅជាគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ?

គោលនយោបាយរបស់កន្លែងធ្វើការ គឺជាសេចក្តីថ្លែងអំពីគោលបំណង និងក្របខ័ណ្ឌសកម្មភាព។ គោលនយោបាយនេះ គួរបង្កើតគោលការណ៍ដាក់ចេញនូវនីតិវិធី និងការការពារសិទ្ធិ។ គោលនយោបាយនេះ ថ្លែងយ៉ាងច្បាស់អំពីឥរិយាបថមួយចំនួន ដែលគ្រប់បុគ្គលិក និងកម្មករនិយោជិតទាំងអស់គួរធ្វើតាម នៅពេលនិយាយ ឬធ្វើសកម្មភាពពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍។ គោលនយោបាយនេះគួរៈ

- សរសេរដោយប្រើប្រាស់ភាសាសាមញ្ញ ងាយស្រួលយល់
- ផ្អែកទៅតាមការពិគ្រោះយោបល់រវាងកម្មករនិយោជិត និងអ្នកគ្រប់គ្រង
- ដាក់បញ្ចូលនូវការប្តេជ្ញាចិត្ត ដាក់ចេញជាគោលដៅ ដែលអាចវាស់វែងបាន ដើម្បីធានាយ៉ាងណាឱ្យកន្លែងធ្វើការក្លាយជាកន្លែងដែលគ្មានការរើសអើង
- ដាក់បញ្ចូលនូវការប្តេជ្ញាចិត្តអនុវត្តតាមច្បាប់អេដស៍ ប្រកាស និងគោលការណ៍ណែនាំនានារបស់ក្រសួង
- ចងក្រងជាឯកសារ អនុវត្ត និងផ្សព្វផ្សាយដល់គ្រប់កម្មករនិយោជិតទាំងអស់
- ផ្តល់ជាព័ត៌មានដល់ភាគីដែលពាក់ព័ន្ធ និង
- ពិនិត្យឡើងវិញជាប្រចាំ ដើម្បីធានាយ៉ាងណាឱ្យគោលនយោបាយនេះ នៅតែទាក់ទង និងសមស្របសម្រាប់សហគ្រាស

## ហេតុអ្វីបានជាសហគ្រាសមួយគួរបង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ?

- ដើម្បីធានាយ៉ាងណាឱ្យក្រុមហ៊ុនរបស់ខ្លួនអនុលោមទៅតាមក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាតិ និង អន្តរជាតិ ស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ។
- ដើម្បីប្រាប់ដល់អ្នកគ្រប់គ្រង និងកម្មករនិយោជិតថា នៅកន្លែងធ្វើការនេះ មានគោលនយោបាយ និងកម្មវិធីបង្ការ និងថែទាំទាក់ទងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍។ និយោជកគួរធ្វើឱ្យកម្មករនិយោជិតដឹងអំពីសិទ្ធិ និង ការទទួលខុសត្រូវរបស់ពួកគេ។

- ដើម្បីថ្លែងបញ្ជាក់យ៉ាងច្បាស់លាស់ថា ពុំមានការរើសអើងចំពោះកម្មករនិយោជិត ដែលផ្ទុកមេរោគអេដស៍ឡើយ ។
- ដើម្បីផ្តល់ការណែនាំអំពីរបៀបឆ្លើយតបចំពោះមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ និង បង្ហាញពីការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ចំពោះការអនុវត្តសកម្មភាព ។
- ដើម្បីជួយឱ្យកម្មករនិយោជិតដែលរស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍យល់ដឹងអំពីការគាំទ្រ និងការថែទាំ ដែលពួកគេនឹងទទួលបានពីប្រព័ន្ធសុខាភិបាល ។
- ដើម្បីជួយកាត់បន្ថយការឆ្លងរាលដាលនៃវីរុសនេះ តាមរយៈកម្មវិធីអប់រំ ។
- ដើម្បីទប់ស្កាត់ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍ ដែលមានន័យថា ជាការសន្សំសំចៃប្រាក់កាស ។
- ដើម្បីជម្រុញឱ្យមាននិរន្តរភាពនៃការប្តេជ្ញាចិត្ត ដើម្បីដោះស្រាយបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ ។

## តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ?

គោលនយោបាយនានាគួរបង្កើតឡើងដោយអ្នកគ្រប់គ្រង និង កម្មករនិយោជិត ដោយមានការចូលរួមពីអ្នកដែលរស់នៅជាមួយមេរោគអេដស៍ ( ប្រសិនបើមាន ) ។ គោលនយោបាយគួរឆ្លើយតបទៅនឹងតម្រូវការ និងស្ថានភាពនៅក្នុងសហគ្រាស ។ ជាធម្មតា គោលនយោបាយនេះត្រូវបានបង្កើតឡើងដោយគណៈកម្មការអេដស៍ ដែលមានសមាជិកជាតំណាងនិយោជក និងតំណាងកម្មករនិយោជិត ។ ផ្នែកសំខាន់បំផុត របស់ដំណើរការនេះ គឺអ្នកគ្រប់គ្រង និងកម្មករនិយោជិតត្រូវបង្កើតគោលនយោបាយមួយ ផ្អែកទៅតាមកិច្ចសន្ទនាការយោគយល់ និង ការគោរពគ្នាទៅវិញទៅមក ។

## ជំហានសម្រាប់បង្កើតគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

- បង្កើតគណៈកម្មការអេដស៍ និងតែងតាំងជនបង្គោលអេដស៍ម្នាក់ ដែលជាអ្នកទទួលខុសត្រូវជាពិសេសលើបញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍នៅក្នុងសហគ្រាស ។ ជនបង្គោលគួរបំពេញតួនាទីជាលេខាធិការរបស់គណៈកម្មការនោះ ។

- កំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មការ (ការបែងចែកតួនាទី ភារកិច្ច) និងអំណាចក្នុងការសម្រេចចិត្ត។
- ពិនិត្យលើច្បាប់ជាតិ លិខិតបទដ្ឋាន និងភាពពាក់ព័ន្ធរបស់ច្បាប់ទាំងនោះ ចំពោះកន្លែងធ្វើការ ដូចជាគោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍របស់អង្គការពលកម្មអន្តរជាតិ និង ប្រកាសលេខ០៨៦ ជាដើម។
- ពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយអ្នកគ្រប់គ្រង និងកម្មករនិយោជិតដើម្បីទទួលបាន "ភាពជាម្ចាស់ និងការគាំទ្រ"។
- បង្កើតសេចក្តីព្រាងគោលនយោបាយ ផ្អែកទៅតាមការពិគ្រោះយោបល់។
- អនុម័តលើគោលនយោបាយ ដោយប្រើប្រាស់ភាសាច្បាស់លាស់ និងងាយស្រួលយល់។
- បង្កើតកម្មវិធី និងផែនការសកម្មភាព ដែលកំណត់ពេលវេលា និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ដើម្បីអនុវត្តគោលនយោបាយនេះ។
- បង្កើតយន្តការត្រួតពិនិត្យ ដើម្បីពិនិត្យតាមដានការអនុវត្ត និងលទ្ធផលរយៈពេលវែងរបស់គោលនយោបាយ។
- ពិនិត្យ និងប្រៀបធៀបគោលនយោបាយនេះជាទៀងទាត់ ជាមួយព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ខាងក្រៅ និងវាយតម្លៃភាពពាក់ព័ន្ធរបស់ព័ត៌មានទាំងនេះជាមួយនឹងកន្លែងធ្វើការ មានន័យថា តើគោលនយោបាយនេះនៅមានភាពរស់រវើក និងឆ្លើយតបចំពោះស្ថានភាពខាងក្រៅ និងគំនិតផ្តួចផ្តើមថ្មីៗដែរឬទេ?

## ជោគជ័យនៃការបង្កើត និងអនុវត្តគោលនយោបាយ

ជោគជ័យនៃការបង្កើត និងអនុវត្តគោលនយោបាយពឹងអាស្រ័យយ៉ាងខ្លាំងលើៈ

- ការប្តេជ្ញាចិត្ត ការចូលរួម និងការគាំទ្ររបស់និយោជក និងអ្នកគ្រប់គ្រង នៅកន្លែងធ្វើការ
- ការចូលរួម និងការគាំទ្ររបស់សហជីព
- ការផ្សព្វផ្សាយគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នេះឱ្យបានញឹកញាប់
- ការពិនិត្យតាមដាន និងការវាយតម្លៃការអនុវត្តគោលនយោបាយនេះ

***→សូមមើលក្នុងឧបសម្ព័ន្ធទី ៤: គោលនយោបាយទូទៅស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ***

## ការអប់រំ និងសេវានានាក់ទងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍

### តើព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍អ្វីខ្លះដែលគួរផ្តល់ទៅឱ្យកម្មករនិយោជិត?

កម្មករនិយោជិតគួរដឹងពីព័ត៌មានជាមូលដ្ឋានអំពីការចម្លង និងការបង្ការមេរោគអេដស៍។ កម្មករនិយោជិតគួរដឹង ពីគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ ។គួរផ្តល់ព័ត៌មានស្តីពីការព្យាបាលជម្ងឺកាមរោគ ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ព្រមទាំងការថែទាំ និង ព្យាបាលមេរោគអេដស៍ ។

**កន្លែងធ្វើការមិនចាំបាច់ផ្តល់សេវាទាំងអស់ដូចជា សេវាប្រឹក្សា ការធ្វើតេស្តឈាម និងពិនិត្យសុខភាព... ។ល។ ឡើយ ប៉ុន្តែ កន្លែងធ្វើការគួរមានតួនាទីជាបណ្តាញផ្សារភ្ជាប់ជាមួយនឹងសេវាកម្មដែលមានស្រាប់នៅក្នុងសហគមន៍ ។**

### តើជនបង្គោលអេដស៍ ឬគណៈកម្មការអេដស៍អាចធ្វើអ្វីខ្លះ ដើម្បីបង្កើនការយល់ដឹង ឬផ្សព្វផ្សាយព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ដល់កម្មករនិយោជិត?

ជនបង្គោលអេដស៍ ឬគណៈកម្មការអេដស៍អាចរៀបចំឱ្យមានការបង្កើនការយល់ដឹងសម្រាប់កម្មករនិយោជិត តាមវិធីជាច្រើនៈ

- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលៈ បណ្តុះបណ្តាលបុគ្គលិករបស់រោងចក្រ សហគ្រាស ឱ្យចេះបណ្តុះបណ្តាលដល់កម្មករនិយោជិត (តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលគ្រូបង្គោល) និង ឬ បណ្តុះបណ្តាលកម្មករនិយោជិត ឱ្យចេះអប់រំមិត្តរួមការងាររបស់ពួកគេ (មិត្តអប់រំមិត្ត)។ គេអាចសុំជំនួយបច្ចេកទេសពីអង្គការស្ម័គ្រចិត្ត នៅក្នុងសហគមន៍ ដែលមានបំណងចង់ជួយ ។
- លើកទឹកចិត្តមិត្តអប់រំមិត្តឱ្យនិយាយជាមួយមិត្តរួមការងាររបស់ពួកគេអំពីការបង្ការមេរោគអេដស៍ នៅពេលសម្រាកញុំាបាយថ្ងៃត្រង់ ឬពេលងាយស្រួលនិយាយគ្នាផ្សេងៗទៀត និងរៀបចំការសន្ទនាជាក្រុមនៅក្នុងរោងចក្រ ។

- រៀបចំមិត្តអប់រំមិត្តឱ្យធ្វើការបញ្ជូនដោយលាក់ការសម្ងាត់ទៅកាន់សេវាដែលមានគុណភាពដើម្បីទទួលបានការព្យាបាលជម្ងឺកាមរោគ និងការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។
- បិទផ្សាយព័ត៌មានទូទៅអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងព័ត៌មានអំពីសេវាមេរោគអេដស៍ និងជម្ងឺអេដស៍នៅលើក្តារខៀនព័ត៌មានរបស់រោងចក្រ និងនៅតាមកន្លែងដទៃទៀតនៅក្នុងរោងចក្រ ដែលកម្មករនិយោជិតងាយស្រួលឃើញ និងចែកខិតប័ណ្ណផ្សព្វផ្សាយដល់កម្មករនិយោជិត។
- បោះពុម្ពសារបង្ការមេរោគអេដស៍ និងជម្ងឺអេដស៍ និងឬព័ត៌មានសំខាន់ៗអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅលើប៉ុងបើកប្រាក់ឈ្នួលបើអាចធ្វើបាន។
- ចែកលេខទូរស័ព្ទសាកសួរអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ដោយមិនគិតថ្លៃ ដល់កម្មករនិយោជិត ឧ. លេខទូរស័ព្ទសមាគមឥន្ទនូ ០១២ ៩៩៩ ០០៨, ០១២ ៩៩៩ ០០៩, ០៩២ ៩១៤ ១១១។
- ផ្តល់ឱ្យកម្មករនិយោជិតនូវបញ្ជីឈ្មោះអ្នកផ្តល់សេវាពាក់ព័ន្ធមេរោគអេដស៍ និងជម្ងឺអេដស៍ ដូចជា សេវាព្យាបាលជម្ងឺកាមរោគ និងសេវាផ្តល់ប្រឹក្សា ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។

→ ***សូមមើលក្នុងឧបសម្ព័ន្ធទី ៥: បញ្ជីឈ្មោះអ្នកផ្តល់សេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការ សម្ងាត់ សេវានិងព័ត៌មានអំពីជម្ងឺកាមរោគ***

**សកម្មភាពពាក់ព័ន្ធជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ដែលអាចអនុវត្តបានដទៃទៀត ដើម្បីផ្តល់ភាពអង់អាចឱ្យកម្មករនិយោជិតមានឥរិយាបថប្រកបដោយការទទួលខុសត្រូវ**

ក្រុមហ៊ុនអាចបញ្ចូលកម្មវិធីជជែក ឬសួរសំណួរអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ ក្នុងពិធីនានាដែលមាននៅក្នុងសហគ្រាស គ្រឹះស្ថាន ដូចជា:

- ពិធីជប់លៀងចូលឆ្នាំថ្មី
- ពិធីអបអរទិវាសិទ្ធិនារីអន្តរជាតិ
- ពិធីអបអរទិវាពលកម្មអន្តរជាតិ
- ពិធីខួបកំណើតរបស់បុគ្គលិក ឬពិធីផ្សេងទៀតនៅក្នុងក្រុមហ៊ុន

## ឧទាហរណ៍អំពីប្រធានបទសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ និង ជម្ងឺកាមរោគ

### អ្វីទៅជាមេរោគអេដស៍?

មេរោគអេដស៍ (វីរុសដែលធ្វើឱ្យប្រព័ន្ធភាពសាំុការពារសពិាង្គកាយរបស់មនុស្សចុះខ្សោយ) វាយប្រហារប្រព័ន្ធភាពសាំុរបស់សពិាង្គកាយ។ ប្រព័ន្ធភាពសាំុ អាចការពារសពិាង្គកាយទប់ទល់នឹងការឆ្លងរោគ និង ជម្ងឺនានា ប៉ុន្តែមិនអាចការពារសពិាង្គកាយពីមេរោគអេដស៍បានឡើយ។ នៅក្នុងរយៈពេលមួយ (ជាធម្មតារវាង ៥ និង ១០ ឆ្នាំ) មនុស្សភាគច្រើនដែលឆ្លងមេរោគអេដស៍ នឹងកាន់តែមិនអាចតទល់នឹងជម្ងឺនានាបាន។

### អ្វីទៅជាជម្ងឺអេដស៍?

ជម្ងឺអេដស៍ (ចង្កោមរោគសញ្ញាដែលកើតមានឡើង ក្រោយពេលដែលប្រព័ន្ធភាពសាំុការពារសពិាង្គកាយចុះខ្សោយ) គឺជាដំណាក់កាលកាន់តែធ្ងន់ធ្ងរនៃការវិវឌ្ឍន៍របស់មេរោគអេដស៍។ អ្នកផ្ទុកមេរោគអេដស៍ចាប់ផ្តើមមានជម្ងឺអេដស៍ នៅពេលដែលប្រព័ន្ធភាពសាំុការពារសពិាង្គកាយចុះខ្សោយខ្លាំង ដែលធ្វើឱ្យវាមិនអាចការពារសពិាង្គកាយពីការបង្ករោគ និងជម្ងឺផ្សេងៗបាន។

### តើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ខុសគ្នាដូចម្តេច?

- មេរោគអេដស៍បង្កឱ្យមានជម្ងឺអេដស៍។ មនុស្សដែលផ្ទុកមេរោគអេដស៍អាចនៅតែមានសុខភាពល្អ និងអាចធ្វើការងារបាន។ ការធ្វើការងារជាមួយអ្នកផ្ទុកមេរោគអេដស៍ មិនបង្កឱ្យមានការឆ្លងមេរោគនេះឡើយ។ តាមពិតទៅមេរោគនេះអាចឆ្លងតែ តាមរយៈការរួមភេទតាមយោនី តាមរន្ធគូថ និងតាមមាត់ ដោយមិនមានការការពារ ការប្រើម្ជុលរួមគ្នា ពេលប្រើប្រាស់ចាក់គ្រឿងញៀនគ្រោះថ្នាក់ ដែលធ្វើឱ្យឈាមរបស់មនុស្សម្នាក់ ចូលទៅក្នុងសសៃឈាមរបស់មនុស្សម្នាក់ទៀត ឬការចម្លងពីម្តាយទៅកូនពេល មានផ្ទៃពោះ ពេលសម្រាល និងតាមរយៈការបំបៅកូនដោយទឹកដោះម្តាយ។
- ជម្ងឺអេដស៍ គឺជាចង្កោមរោគសញ្ញាដែលកើតឡើងក្រោយពេលប្រព័ន្ធភាពសាំុការពារសពិាង្គកាយចុះខ្សោយ ដែលបង្ហាញពីដំណាក់កាលកាន់តែធ្ងន់ធ្ងរនៃការឆ្លងមេរោគអេដស៍នៅពេលដែលប្រព័ន្ធ

ភាពស៊ាំលែងដំណើរការបានល្អតទៅទៀត។ អ្នកជម្ងឺអេដស៍ អាចលេចចេញសញ្ញា និង រោគសញ្ញាជម្ងឺច្រើនព្រមគ្នាហើយប្រសិនបើគេទុកមិនព្យាបាលរោគសញ្ញានោះទេអ្នកជម្ងឺអាចស្លាប់បាន។

**តើមេរោគអេដស៍ឆ្លងតាមរបៀបណា?**

មេរោគអេដស៍ឆ្លង:

- តាមរយៈការរួមភេទ (តាមយោនី តាមរន្ធគូថ និង តាមមាត់) ដោយមិនមានការការពារ ជាមួយដៃគូដែលមានផ្ទុកមេរោគអេដស៍។ ការចម្លងអាចកើតឡើងរវាងបុរសនិងស្ត្រី រវាងបុរសនិងបុរស ឬ រវាងស្ត្រី និងស្ត្រី ដែលមានទំនាក់ទំនងផ្លូវភេទជាមួយគ្នា។
- តាមរយៈឈាម ឬផលិតផលឈាម ដែលមានមេរោគអេដស៍ ដូចជាការបញ្ចូលឈាម ឬការប្រើម្ជុលដែលមានមេរោគជាមួយគ្នា ដើម្បីចាក់គ្រឿងញៀន។
- ពីម្តាយទៅកូន ដែលគេហៅថាការចម្លងពីម្តាយទៅកូន និងដែលអាចកើតឡើង:
    - o មុនកំណើត (មានផ្ទៃពោះ)
    - o ក្នុងពេលសម្រាល ឬ
    - o តាមរយៈការបំបៅកូនដោយទឹកដោះម្តាយ

**តើមេរោគអេដស៍មិនអាចឆ្លងតាមរបៀបណាខ្លះ?**

មេរោគអេដស៍មិនអាចចម្លង តាមរយៈ :

- ការប៉ះពាល់ជាធម្មតា ដូចជា ចាប់រលាក់ដៃ ឱប ឬ ថើប
- មូស ឬសត្វល្អិតខាំ
- ក្អក ឬកណ្តាស
- ប្រើសម្ភារៈផ្ទះបាយរួមគ្នា ដូចជា ពែង ចាន ស្លាបព្រា សម ឬកាំបិត
- ទទួលទានអាហារ ដែលចម្អិនដោយអ្នកផ្ទុកមេរោគអេដស៍
- ទឹកភ្នែក ទឹកមាត់
- ប្រើបង្គន់រួមគ្នា
- ធ្វើការងារជាមួយគ្នា

### របៀបបង្ការមេរោគអេដស៍?

- តមមិនរួមភេទ[៤]
- ស្មោះត្រង់មួយទល់មួយជាមួយដៃគូរួមភេទ ដែលមិនមានផ្ទុកមេរោគអេដស៍
- ធានាឱ្យមានរបាំងការពារការចម្លងមេរោគ ដូចជា:
    - o ប្រើស្រោមអនាម័យ
    - o ប្រើសម្ភារៈការពារ ( ជាពិសេសស្រោមដៃកៅស៊ូ )
    - o ធានាថាសម្ភារៈ ដែលអាចចាក់ទម្លុះស្បែកបាន ដូចជា ម្ជុល ស៊ីរ៉ាំង និងឧបករណ៍វះកាត់ មិនមានជាប់មេរោគ
- ក្នុងករណីមានគ្រោះថ្នាក់កើតឡើង សំខាន់ត្រូវធ្វើតាមវិធីបង្ការការចម្លងរោគជាសកលចំពោះឈាម និង អង្គធាតុរាវរបស់សពាង្គកាយ (ដែលគេហៅថា ការបង្ការជាសកល ឬការប្រុងប្រយ័ត្នជាស្តង់ដា ដែលត្រូវបានបង្កើតឡើងដំបូងនៅក្នុងឆ្នាំ ១៩៨៥): ពាក់ស្រោមដៃកៅស៊ូ មុនពេលប៉ះពាល់នឹង អង្គធាតុរាវ គ្រប់ប្រភេទរបស់សពាង្គកាយ។ បើទោះបីជាបម្រុងប្រយ័ត្នទាំងនេះត្រូវបានបង្កើតឡើង សម្រាប់វិស័យវេជ្ជសាស្ត្រក៏ដោយ យកល្អត្រូវធានាយ៉ាងណាឱ្យកម្មករនិយោជិតរបស់អ្នកដឹង ពីរបៀបការពារ ខ្លួនពី ជម្ងឺដែលឆ្លងតាមរយៈឈាម។ ខាងក្រោមនេះ គឺជាវិធីបង្ការជាសកលៈ
    - o ប៉ះពាល់ និងចោលរបស់មុតស្រួចដោយប្រុងប្រយ័ត្ន (ដូចជា ម្ជុល ឬវត្ថុមុតស្រួចដទៃទៀត)
    - o លាងដៃ មុន និងក្រោយពីធ្វើអ្វីមួយ ដែលអាចប្រឈមមុខនឹងការឆ្លងមេរោគ
    - o ប្រើប្រាស់របាំងការពារ ដូចជា ស្រោមដៃកៅស៊ូ អាវអៀម និងម៉ាស នៅពេលប៉ះពាល់ឈាម ឬ អង្គធាតុរាវផ្សេងទៀតចេញពីសពាង្គកាយដោយផ្ទាល់
    - o ចោលកាកសំណល់ ដែលមានប្រឡាក់ឈាម និងអង្គធាតុរាវសពាង្គកាយប្រកបដោយសុវត្ថិភាព
    - o សម្លាប់មេរោគលើឧបករណ៍ និងសម្ភារៈដែលជាប់មេរោគផ្សេងទៀតឱ្យបានត្រឹមត្រូវ ( មេរោគ ងាប់នៅពេលប៉ះពាល់នឹងសារធាតុសម្រាប់លាងសម្អាត ដូចជា អូសាវ៉ែល អាល់កុល សាប៊ូ ដែលមានឋាមពលខ្លាំង និងទឹកក្តៅខ្លាំង)
    - o ទុកដាក់ក្រណាត់ស្បៃដែលប្រឡាក់ឱ្យបានត្រឹមត្រូវ

[៤] ការតមមិនរួមភេទ អាចជាវិធីដ៏មានប្រសិទ្ធភាពមួយដើម្បីបង្ការមេរោគអេដស៍ ប៉ុន្តែជារឿយៗ វិធីនេះមនុស្សពេញវ័យ ដែលកំពុងសកម្មខាង ផ្លូវភេទមិនទទួលយកឡើយ។

## ជម្ងឺកាមរោគ

ជម្ងឺកាមរោគ ដូចជា ស្វាយ ប្រមេះទឹកបាយ ប្រមេះទឹកថ្លា និងទាមទ្បា ត្រូវបានរកឃើញ នៅប្រទេសកម្ពុជា ក្នុងចំណោមក្រុមដែលងាយរងគ្រោះជាងគេ ដូចជា អ្នកបម្រើសេវាកម្សាន្តសប្បាយ និង អតិថិជនរបស់ពួកគេជាដើម ។ អ្នកមានជម្ងឺកាមរោគ មានគ្រោះថ្នាក់ទៅនឹងការឆ្លងមេរោគអេដស៍ ខ្ពស់ជាងមនុស្សដទៃ ទៀត ។

ជម្ងឺកាមរោគជាច្រើនអាចព្យាបាលជាសះស្បើយ បើយើងឆាប់ធ្វើរោគវិនិច្ឆ័យ និងព្យាបាលវា ។ អ្នក ជំនាញជឿថា អ្នកដែលមានជម្ងឺកាមរោគ កាន់តែប្រថុយប្រថានខ្ពស់ទៅនឹងការឆ្លងមេរោគអេដស៍ ។ មានទំនាក់ទំនងមួយ រវាងការឆ្លងមេរោគអេដស៍ និងជម្ងឺកាមរោគ ដោយសារតែជម្ងឺកាមរោគមួយចំនួន អនុញ្ញាតឱ្យមេរោគអេដស៍ចូលក្នុងសពាង្គកាយយ៉ាងងាយ ។ ឧទាហរណ៍ ជម្ងឺកាមរោគមួយចំនួនធ្វើឱ្យមាន ពងបែក ឬរបួសបើកមុខ ដូច្នេះ បង្កើតជាច្រកឱ្យមេរោគអេដស៍ចូលមកក្នុងសពាង្គកាយបានងាយប្រសិនបើ មនុស្សម្នាក់នេះ រួមភេទដោយគ្មានសុវត្ថិភាព ឬរួមភេទតាមមាត់ ដោយមិនប្រើស្រោមអនាម័យ ។

### របៀបបង្ការជម្ងឺកាមរោគ?

មានសកម្មភាពជាច្រើន ដែលអាចអនុវត្ត ដើម្បីកាត់បន្ថយគ្រោះថ្នាក់ នៃការឆ្លងជម្ងឺកាមរោគ ។

- មានទំនាក់ទំនងផ្លូវភេទ តែជាមួយដៃគូម្នាក់ ដែលគ្មានជម្ងឺកាមរោគ
- ប្រើប្រាស់ស្រោមអនាម័យបុរស ឬស្ត្រីឱ្យបានត្រឹមត្រូវ
- កុំប្រើគ្រឿងញៀន ជាពិសេសគ្រឿងញៀនដែលចាក់បញ្ចូលដោយម្ជុល
- បង្ការ និងទប់ស្កាត់ជម្ងឺកាមរោគដទៃទៀត ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ និង កាត់បន្ថយ គ្រោះថ្នាក់របស់អ្នក ប្រសិនបើអ្នកមានផ្ទុកមេរោគអេដស៍រួចទៅហើយ
- កាត់បន្ថយចំនួនដៃគូរួមភេទ ដែលអ្នកមានដោយសារតែ ការធ្វើបែបនេះអាចកាត់បន្ថយឱកាស ដែលអ្នកអាចឆ្លងជម្ងឺកាមរោគបាន

**អ្នកដែលសកម្មនឹងការរួមភេទគួរៈ**

- ពិនិត្យរកជម្ងឺកាមរោគជាទៀងទាត់ សូម្បីតែគ្មានរោគសញ្ញាក៏ដោយ ។
- ស្វែងយល់ពីរោគសញ្ញារបស់ជម្ងឺកាមរោគ ដែលតែងលេចចេញមក ។ សុំជំនួយពីគ្រូពេទ្យភ្លាម ប្រសិនបើមានលេចចេញរោគសញ្ញាគួរឱ្យសង្ស័យ ទោះបីជារោគសញ្ញាស្រាលក៏ដោយ ។

**អ្នកដែលធ្វើរោគវិនិច្ឆ័យឃើញថាមានជម្ងឺកាមរោគគួរៈ**

- ទទួលការព្យាបាល ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការចម្លងទៅអ្នកដទៃ ឬទៅទារក ។
- ប្រាប់ដល់គ្រប់ដៃគូរួមភេទបច្ចុប្បន្នទាំងអស់ ហើយជម្រុញឱ្យពួកគេទៅពិនិត្យរកជម្ងឺកាមរោគ ។
- ធ្វើទៅតាមការណែនាំរបស់វេជ្ជបណ្ឌិត និងលេបថ្នាំឱ្យបានពេញលេញទៅតាមវេជ្ជបញ្ជា ។ យកល្អ គួរធ្វើតេស្តតាមដានបន្ត ដើម្បីធានាឱ្យប្រាកដថា ជម្ងឺកាមរោគដែលបានឆ្លងពិតជាជាសះស្បើយ ។
- ចៀសវាងគ្រប់សកម្មភាពផ្លូវភេទទាំងអស់ ពេលកំពុងមានជម្ងឺកាមរោគ និងពេលលេបថ្នាំព្យាបាលជម្ងឺកាមរោគ ។

***ជួនកាល មនុស្សខ្លាចទទួលរងការអាម៉ាស់ ឬភ័យខ្លាចពេកមិនហ៊ានស្នើសុំជំនួយ ឬព័ត៌មានទេ ។ ជម្ងឺកាមរោគភាគច្រើនអាចព្យាបាលជា ហើយនៅពេលដែលមនុស្សម្នាក់ស្វែងរកការព្យាបាល និងប្រាប់ដល់ដៃគូរួមភេទរបស់ខ្លួនអំពីការឆ្លង ជម្ងឺនេះកាន់តែឆាប់ នោះការឆ្លងជម្ងឺនេះនឹងកាន់តែមិនសូវបង្កឱ្យមានការខូចខាតជាអចិន្ត្រៃយ៍ដល់រូបរាងកាយ ។***

**រោគសញ្ញានៃជម្ងឺកាមរោគ**

**រោគសញ្ញាទូទៅ (បុរស និងស្ត្រី)**

- ធ្លាក់ស ឬហូរខ្ទុះតាមបង្ហួរនោម ឬយោនី
- ដំបៅ ឬពងបែក នៅជុំវិញប្រដាប់បន្តពូជ អាចឈឺចាប់ ឬមិនឈឺចាប់
- ឡើងហើមកូនកណ្តុរ ឬឈឺកូនកណ្តុរត្រង់ក្រលៀន

- ឡើងកន្ទួលមិនរមាស់លើខ្លួនប្រាណ
- មានសិរមាន់លើប្រដាប់បន្តពូជ
- ឈឺចុកចាប់នៅផ្នែកខាងក្រោមនៃពោះ
- ពងបែកក្នុងមាត់ *
- មានរោគសញ្ញាដូចផ្តាសាយ - គ្រុនក្តៅ ឈឺខ្លួន ឈឺក្បាល*

* មេរោគដទៃទៀតអាចបង្កឱ្យមានរោគសញ្ញាមួយចំនួន ក្នុងចំណោមរោគសញ្ញាទាំងនេះ ដូច្នេះសំខាន់ត្រូវឱ្យវេជ្ជបណ្ឌិតធ្វើរោគវិនិច្ឆ័យ និងព្យាបាលឱ្យបានត្រឹមត្រូវ ។

### រោគសញ្ញាលើស្ត្រី

- ធ្លាក់សខុសធម្មតា ( មានពពុះ ខាប់ៗ ដូចខ្ទុះ ក្លិនស្អុយ មានលាយឈាម)
- ឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ
- ធ្លាក់ឈាមខុសធម្មតា ពីប្រដាប់បន្តពូជ
- រលាក ឬ រមាស់ជុំវិញយោនី
- ឈឺចាប់ពេលរួមភេទ

### រោគសញ្ញាលើបុរសៈ

- ហូរខ្ទុះចេញពីលិង្គ

**សម្គាល់:** ជម្ងឺកាមរោគមួយចំនួនមិនចេញរោគសញ្ញាឡើយ ជាពិសេសចំពោះស្ត្រី ។ ដូច្នេះ ស្ត្រីអាចមិនដឹងថាខ្លួនមានជម្ងឺកាមរោគ ។

## ស្រោមអនាម័យ

### អ្វីទៅជាស្រោមអនាម័យ?

មានស្រោមអនាម័យសម្រាប់បុរស និងសម្រាប់ស្ត្រី។ ស្រោមអនាម័យបុរស គឺជាជ័រទន់យឺតស្រោបលើលិង្គ។ គេយកស្រោមអនាម័យបុរសមកពាក់លើលិង្គ ពេលរួមភេទ ហើយនៅពេលប្រើបានត្រឹមត្រូវ វាបង្ការជម្ងឺកាមរោគ រួមទាំងមេរោគអេដស៍ និងការពារមិនឱ្យមានផ្ទៃពោះ ។

ស្រោមអនាម័យស្ត្រី ដូចស្រោមអនាម័យបុរសដែរ គឺជាជ័រទន់ ដែលការពារស្ត្រីកុំឱ្យប៉ះពាល់ដោយផ្ទាល់ទៅនឹងទឹកកាមរបស់បុរស។ ស្រោមអនាម័យស្ត្រីមានរង្វង់នៅចុងសងខាង។ រង្វង់នេះដាក់នៅខាងក្នុងយោនីគ្របលើមាត់ស្បូន ហើយរង្វង់ម្ខាងទៀតដែលបើកមាត់ដាក់នៅខាងក្រៅយោនី ពាក់ជាប់នឹងមាត់យោនី។

### ហេតុអ្វីបានជាស្រោមអនាម័យមានសារៈសំខាន់?

ក្នុងពេលដែលអ្នកនៅតែរីករាយជាមួយនឹងទំនាក់ទំនងផ្លូវភេទ ការប្រើប្រាស់ស្រោមអនាម័យអាចបង្ការមេរោគអេដស៍ និងជម្ងឺកាមរោគដទៃទៀតបាន។ ស្រោមអនាម័យអាចការពារមិនឱ្យមានផ្ទៃពោះដោយមិនបង្កឱ្យមានផលរំខានអ្វីឡើយ។

## ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់

ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ (VCCT) គឺជាផ្នែកមួយដ៏សំខាន់នៃគ្រប់កម្មវិធីនៅកន្លែងធ្វើការទាំងអស់។ ការបង្ការមិនអាចមានប្រសិទ្ធភាព ពេញលេញឡើយ បើពុំមានទំនាក់ទំនងជាមួយសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នោះ។

ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មានសារៈសំខាន់ព្រោះ :

- វាអាចជួយសង្គ្រោះជីវិតបាន - អ្នកដែលដឹងពីស្ថានភាពរបស់ខ្លួនអាចទទួលបានការព្យាបាលពីកម្មវិធីព្យាបាលរបស់ជាតិ នៅពេលដែលពួកគេត្រូវការ។ នៅពេលដែលមនុស្សឆាប់ដឹងពីស្ថានភាពរបស់ខ្លួនពេលដែលកំពុងឆ្លងមេរោគ ពួកគេទំនងជារស់នៅបានយូរ និងរស់នៅកាន់តែប្រសើរ ព្រោះពួកគេអាចចាប់ផ្តើមទទួលការព្យាបាល មុនពេលដែលប្រព័ន្ធភាពសាំរបស់ពួកគេចុះខ្សោយធ្ងន់ធ្ងរ។ *មេរោគអេដស៍ និងជម្ងឺអេដស៍មិនមែនជាការកាត់ទោសប្រហារជីវិតឡើយ ប៉ុន្តែសំខាន់ត្រូវឆាប់ធ្វើតេស្ត ដើម្បីបន្តមានសុខភាពល្អ។*
- វាអាចការពារអ្នកដទៃ - នៅពេលដែលមនុស្សដឹងពីស្ថានភាពរបស់ខ្លួន ពួកគេនឹងមិនទំនងជាចម្លងមេរោគទៅកាន់អ្នកដទៃឡើយ។

- វាអាចបង្កើតសន្តិភាពក្នុងចិត្ត ព្រោះមានសេវាគាំទ្រជាច្រើន ដើម្បីធានាយ៉ាងណាឱ្យមានការឆ្លើយតបចំពោះតម្រូវការផ្នែកចិត្តសង្គម និងតម្រូវការវេជ្ជសាស្ត្រ ។

- វាអាចជួយអ្នកដែលមិនឆ្លងឱ្យរក្សាឥរិយាបថ ដែលធ្វើឱ្យពួកគេកាន់តែមានសុវត្ថិភាព ជាមួយនឹងការផ្តល់ប្រឹក្សា ដែលលើកទឹកចិត្តឱ្យពួកគេចៀសវាងឥរិយាបថដែល ប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ។

ការធ្វើតេស្ត ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត រក្សាការសម្ងាត់ និងផ្សារភ្ជាប់ជាមួយនឹងសេវាផ្តល់ប្រឹក្សាៈ

១. ការរក្សាការសម្ងាត់ - មនុស្សដែលរស់នៅជាមួយមេរោគអេដស៍មានសិទ្ធិសម្រេចចិត្តថា គួរឱ្យអ្នកណាដឹងពីស្ថានភាពរបស់ពួកគេ ។ ដោយសារតែជារឿយៗ គេមិនអាចរក្សាការសម្ងាត់បាននៅកន្លែងធ្វើការ យកល្អគួរបញ្ជូនកម្មករនិយោជិតទៅរកសេវាធ្វើតេស្តក្នុងសហគមន៍ ។

២. ស្ម័គ្រចិត្ត - មនុស្សមានសិទ្ធិជាមូលដ្ឋាន ដើម្បីធ្វើការសម្រេចចិត្តពីពេលវេលា និងថាតើពួកគេចង់ធ្វើតេស្តឬអត់ ។ កម្មវិធីបង្ការគួរគូសបញ្ជាក់ពីអត្ថប្រយោជន៍នៃការធ្វើតេស្ត សម្រាប់រក្សាសុខភាព និង ផលិតភាព ដើម្បីឱ្យមនុស្សចង់ធ្វើតេស្តដោយខ្លួនឯង ។

៣. ការផ្តល់ប្រឹក្សា - ដោយសារការភ័យខ្លាចខ្ពស់ ការយល់ច្រឡំ និងកង្វះការយល់ដឹងអំពីសេវាព្យាបាល និងគាំទ្រដែលមាន ការធ្វើតេស្តរកមេរោគអេដស៍ត្រូវអមជាមួយការផ្តល់ប្រឹក្សា ដើម្បីធានាយ៉ាងណាឱ្យមនុស្សដឹងពីរបៀបទទួលសេវា នៅពេលដែលពួកគេត្រូវការសេវាទាំងនោះ ។

## ការព្យាបាល និងការថែទាំ

មានការផ្តល់សេវាព្យាបាល ហើយសេវានេះមានប្រសិទ្ធភាព ។ នៅក្នុងប្រទេសកម្ពុជា មានសេវាព្យាបាលថ្នាក់ជាតិ ដែលផ្តល់ឱសថប្រឆាំងមេរោគអេដស៍ សម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។ នៅពេលដែលមនុស្សប្រកាន់ខ្ជាប់ទៅតាមកម្មវិធីព្យាបាលសម្រាប់ពួកគេ ពួកគេនឹងរស់នៅបានយូរ និងមានជីវិតដែលមានប្រយោជន៍ដូចមនុស្សដទៃទៀតដែរ ។

ប្រសិនបើមានអ្នកណាម្នាក់ទៅទទួលសេវាផ្តល់ប្រឹក្សា ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ពេលនោះគេគួរបញ្ជូនគាត់ ទៅកាន់សេវាគាំទ្រក្នុងសហគមន៍ និងសេវាព្យាបាលភ្លាមផងដែរ ។ នៅក្នុងដំណាក់កាលដំបូងនៃការឆ្លងមេរោគអេដស៍ មនុស្សអាចមិនត្រូវការការព្យាបាល ប៉ុន្តែ

គួរពិនិត្យតាមដានស្ថានភាពរបស់ពួកគេជាទៀងទាត់ដោយមានការថែទាំពីគ្រូពេទ្យ។ សម្រាប់ដំណាក់កាលក្រោយៗនៃការឆ្លងមេរោគ មនុស្សចាំបាច់ត្រូវចាប់ផ្តើមលេបថ្នាំ ដែលគេហៅថា ARV ឬឱសថប្រឆាំងមេរោគអេដស៍ដែលមានសកម្មភាពខ្លាំង។ ឱសថទាំងនេះត្រូវលេបជារៀងរាល់ថ្ងៃ ហើយត្រូវមានការតាមដានផលប៉ះពាល់របស់ឱសថនេះ ក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងរបស់គ្រូពេទ្យ។ ពេលដែលមានផលរំខានមួយចំនួន ជាទូទៅមនុស្សមិនមានបញ្ហាអ្វីឡើយ នៅពេលលេបថ្នាំ ARV ហើយអាចបន្តធ្វើការងារ និងរស់នៅក្នុងសង្គមគ្រួសារធម្មតាបាន។

បន្ថែមពីលើការត្រួតពិនិត្យវេជ្ជសាស្ត្រ និងការព្យាបាល ជារឿយៗមនុស្សត្រូវការការគាំទ្រផ្នែកចិត្តសង្គម ជាពិសេសភ្លាមៗក្រោយពេលធ្វើរោគវិនិច្ឆ័យរួច ឬនៅក្នុងរយៈពេលពេលទើបលេបថ្នាំប្រឆាំងមេរោគអេដស៍។ បន្ទាប់ពីការធ្វើរោគវិនិច្ឆ័យរួច ជារឿយៗ មនុស្សតែងជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន ដូចជាត្រូវជំនះការភ័យខ្លាច ការអៀនខ្មាស់ និងការយល់ខុសដោយខ្លួនឯង ដែលថាមេរោគនេះគឺជា "ការកាត់ទោសប្រហារជីវិត" ដែលគេចាត់ទុកថាកើតឡើងដោយសារទង្វើអសីលធម៌ ត្រូវប្រាប់ និងអប់រំដល់គ្រួសារ និងអ្នកជាទីស្រឡាញ់ អំពីមេរោគនេះ និងត្រូវរៀនសូត្រពីការពិនិត្យតាមដាន និងការព្យាបាលមេរោគនេះ ដែលពេលដំបូងហាក់បីដូចជា ធ្វើឱ្យមានការភ័ន្តច្រឡំខ្លាំង។ នៅពេលដែលមនុស្សចាប់ផ្តើមការព្យាបាល ពួកគេក៏ប្រហែលជាត្រូវការការគាំទ្របន្ថែមទៀត ដើម្បីដឹងពីយុទ្ធសាស្ត្រ សម្រាប់ប្រកាន់ខ្ជាប់ទៅតាមកម្មវិធីព្យាបាល និង ទប់ទល់នឹងផលរំខានដែលអាចកើតឡើង។

ជារឿយៗ អ្នកដែលរស់នៅជាមួយមេរោគអេដស៍ដទៃទៀតអាចជាមនុស្សល្អបំផុត សម្រាប់ផ្តល់ការគាំទ្រសង្គម។ ពួកគេអាចចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនជាក់ស្តែង ដើម្បីជួយអ្នកដែលត្រូវការការគាំទ្រ ឱ្យពួកគេយល់ថា ពួកគេអាចបន្តធ្វើការងារ និងរក្សាសុខភាព និងសុខុមាលភាពឱ្យបានល្អ នៅពេលដែលខ្លួនកំពុងមានមេរោគនេះ។

ផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងសេវាព្យាបាលជម្ងឺកាមរោគអាច ទទួលបាននៅតាមគ្លីនិករដ្ឋភាគច្រើន (ដែលមានសញ្ញាបូរពណ៌ក្រហម សំរាប់ការធ្វើតេស្ត) ដូចជា:

- គ្លីនិកជាតិកាមរោគ និងសើស្បែក អគារលេខ ២៥៥H ផ្លូវជាតិលេខ៦A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ។
- មន្ទីរពេទ្យគាំពារមាតា និងទារក អគារលេខ ៨៦ ផ្លូវលេខ ៤៧ ក្រុងភ្នំពេញ

- គ្រប់មន្ទីរពេទ្យបង្អែកថ្នាក់ខេត្ត និងស្រុកប្រតិបត្តិទាំងអស់

→ ***សូមមើលក្នុងឧបសម្ព័ន្ធទី ៥ អំពីបញ្ជីអ្នកផ្តល់សេវាប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងអ្នកផ្តល់សេវាព្យាបាលជម្ងឺកាមរោគ និង ព័ត៌មានតាមមូលដ្ឋាន***

ធនធានបន្ថែមអំពីមេរោគអេដស៍ និងជម្ងឺអេដស៍អាចយកចេញពី ***"ការណែនាំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍សម្រាប់បុគ្គលិកសហប្រជាជាតិនៅប្រទេសកម្ពុជា"*** ដែលមានចែកជាមួយនឹងគោលការណ៍ណែនាំនេះ ។

## ការរាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃ

### ការរាយការណ៍

កត់ត្រាចំណុចដែលគណៈកម្មការអេដស៍លើកយកមកពិភាក្សា ចងក្រងទុកជាឯកសារនូវគ្រប់សកម្មភាពទាំងអស់ពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ និង ចែករំលែកព័ត៌មាននេះដល់គ្រប់សមាជិក សមាជិកា ដៃគូ និងអ្នកដែលពាក់ព័ន្ធទាំងអស់ទៅតាមការចាំបាច់។ ផ្តល់របាយការណ៍សង្ខេបប្រចាំត្រីមាសដល់នាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកបញ្ជាទិញ និងអ្នកដែលមានការពាក់ព័ន្ធដទៃទៀតទៅតាមការស្នើសុំ។

### ការពិនិត្យតាមដាន និងការវាយតម្លៃ

កំណត់ពីរបៀបពិនិត្យតាមដានទៅលើមុខងាររបស់គណៈកម្មការអេដស៍ ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ និងការអនុវត្តគោលនយោបាយនេះ នឹងកំណត់នូវសូចនាករដែលត្រូវប្រើប្រាស់ដើម្បីវាស់វែងលទ្ធផលសម្រេចបាន។ គួរបង្កើតទម្រង់សម្រាប់ពិនិត្យតាមដានសាមញ្ញមួយដោយមានសូចនាករជាក់លាក់។

ខាងក្រោមនេះគឺជាទម្រង់ពិនិត្យតាមដាននៅកន្លែងធ្វើការ ដែលអាចយកមកកែសម្រួលប្រើប្រាស់នៅតាមសហគ្រាស គ្រឹះស្ថានបាន។

### ឧទាហរណ៍នៃទម្រង់ពិនិត្យតាមដាននៅកន្លែងធ្វើការ

[ឈ្មោះសហគ្រាស គ្រឹះស្ថាន]

ទម្រង់ពិនិត្យតាមដានសកម្មភាពពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

កាលបរិច្ឆេទ ............................

រាយការណ៍ដោយ (ឈ្មោះជនបង្គោល)៖ ..........................................................................

ទម្រង់នេះគួរបំពេញរៀងរាល់ត្រីមាស ដោយអ្នកទទួលខុសត្រូវដែលបានចាត់តាំង នៅក្នុងរោងចក្រ

| សូចនាករ | កាលបរិច្ឆេទបញ្ចប់ | កំណត់សំគាល់ |
|---|---|---|
| **១. ការអប់រំ និងការផ្ដល់ព័ត៌មានអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ** | | |
| គ្រូបណ្ដុះបណ្ដាលអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ *(ចំនួនគ្រូបណ្ដុះបណ្ដាល)* | | |
| មិត្តអប់រំមិត្តអំពីមេរោគអេដស៍  និងជម្ងឺអេដស៍ *(ចំនួនមិត្តអប់រំមិត្ត)* | | |
| សកម្មភាពអប់រំអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ *(ចំនួនវគ្គបណ្ដុះបណ្ដាល ឬវគ្គអប់រំ)* | | |
| ស្រោមអនាម័យដែលមាន *(ចំនួនស្រោមអនាម័យដែលបានចែកទៅឱ្យកម្មករនិយោជិតនៅក្នុងត្រីមាសមុន)* | | |
| សម្ភារៈព័ត៌មាន អប់រំ និងផ្សព្វផ្សាយ (IEC) ដែលបានចែកទៅឱ្យកម្មករនិយោជិត *(ចំនួនសម្ភារៈ IEC ដែលបានចែក)* | | |
| សេវាព័ត៌មានអំពីជម្ងឺកាមរោគ *(ចំនួនមនុស្សដែលស្នើសុំព័ត៌មាន)* | | |
| សេវាព័ត៌មានអំពីការផ្ដល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ *(ចំនួនមនុស្សដែលស្នើសុំព័ត៌មាន)* | | |
| សេវាព័ត៌មានអំពីការថែទាំ និងការគាំទ្រ *(ចំនួនមនុស្សដែលស្នើសុំព័ត៌មាន)* | | |
| តើប្រធានបទអំពីមេរោគអេដស៍ និងជម្ងឺអេដស៍ត្រូវបានដាក់បញ្ចូលទៅក្នុងការបណ្ដុះបណ្ដាលអំពីសុខភាព | | |

| | | |
|---|---|---|
| និងសុវត្ថិភាពការងារ ឬធនធានមនុស្សដែលមានស្រាប់ដែរឬទេ? | | |
| **២. គណៈកម្មការ និងជនបង្គោលអេដស៍** | | |
| មានគណៈកម្មការអេដស៍ដោយឡែក | | |
| មេរោគអេដស៍ និងជម្ងឺអេដស៍ត្រូវបានដាក់បញ្ចូល ទៅក្នុងកម្មវិធីសុខភាព និងសុវត្ថិភាពការងារ | | |
| បញ្ហាមេរោគអេដស៍ និងជម្ងឺអេដស៍ត្រូវបានដាក់បញ្ចូលទៅក្នុងគណៈកម្មការ ឬ កម្មវិធីដទៃទៀត *(សូមបញ្ជាក់)* | | |
| ចាត់តាំងឱ្យមានជនបង្គោលអេដស៍ម្នាក់ *(សូមប្រាប់ឈ្មោះ)* | | |
| សហគ្រាសមានថវិកាដាក់លាក់ សម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងមេរោគអេដស៍ និងជម្ងឺអេដស៍ | | |
| ចំនួនកិច្ចប្រជុំរបស់គណៈកម្មការអេដស៍ក្នុងមួយឆ្នាំ *(ចំនួនកិច្ចប្រជុំ ដែលបានរៀបចំឡើង)* | | |
| **៣. គោលនយោបាយស្តីពី មេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ** | | |
| មានគោលនយោបាយស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ជាលាយលក្ខណ៍អក្សរ | | |
| គោលនយោបាយស្តីពី មេរោគអេដស៍ និងជម្ងឺអេដស៍នោះមានដាក់បញ្ចូល:<br>- ការមិនរើសអើង<br>- មិនមានការតម្រូវឱ្យធ្វើតេស្ត<br>- ការទទួលបានការអប់រំ | | |

## ឯកសារយោង


- The ILO's *Know More About HIV and AIDS: Toolkit for the Informal Economy*;
- The ILO Code of Practice on HIV/AIDS and the World of Work;
- The Factory Improvement Program (FIB) module on HIV/AIDS;
- Training of Trainer (ToT) manual on HIV/AIDS in the ILO/USDOL HIV/AIDS Workplace Program;
- Developing a policy on HIV and AIDS for your workplace. A toolkit for employers and workers in Papua New Guinea (PNG)
- United Nations Cambodia: *PRIMER ON HIV-AIDS FOR UN STAFF Cambodia, 2010*

## ឧបសម្ព័ន្ធ

១. គោលការណ៍សំខាន់៧នៃគោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ របស់អង្គការពលកម្មអន្តរជាតិ

២. ប្រកាស (លេខ ០៨៦) ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

៣. មាត្រាពាក់ព័ន្ធមួយចំនួននៃ ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាល មេរោគអេដស៍ និងជម្ងឺអេដស៍

៤. គោលនយោបាយទូទៅស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

៥. បញ្ជីអ្នកផ្តល់សេវាប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងអ្នកផ្តល់សេវាព្យាបាលជម្ងឺកាមរោគ និង ព័ត៌មានតាមមូលដ្ឋាន

## ឧបសម្ព័ន្ធទី ១៖ គោលការណ៍សំខាន់ៗ នៃគោលការណ៍អនុវត្តស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍និងពិភពការងារ របស់អង្គការពលកម្មអន្តរជាតិ

- **ការទទួលស្គាល់ថាមេរោគអេដស៍ និងជម្ងឺអេដស៍ គឺជាបញ្ហានៅកន្លែងធ្វើការ៖** មេរោគអេដស៍ និងជម្ងឺអេដស៍ គឺជាបញ្ហានៅកន្លែងធ្វើការ ហើយគួរត្រូវបានគេចាត់ទុកដូចជម្ងឺ និងស្ថានភាពធ្ងន់ធ្ងរដទៃទៀតនៅកន្លែងធ្វើការដែរ ។

- **ការមិនរើសអើង៖** នៅក្នុងស្មារតីការងារសមរម្យ និងការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់អ្នករស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ មិនគួរមានការរើសអើងចំពោះកម្មករនិយោជិត ដោយដឹងពីស្ថានភាពមេរោគអេដស៍ជាក់ស្តែង ឬ គ្រាន់តែគិតថានរណាម្នាក់មានផ្ទុកមេរោគអេដស៍នោះទេ ។

- **សមភាពយេនឌ័រ៖** គួរមានការទទួលស្គាល់ទិដ្ឋភាពយេនឌ័ររបស់មេរោគអេដស៍ និងជម្ងឺអេដស៍ ។ ដោយសារតែមូលហេតុជីវសាស្ត្រ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ស្ត្រីទំនងជាមានឱកាសឆ្លង និងរងផលប៉ះពាល់ដោយសារការរាលដាលនៃមេរោគនេះជាងបុរស ។

- **បរិយាកាសការងារប្រកបដោយសុខភាពល្អ៖** បរិយាកាសការងារគួរធ្វើឱ្យភាគីដែលពាក់ព័ន្ធទាំងអស់ មានសុខភាពល្អ និងមានសុវត្ថិភាព ដើម្បីបង្ការការចម្លងមេរោគអេដស៍ ។

- **ការចចារសង្គម (ការប្រាស្រ័យទាក់ទងនៅកន្លែងធ្វើការ)៖** ជោគជ័យនៃការអនុវត្តកម្មវិធីមេរោគអេដស៍ និងជម្ងឺអេដស៍ តម្រូវឱ្យមានការសហការ និងការជឿទុកចិត្តគ្នារវាងនិយោជក កម្មករនិយោជិត តំណាងរបស់ពួកគេ និងរដ្ឋាភិបាល ។ កិច្ចសន្ទនាសង្គមក៏គួរមានការចូលរួមពីកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជម្ងឺអេដស៍ផងដែរ ។

- **ពុំមានការធ្វើតេស្តឈាមក្នុងគោលបំណងបដិសេធពីការងារ ឬក្នុងដំណើរការជ្រើសរើសចូលធ្វើការ៖** មិនតំរូវឱ្យមានការពិនិត្យឈាមរកមេរោគអេដស៍ សម្រាប់បេក្ខជនដាក់ពាក្យសុំធ្វើការងារ ឬបុគ្គលិកដែលកំពុងបម្រើការងាររួចទៅហើយនោះទេ ។

- **ការរក្សាការសម្ងាត់៖** ពុំមានហេតុផលណាមួយ សម្រាប់ឱ្យបេក្ខជនដាក់ពាក្យសុំធ្វើការងារ ឬកម្មករនិយោជិតបង្ហាញពីព័ត៌មានផ្ទាល់ខ្លួន ដែលពាក់ព័ន្ធនឹងមេរោគអេដស៍របស់ពួកគេឡើយ ។ កម្មករនិយោជិតក៏មិនគួរមានកាតព្វកិច្ចបង្ហាញព័ត៌មានផ្ទាល់ខ្លួនបែបនេះអំពីមិត្តរួមការងាររបស់ពួកគេឡើយ ។

- **ការបន្តរក្សាទំនាក់ទំនងក្នុងការបំរើការងារ:** ការផ្ទុកមេរោគអេដស៍មិនមែនជាមូលហេតុ សម្រាប់ការបញ្ឈប់ពីការងារឡើយ។ ដូចគ្នាជាមួយលក្ខខណ្ឌជាច្រើនផ្សេងទៀតដែរ អ្នកដែលមានជម្ងឺពាក់ព័ន្ធជាមួយមេរោគអេដស៍ គួរតែអាចបន្តធ្វើការងារដែលមាន សមស្របទៅតាមស្ថានភាពសុខភាពជាក់ស្តែងរបស់ពួកគេ។

- **ការបង្ការ:** យើងអាចបង្ការការឆ្លងមេរោគអេដស៍បាន។ ការបង្ការគ្រប់បែបផែននៃការចម្លងទាំងអស់ អាចធ្វើទៅបានតាមរយៈយុទ្ធសាស្ត្រផ្សេងៗជាច្រើន ដែលផ្តោតគោលដៅសមស្រប ទៅតាមស្ថានភាព និង វប្បធម៌ក្នុងប្រទេសនីមួយៗ។

- **ការថែទាំ និងការគាំទ្រ:** សាមគ្គីភាព ការថែទាំ និងការគាំទ្រគួរជាមគ្គុទេសក៍ណែនាំដល់ការឆ្លើយតបចំពោះមេរោគអេដស៍ និងជម្ងឺអេដស៍ នៅក្នុងពិភពការងារ។ គ្រប់កម្មករនិយោជិតទាំងអស់ រួមទាំងអ្នកដែលផ្ទុកមេរោគអេដស៍ផងមានសិទ្ធិទទួលបានសេវាសុខភាពដែលមានតម្លៃសមស្រប។ មិនគួរមានការរើសអើងចំពោះពួកគេ និងអ្នករស់នៅក្នុងបន្ទុករបស់គេក្នុងការប្រើប្រាស់ និងការទទួលបានអត្ថប្រយោជន៍ពីកម្មវិធីសន្តិសុខ សង្គម និង ផែនការឧបត្ថម្ភទាក់ទងនឹងការងារផ្សេងៗដែលតម្រូវដោយច្បាប់ឡើយ។

**ឧបសម្ព័ន្ធទី ២៖** ប្រកាស (លេខ០៨៦) ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍ នៅកន្លែងធ្វើការ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ **០៨៦** ក.ក.ប.វ/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៦

**ប្រកាស**

**ស្តីពី**

**ការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន**

**និងការបង្ការទប់ស្កាត់ មេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការ**

## រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ៥២អនក្រ/បក/ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**សម្រេច**

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណង បំផុស លើកកំពស់ស្មារតី និងជម្រុញដល់ការអប់រំ និងជួយកម្មករនិយោជិត អំពីការបង្ការ និងការទប់ស្កាត់ ការឆ្លងរីករាលដាល មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ ។

1

**ប្រការ ២.-**

សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើ កម្មករនិយោជិត ចាប់ពី៨នាក់ឡើងទៅ ត្រូវរៀបចំបង្កើតក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍សំរាប់ សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

**ប្រការ ៣.-**

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតពី ៨នាក់ដល់៥០នាក់ និយោជក និង សហជីព មូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតក្រុមការងារអេដស៍សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួនដែលមាន តំណាងនិយោជកចំនួនមួយរូបយ៉ាងតិច និងតំណាងសហជីពមូលដ្ឋានចំនួនមួយរូបយ៉ាងតិច ចូលរួមក្នុងក្រុម ការងារ តំណាងនិយោជកត្រូវទទួលភារកិច្ចជាប្រធានក្រុមការងារ ។

ចំពោះសហគ្រាសគ្រឹះស្ថានដែលមានកម្មករនិយោជិតចាប់ពី ៥១នាក់ឡើងទៅ និយោជក និងសហជីពមូលដ្ឋាន ត្រូវពិគ្រោះគ្នាអំពីការបង្កើតគណៈកម្មការអេដស៍ សំរាប់សហគ្រាស គ្រឹះស្ថាន របស់ខ្លួន ។

គណៈកម្មការនេះ ត្រូវមានតំណាងនិយោជកយ៉ាងតិចចំនួនពីររូប តំណាងសហជីពមូលដ្ឋានចំនួនយ៉ាងតិចពីររូប និងអ្នកទទួលខុសត្រូវគិលានដ្ឋានមួយរូប ចូលរួមជាសមាជិក ។ ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានសហជីព មូលដ្ឋានច្រើន សហជីពនីមួយៗអាចបញ្ជូនតំណាងរបស់ខ្លួនមួយរូប ឱ្យចូលរួមជាសមាជិកគណៈកម្មការ ។

**ប្រការ ៤.-**

គណៈកម្មការអេដស៍ដូចមានចែងក្នុង ប្រការ៣ កថាខ័ណ្ឌទី២ ខាងលើ ត្រូវពិគ្រោះគ្នាអំពីការតែងតាំងប្រធាន ១ រូបរបស់គណៈកម្មការ ។ តំណាងមកពីភាគីនិយោជកគួរតែទទួលបន្ទុកធ្វើជាប្រធានគណៈកម្មការ ។ បើពុំមាន ការឯកភាពគ្នាទេ ការតែងតាំងប្រធានគណៈកម្មការត្រូវប្រព្រឹត្តទៅតាម វិធីចាប់ឆ្នោតដោយសមាជិកទាំង អស់អាចឈរឈ្មោះជាប្រធានគណៈកម្មការតាមការស្ម័គ្រចិត្ត ហើយសរសេរឈ្មោះខ្លួនឯងលើសន្លឹកឆ្នោតម្នាក់ ១សន្លឹករួចយកទៅដាក់ក្នុងហិបឆ្នោតមួយ ។ សមាជិក ដែលមាន អាយុច្រើនជាងគេចាប់យកសន្លឹកឆ្នោត១ សន្លឹកពីក្នុងហិបឆ្នោត រួចប្រកាសឈ្មោះនោះជា ប្រធានគណៈកម្មការ ចាប់ពីពេលនោះតទៅ ។ករណីមានបេក្ខ ជនតែមួយរូបឈរឈ្មោះ បេក្ខជននោះត្រូវតែបានទទួលស្គាល់ថាជា ប្រធានគណៈកម្មការដោយស្វ័យប្រវត្តិ ។ ប្រធានគណៈកម្មការមានអាណត្តិ ២ឆ្នាំ ។ ក្នុងអំឡុងពេល ៣០ថ្ងៃមុនចប់អាណត្តិគណៈកម្មការត្រូវប្រជុំពិគ្រោះ គ្នា អំពីការតែងតាំងប្រធានសំរាប់អាណត្តិថ្មី តាមនីតិវិធីដូចមានចែងក្នុងប្រការនេះស្រាប់ ។

ដោយហេតុផលសមស្របណាមួយ ដែលពុំទាន់អាចធ្វើការតែងតាំងប្រធានសំរាប់អាណត្តិថ្មីបាន ប្រធាននៃអា ណត្តិចាស់ត្រូវបន្តការងាររបស់ខ្លួនរហូតដល់តែងតាំងបានប្រធានថ្មីមកជំនួស ។ HS

ក្នុងករណីដែលប្រធានគណៈកម្មការអវត្តមាន មិនអាចបំពេញតួនាទីជាប្រធានបាន សមាជិកដែលមានអាយុច្រើនជាងគេត្រូវទទួលភារកិច្ចជាប្រធានស្តីទី ។

ក្នុងករណីមានសមាជិកឈប់ ឬលាលែង ពីតំណែងនៃសមាជិកគណៈកម្មការ ប្រធានត្រូវស្នើសុំទៅ និយោជក ឬ សហជីពមូលដ្ឋាន ឱ្យបញ្ជូនឈ្មោះសមាជិកថ្មីមកបំពេញអាសនៈដែលទំនេរ ។

**ប្រការ ៥.-**

ក្រោយពេលបង្កើតក្រុមការងារ ឬគណៈកម្មការអេដស៍ ដូចមានចែងក្នុង ប្រការ៣ និង ប្រការ៤ ខាងលើបានហើយ ប្រធានក្រុមការងារ ឬប្រធានគណៈកម្មការ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងអំឡុងពេល ១៥ថ្ងៃយ៉ាងយូរ ដោយមានភ្ជាប់ទៅជាមួយ នូវបញ្ជីរាយនាមក្រុមការងារ ឬបញ្ជីរាយនាមគណៈកម្មការ តាមតារាងគំរូជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៦.-**

ចំពោះសហគ្រាស គ្រឹះស្ថាន ដែលពុំទាន់មានសហជីព ពាក្យថា "សហជីពមូលដ្ឋាន" ដូចមានចែងក្នុងប្រការ៣ ខាងលើ ត្រូវជំនួសដោយប្រតិភូបុគ្គលិក ឬតំណាងកម្មករនិយោជិត តាមការស្ម័គ្រចិត្ត ។

**ប្រការ ៧.-**

ក្រុមការងារអេដស៍ និងគណៈកម្មការអេដស៍ ដូចមានចែងក្នុងប្រការ៣ មានតួនាទីភារកិច្ចដូចតទៅ:

**ក.** ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់របស់ខ្លួន ឱ្យបានយល់ជ្រួតជ្រាបអំពីការបង្កើតក្រុមការងារ ឬគណៈកម្មការនេះ និងសមាសភាពរបស់ក្រុមការងារ ឬគណៈកម្មការ ។

**ខ.** ប្រជុំគ្នាតាមពេលវេលាដែលអាចធ្វើបាន ដើម្បីពិគ្រោះពិភាក្សារៀបចំកម្មវិធី សំរាប់អប់រំកម្មករនិយោជិត នៅកន្លែងការងារអំពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។

**គ.** លើកសំណើទៅនាយកដ្ឋានពេទ្យការងារ សុំជំនួយបច្ចេកទេស ឯកសារ ឬវិធីសាស្ត្រផ្សេងៗ សំរាប់អប់រំ និងជួយកម្មករនិយោជិតឱ្យយល់ជ្រួតជ្រាបអំពីការបង្ការនិងទប់ស្កាត់ ការឆ្លងរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ នៅកន្លែងធ្វើការ ។

**ឃ.** យកចិត្តទុកដាក់អប់រំឱ្យបានយល់ជ្រួតជ្រាបមុនគេចំពោះថ្នាក់ដឹកនាំសហជីព ប្រតិភូបុគ្គលិក មេការ ប្រធានផ្នែក ប្រធានក្រុម ប្រធានពួក ហើយបង្កឱកាសដល់អ្នកទាំងនោះធ្វើការអប់រំបន្តដល់កម្មករនិយោជិតជាទូទៅ តាមពេលវេលា និងលទ្ធភាពជាក់ស្តែង ប្រកបដោយភាពយោគយល់គ្នា រវាងនិយោជក និងតំណាងកម្មករនិយោជិត ។ HS

**ង.** អប់រំកម្មករនិយោជិតទាំងអស់ អំពីយុទ្ធសាស្ត្រនៃការកាត់បន្ថយគ្រោះថ្នាក់ ដោយផ្តល់នូវពត៌មានដែលទាក់ទាញការចាប់អារម្មណ៍ហើយច្បាស់លាស់ និងសមស្របទៅនឹងកាលវេលា ។ ក្នុងករណីចាំបាច់ ត្រូវធ្វើយ៉ាងណាឱ្យបុរសនិងស្ត្រី ងាយរកបាននូវស្រោមអនាម័យនៅពេលត្រូវការប្រើប្រាស់ ។

**ច.** ជួយដល់កម្មករនិយោជិត ដែលមានផ្ទុកមេរោគអេដស៍ ឬមានកើតជំងឺអេដស៍ ឱ្យទទួលបាននូវសេវាសុខាភិបាលសំរាប់ការព្យាបាល និងការបង្ការការឆ្លងអេដស៍ និងជួយលើកទឹកចិត្តដល់អ្នកទាំងនោះ ឱ្យមានសេចក្តីសង្ឃឹមក្នុងជីវិត បន្តការងារក្នុងស្ថានភាពធម្មតានិងជាប្រក្រតី ។

**ឆ.** លើកសំណើទៅនិយោជក ទៅក្រសួងស្ថាប័នមានសមត្ថកិច្ច ឬទៅអង្គការនានា ឱ្យជួយដោះស្រាយបញ្ហាដែលគណៈកម្មការមិនអាចដោះស្រាយបាន សំដៅជួយដល់កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ ឬមានជំងឺអេដស៍ តាមការជាក់ស្តែងនៃបញ្ហានីមួយៗ ។

**ប្រការ ៨.-**

ប្រធានគណៈកម្មការអេដស៍ដូចមានចែងក្នុង ប្រការ៤ មានតួនាទីភារកិច្ចដូចតទៅ:

**ក.** ដឹកនាំការប្រជុំលើកដំបូង ដើម្បីរៀបចំកម្មវិធីការងាររបស់គណៈកម្មការ តាមពេលវេលានិងទីកន្លែង ដោយភាពយោគយល់គ្នារវាងនិយោជក និងតំណាងកម្មករនិយោជិត ។

**ខ.** ចាត់ចែងឱ្យមានសកម្មភាពជាក់ស្តែង ត្រឹមត្រូវតាមកម្មវិធីការងាររបស់ខ្លួន ឬតាមការណែនាំពីនាយកដ្ឋានពេទ្យការងារ ឬពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**គ.** ទទួលសំណូមពរផ្សេងៗពីសមាជិក ឬពីកម្មករនិយោជិត រួចលៃលកពេលវេលាសមស្របដើម្បីប្រជុំគ្នា ពិគ្រោះដោះស្រាយសំណូមពរទាំងនោះ ។ ក្នុងករណីចាំបាច់ ត្រូវលើកសំណូមពរនោះជូននិយោជក ជូននាយកដ្ឋានពេទ្យការងារ ឬជូនក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬអង្គការនានាសុំជួយដោះស្រាយ ។

**ឃ.** ត្រូវលៃលកពេលវេលាសមស្រប ធ្វើការប្រជុំគណៈកម្មការមួយខែម្តង ឬយ៉ាងយូរមួយត្រីមាសម្តង ដើម្បីត្រួតពិនិត្យការងាររបស់ខ្លួន និងដាក់ចេញនូវវិធានការកែលំអការខ្វះខាតក្នុងករណីចាំបាច់ ដើម្បីជំរុញការងាររបស់គណៈកម្មការមានដំណើរការល្អ ។

**ប្រការ ៩.-**

កម្មករនិយោជិត ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមការណែនាំ និងការអប់រំផ្សព្វផ្សាយ របស់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ ឬរបស់នាយកដ្ឋានពេទ្យការងារ ឬរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច សំដៅបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកន្លែងធ្វើការ ។ HS

**ប្រការ ១០.-**

កម្មករនិយោជិត អាចលើកសំណើ ឬសំណូមពរផ្សេងៗ តាមការជាក់ស្តែង ដែលពាក់ព័ន្ធនឹងមេរោគអេដស៍ ឬជំងឺអេដស៍នៅកន្លែងធ្វើការ តាមរយៈប្រតិភូបុគ្គលិក ឬសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថាន របស់ខ្លួន ទៅក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ ដូចមានចែងក្នុង ប្រការ៣ ឱ្យជួយដោះស្រាយ ។

កម្មករនិយោជិត អាចលើកសំណើ ឬសំណូមពរទាំងនោះ ត្រង់ទៅក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ នៃសហគ្រាស គ្រឹះស្ថានរបស់ខ្លួនដើម្បីសុំការជួយដោះស្រាយ ។

**ប្រការ ១១.-**

និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង ប្រការ៣ ខាងលើត្រូវផ្តល់ឱកាសនិងបង្កភាពងាយស្រួល ដល់ក្រុមការងារអេដស៍ ឬគណៈកម្មការអេដស៍ នៃសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ឱ្យបំពេញតួនាទីភារកិច្ច ដូចមានចែងក្នុង ប្រការ៧ ឱ្យបានទទួលជោគជ័យ ។

ហាមដាច់ខាត រាល់ការរើសអើងរបស់និយោជក ចំពោះកម្មករនិយោជិត ទាំងបុរស ទាំងស្ត្រី ដែលមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ឡើយ ជាអាទិ៍ ការបញ្ឈប់ពីការងារ ការមិនផ្តល់ការងារឱ្យបានគ្រប់គ្រាន់ ការមិនផ្តល់ប្រាក់ឈ្នួលឱ្យដូចកម្មករនិយោជិតដទៃ ការមិនតម្លើងឋានៈនាទី ការមិនផ្តល់ប្រាក់រង្វាន់ផ្សេងៗ ដោយសារតែសាមីខ្លួនមានផ្ទុកមេរោគអេដស៍ ឬជំងឺអេដស៍ ។

**ប្រការ ១២.-**

គោលការណ៍គន្លឹះសំខាន់ៗ មានដូចតទៅ:

**ក. ការទទួលស្គាល់ថាមេរោគអេដស៍/ជំងឺអេដស៍ជាបញ្ហានៅកន្លែងធ្វើការ**

បញ្ហាមេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការ គួរតែទទួលបាននូវការដោះស្រាយដូចជម្ងឺធ្ងន់ធ្ងរ ឬលក្ខខណ្ឌដទៃទៀត នៅកន្លែងធ្វើការ ។ នេះជាការចាំបាច់មួយ ដែលមិនមែនគ្រាន់តែដោយសារការប៉ះពាល់កម្លាំងពលកម្មប៉ុណ្ណោះទេ ប៉ុន្តែកន្លែងធ្វើការជាផ្នែកមួយនៃសហគមន៍មូលដ្ឋាន ដែលត្រូវមានតួនាទីធំធេង ក្នុងការប្រយុទ្ធប្រឆាំង ដើម្បីកាត់បន្ថយការឆ្លងរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងដោះស្រាយផលប៉ះពាល់នៃជម្ងឺនេះផងដែរ ។

**ខ. ការមិនរើសអើង**

នៅក្នុងស្មារតីធ្វើឱ្យរាល់ការងារអាចប្រព្រឹត្តទៅក្នុងលក្ខខណ្ឌសមរម្យ ការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរបស់បុគ្គលដែលមានមេរោគអេដស៍/ជំងឺអេដស៍ និងអ្នកដែលទទួលរងផលប៉ះពាល់ដោយសារជំងឺនេះ ។ ដូច្នេះ H8

ហើយ បានជាមិនត្រូវមានការរើសអើង ចំពោះកម្មករនិយោជិតដោយផ្អែកលើពតិមាន ថាពួកគេមានមេរោគអេដស៍/ជំងឺអេដស៍ ។ ការរើសអើង និងការប្រមាថមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ជាឧបស័គ្គរាំងដល់ការខិតខំប្រឹងប្រែង ក្នុងការបង្ការ ការឆ្លងរីករាលដាលនៃមេរោគនេះ ។

**គ. សមភាពយេនឌ័រ**

គួរតែបានទទួលស្គាល់មាត្រដ្ឋានយេនឌ័រ ដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ។ ស្ត្រីងាយទទួលរងគ្រោះជាងបុរសដោយសារលក្ខណៈជីវសាស្ត្រ វប្បធម៌សង្គម និងហេតុផលសេដ្ឋកិច្ច ដែលធ្វើឱ្យស្ត្រីជាអ្នកដែលងាយទទួលរងការឆ្លងមេរោគ និងផលប៉ះពាល់ធ្ងន់ធ្ងរ ដោយការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ។ ដរាបណាការរើសអើងដល់យេនឌ័រក្នុងសង្គមកាន់តែខ្លាំង និងដរាបណាស្ត្រីមានតួនាទីតូចទាបនៅក្នុងសង្គម ដរាបនោះស្ត្រីកាន់តែងាយរងគ្រោះដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។ ដូច្នេះហើយ សមភាពយេនឌ័រ និងការផ្តល់សិទ្ធិជាម្ចាស់ដល់ស្ត្រីជាចំណុចគន្លឹះសំខាន់ក្នុងការធ្វើឱ្យការបង្ការទប់ស្កាត់ ការឆ្លងរីករាលដាលមេរោគអេដស៍ និងជួយឱ្យស្ត្រីអាចដោះស្រាយផលវិបាកនៃជំងឺនេះ ទទួលបានជោគជ័យ ។

**ឃ. បរិយាកាសប្រកបដោយសុខុមាលភាពនៅកន្លែងធ្វើការ**

ដោយអនុលោមតាមអនុសញ្ញាលេខ១៥៥ ស្តីពីសុវត្ថិភាពការងារ និងការបង្ការសុខភាពឆ្នាំ១៩៨១ បរិយាកាសនៅកន្លែងធ្វើការគួរតែប្រកបដោយផាសុខភាពនិងសុវត្ថិភាព ធ្វើយ៉ាងណាឱ្យគ្រប់ផ្នែកទាំងអស់ងាយស្រួលនឹងបង្ការការចម្លងមេរោគអេដស៍ ។

បរិយាកាសប្រកបដោយផាសុខភាពនៅកន្លែងធ្វើការ សម្រួលយ៉ាងប្រសើរដល់ការប្រើប្រាស់កម្លាំងកាយ និងកម្លាំងចិត្តរបស់កម្មករនិយោជិត ក្នុងការបំពេញការងារដោយយោលទៅតាមសមត្ថភាពការងារ និងដោយផ្អែកតាមស្ថានភាពសុខភាព និងសុខភាពផ្លូវចិត្តរបស់ពួកគេ ។

**ង. ការចរចាសង្គម**

ការអនុវត្តន៍នូវគោលនយោបាយ និងកម្មវិធីស្តីពីមេរោគអេដស៍/ជំងឺអេដស៍ អាចទទួលបាននូវជោគជ័យ ដរាបណាមានកិច្ចសហប្រតិបត្តិការ និងការជឿទុកចិត្តរវាងនិយោជក កម្មករនិយោជិត និងតំណាងរបស់ពួកគេ និងមន្ត្រីរាជការ ហើយបើជាករណីចាំបាច់នោះ គួរមានការចូលរួមយ៉ាងសកម្មពីកម្មករនិយោជិត ដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងអ្នករងគ្រោះដោយសារជំងឺអេដស៍ ។

**ច. ការពិនិត្យឈាមរកមេរោគអេដស៍ក្នុងគោលបំណងបដិសេធពីការងារ**

មិនត្រូវទាមទារឱ្យអ្នកដាក់ពាក្យសុំបំរើការងារ ឬអ្នកកំពុងបំពេញការងារ ពិនិត្យឈាមរកមេរោគអេដស៍/ជំងឺអេដស៍ឡើយ ។

**ឆ. ការរក្សាភាពសម្ងាត់**

គ្មានហេតុផលណាមួយដែលតម្រូវឱ្យអ្នកដាក់ពាក្យសុំបំរើការងារ ឬកម្មករនិយោជិត បង្ហាញព័ត៌មានផ្ទាល់ខ្លួនដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ឡើយ ។ ហើយកម្មករនិយោជិតក៏មិនតម្រូវឱ្យបង្ហាញព័ត៌មានផ្ទាល់ខ្លួនទាំងនេះ ទៅដល់កម្មករនិយោជិតដទៃទៀតដែរ ។ ការបើកឆែកមើលពត៌មានផ្ទាល់ខ្លួនទាំងឡាយណាដែលទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ត្រូវធ្វើឡើងតាមគោលការណ៍រក្សាការសម្ងាត់ ដែលសមស្របនឹងគោលការណ៍របស់អង្គការអន្តរជាតិខាងការងារ ស្តីពីការការពារពត៌មានផ្ទាល់ខ្លួន របស់កម្មករនិយោជិត ។

**ជ. ការបន្តរក្សាទំនាក់ទំនងក្នុងការបំរើការងារ**

ការឆ្លងមេរោគអេដស៍ ពុំមែនជាមូលហេតុនៃការបញ្ឈប់ពីការងារឡើយ ។ បើធៀបទៅនឹងលក្ខខណ្ឌផ្សេងៗនោះ អ្នកផ្ទុកមេរោគអេដស៍ ក៏អាចបន្តការងារបាន ដរាបណាដែលគ្រូពេទ្យបញ្ជាក់ថានៅមានសុខភាពមាំមួន ហើយអាចបំពេញការងារបាន ។

**ឈ. ការបង្ការ**

គេអាចបង្ការការចម្លងមេរោគអេដស៍បាន ។ ការបង្ការគ្រប់ផ្លូវចម្លងមេរោគ អាចធ្វើឡើងតាមរយៈយុទ្ធសាស្ត្រមួយចំនួនដែលផ្តោតចំទៅនឹងស្ថានភាពជាក់ស្តែងរបស់ប្រទេស ហើយសមស្របនឹងវប្បធម៌ទៀតផង ។
ការបង្ការអាចធ្វើឡើងបានតាមរយៈការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្ត ការបង្កើនចំណេះដឹង ការព្យាបាល និងការបង្កើតឱ្យមានបរិយាកាសសង្គមដោយគ្មានការរើសអើង ។
ដៃគូនានាដែលបំរើការងារសង្គម សុទ្ធតែមានតួនាទីក្នុងការលើកកំពស់ការបង្ការ ជាពិសេសធ្វើយ៉ាងណាឱ្យមានការផ្លាស់ប្តូរឥរិយាបថនិងការប្រព្រឹត្ត តាមរយៈការផ្តល់ពត៌មាន ការអប់រំ និងការកែប្រែកត្តាសង្គម សេដ្ឋកិច្ចដែលនាំឱ្យមានការប្រឈមនឹងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ ។

**ញ. ការថែទាំ និងការគាំទ្រ**

នៅក្នុងពិភពការងារ សាមគ្គីភាព ការថែទាំ និងការគាំទ្រ គួរជាមគ្គុទ្ទេសក៍ក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ ។ កម្មករនិយោជិតទាំងអស់ រួមទាំងកម្មករនិយោជិតដែលផ្ទុកមេរោគអេដស៍ មានសិទ្ធិគ្រប់គ្រាន់ ក្នុងការទទួលបាននូវសេវាសុខភាព ។ មិនត្រូវមានការរើសអើងដល់អ្នកទាំងនោះ និងគ្រួសារពួកគេ ក្នុងការប្រើប្រាស់សេវា និងការទទួលផលកំរៃពីកម្មវិធីសន្តិសុខសង្គម និងផែនការផ្តល់ការឧបត្ថម្ភផ្សេងៗដែលបានមកពីការងារឡើយ ។

**ប្រការ ១៣.-**

នាយកដ្ឋានពេទ្យការងារនៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ច ដូចតទៅ: HS

-ផ្ដល់ជំនួយផ្នែកបច្ចេកទេស ឯកសារ វិធីសាស្ត្រផ្សេងៗដល់ក្រុមការងារអេដស៍ ឬ គណៈកម្មការអេដស៍នៃសហគ្រាស គ្រឹះស្ថាននានា សំដៅជួយដល់ក្រុមការងារ ឬគណៈកម្មការទាំងនោះអាចដំណើរការបានជោគជ័យ ។

-ចុះត្រួតពិនិត្យ និងតាមដានការអនុវត្តន៍បទប្បញ្ញត្តិនៃប្រកាសនេះជាប្រចាំ ។

-ផ្សព្វផ្សាយ ពន្យល់និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង ប្រការ២ ខាងលើឱ្យយល់ជ្រួតជ្រាប ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ ។

-ចាត់វិធានការផ្ដល់ដំបូន្មាន ហើយក្នុងករណីធ្ងន់ធ្ងរ ចាត់វិធានការដាក់កំហិតចំពោះនិយោជកដែលពុំព្រមអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃប្រកាសនេះ ។

-បូកសរុប និងលើកសំណើផ្ដល់ការសរសើរ ឬលើកទឹកចិត្ត តាមរូបភាពផ្សេងៗជូនដល់និយោជកដែលខិតខំអនុវត្តបទប្បញ្ញត្តិនៃប្រកាសនេះបានល្អ ។

**ប្រការ ១៤.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៕

**ចម្លងជូនៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
-*អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
 "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានបណ្ដុះបណ្ដាលវិជ្ជាជីវៈ
 "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរ ការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
 "ដើម្បីផ្សព្វផ្សាយ និង អនុវត្ត"
-សមាគមនិយោជក "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សហភាពសហព័ន្ធសហជីព សហព័ន្ធសហជីព សហជីពមូលដ្ឋាន
 "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់បណ្ដាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

រដ្ឋមន្ត្រី

ញ៉ៀប ប៊ុនជិន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាងឧបសម្ព័ន្ធនៃប្រកាសលេខ ០៨៦ ក.ក.ប.វ/ប្រក
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦

**បញ្ជីរាយនាមក្រុមការងារ ឬបញ្ជីរាយនាមគណៈកម្មការអេជីស៍**
**នៃសហគ្រាស (ឬក្រុមហ៊ុន ឬរោងចក្រ)**

| ល.រ. | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃ ខែ ឆ្នាំកំណើត | មុខងារក្នុងសហគ្រាស | មុខងារក្នុងក្រុមការងារ ឬគណៈកម្មការ | អាសយដ្ឋានទាក់ទង | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

បានបញ្ឈប់បញ្ជីត្រឹមចំនួន......................នាក់។
ធ្វើនៅភ្នំពេញ ថ្ងៃទី................ខែ..............ឆ្នាំ ២០០
ប្រធានក្រុមការងារ ឬប្រធានគណៈកម្មការ
ហត្ថលេខា និងឈ្មោះ

## ឧបសម្ព័ន្ធទី ៣: មាត្រាពាក់ព័ន្ធមួយចំនួននៃ ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ជម្ងឺអេដស៍

### ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍(HIV/AIDS) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយ ដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ:

### ជំពូកទី ១: បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់បង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និង ជម្ងឺអេដស៍ (HIV/AIDS) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២.-

ជម្ងឺអេដស៍ គឺជាជម្ងឺឆ្លងរីករាលដាលមួយបង្កឡើងដោយមេរោគអេដស៍ និងដែលទទួលស្គាល់ថា គ្មានព្រំដែន ផ្នែកផែនដី សង្គម នយោបាយ និង សេដ្ឋកិច្ច ហើយជម្ងឺនេះពុំទាន់មានថ្នាំព្យាបាលឱ្យជាសះស្បើយទេ។ ការរីករាលដាលនៃជម្ងឺនេះ បាននឹងកំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទៅលើសន្តិសុខ ស្ថិរភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងទាមទារឱ្យរដ្ឋចាត់វិធានការឆ្លើយតបជាពហុវិស័យ ដើម្បី:

១- ជំរុញឱ្យមានការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូបស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) តាមរយៈកម្មវិធីអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយទូទាំងប្រទេស។

២. ហាមឃាត់ការរើសអើងគ្រប់ប្រភេទចំពោះ រាល់បុគ្គលណាដែលត្រូវបានសង្ស័យ ឬត្រូវបានដឹងថាមានមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ។

៣. ជំរុញឱ្យមានការប្រុងប្រយ័ត្នជាសកលចំពោះ វិធីសាស្ត្រ និងការអនុវត្តន៍ទាំងឡាយដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងការឆ្លងមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ។

៤. ចាត់វិធានការសមស្រប ចំពោះរាល់កត្តាទាំងឡាយដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរដល់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍(HIV/AIDS) ។

៥- លើកទឹកចិត្តឱ្យមានតួនាទីជាសក្តានុពលរបស់ បុគ្គលដែលមានមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ក្នុងការលាតត្រដាងព័តមាន និងបទពិសោធន៍របស់ពួកគេ ដើម្បីចង្អុលបង្ហាញដល់ សាធារណជន។

៦- បញ្ចូលកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ជាកម្មវិធីអាទិភាព ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ។

…

**ជំពូកទី ២: ការអប់រំ និងការផ្សព្វផ្សាយព័តិមាន**

…

មាត្រា ៩.-

គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ រៀបចំឱ្យមានកម្មវិធីអប់រំស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) នៅកន្លែងធ្វើការដោយត្រូវបញ្ចូលទាំងប្រធានបទចំពោះការរក្សាភាពសម្ងាត់នៅកន្លែងធ្វើការ និងឥរិយាបថចំពោះអ្នកមានមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ។

ជាមួយគ្នានឹងការអប់រំស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវរៀបចំឱ្យមានផែនការទៅតាមអាណត្តិការងាររបស់ខ្លួនក្នុងការរួមចំណែកទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍។

…

**ជំពូកទី ៤: ការធ្វើតេស្ត និងការផ្តល់កិច្ចប្រឹក្សា**

…

មាត្រា ១៩.-

ការធ្វើតេស្ត មេរោគអេដស៏ និងជម្ងឺអេដស៏ (HIV/AIDS) ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងត្រូវមានការយល់ព្រមជាមុនពីសាម៉ីជនផ្ទាល់។ ចំពោះសាម៉ីជនជាអនីតិជន តម្រូវឱ្យមានការយល់ព្រមជាលាយលក្ខអក្សរពីអាណាព្យាបាលស្របច្បាប់។

បើការយល់ព្រមជាលាយលក្ខអក្សរពីអាណាព្យាបាលស្របច្បាប់ពុំអាចធ្វើបាន ការធ្វើតេស្ត មេរោគអេដស៏ និងជម្ងឺអេដស៍ (HIV/AIDS) អាចប្រព្រឹត្តទៅបានដោយគ្រាន់តែមាន ការព្រមព្រៀងពីអនីតិជន ប្រសិនបើការធ្វើតេស្តនេះផ្តល់អត្ថប្រយោជន៍ផ្ទាល់ចំពោះអនីតិជននោះ។

ចំពោះ ជនវិកលចរិត រដ្ឋត្រូវយកចិត្តទុកដាក់។

មាត្រា២០.-

ហាមដាច់ខាតចំពោះការដាក់ល័ក្ខខ័ណ្ឌឱ្យធ្វើតេស្តមេរោគអេដស៏ និងជម្ងឺអេដស៏ (HIV/AIDS) មុន និងក្រោយការអនុញ្ញាតឱ្យចូលបំរើការងារ ចូលសិក្សានៅក្នុងគ្រឹះស្ថានសិក្សានានា ក៏ដូចជា សម្រាប់ការអនុវត្តន៏សេរីភាពស្នាក់នៅ សិទ្ធិធ្វើដំណើរ ការផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ ឬសេវាកម្មផ្សេងទៀត។

មាត្រា ២១.-

ការធ្វើតេស្ត មេរោគអេដស៏ និងជម្ងឺអេដស៏ (HIV/AIDS) ដោយបង្ខំ ត្រូវអនុញ្ញាតតែក្នុងករណីមានសេចក្តីបង្គាប់របស់តុលាការ។

• • •

## ជំពូកទី ៧: ការរក្សាភាពសម្ងាត់

មាត្រា ៣៣.-

អ្នកមានមេរោគអេដស៏ និងជម្ងឺអេដស៍ (HIV/AIDS) ត្រូវទទួលបានការរក្សាភាពសម្ងាត់។ អ្នកមានអាជីពផ្នែកវេជ្ជសាស្ត្រ កម្មករ និយោជក ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនានា ក្រុមហ៊ុនធានារ៉ាប់រង អ្នកបញ្ចូលទិន្នន័យ អ្នករក្សាសំណុំឯកសារទាក់ទងនឹងមេរោគអេដស៏ និងជម្ងឺអេដស៍ (HIV/AIDS) និង អ្នកដែលមានភារកិច្ច

ពាក់ព័ន្ធផ្សេងៗទៀត ត្រូវបានទទួលការណែនាំឱ្យយកចិត្តទុកដាក់ពីការរក្សាការសម្ងាត់ នៅក្នុងទំនាក់ទំនងការងារ ជាពិសេសអត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួនរបស់អ្នកមានមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ។

…

មាត្រា ៣៥.-

លទ្ធផលនៃការធ្វើតេស្ត មេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) អាចផ្តល់ឱ្យ:

ក- ជនដែលសុំធ្វើតេស្ត មេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ដោយស្ម័គ្រចិត្ត

ខ- អាណាព្យាបាលស្របច្បាប់របស់អនីតិជនដែលត្រូវបានធ្វើតេស្ត មេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS)

គ- ជនដែលត្រូវបានអនុញ្ញាតឱ្យទទួលលទ្ធផលនេះ សម្រាប់កម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS) ដូចដែលមានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ និង

ឃ- តាមតម្រូវការរបស់តុលាការដូចមានចែងក្នុងចំណុច (គ) មាត្រា ៣៤ នៃច្បាប់នេះ។

## ជំពូកទី ៨: គោលនយោបាយ និង សកម្មភាពនៃការរើសអើង

មាត្រា ៣៦.-

ហាមដាច់ខាតការរើសអើងដល់ជនណាម្នាក់តាមបែបណាមួយគិតពីមុន និងក្រោយពេល ឱ្យចូលបំរើការងារ រួមទាំងការងារ រួមទាំងការជួល ការតំឡើងឋានន្តរសក្តិ ការចាត់ឱ្យបំពេញការងារ ការរួមរស់នៅក្នុងសង្គម ដោយផ្អែកលើការដឹង ឬសង្ស័យថា ជននោះ ឬក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS ។ ត្រូវចាត់ទុកថាខុសច្បាប់ រាល់ការបញ្ឈប់ពី ការងារចំពោះជនណាម្នាក់ ដោយផ្អែកលើការដឹង ឬសង្ស័យថាជននោះ ឬក្រុមគ្រួសាររបស់ជននោះមាន មេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS)។

…

## ជំពូកទី ១០: ទោសប្បញ្ញត្តិ

មាត្រា ៥១.-

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា... ឬមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោស ពិន័យជាប្រាក់ពី ៥០.០០០ (ប្រាំម៉ឺន) រៀល ដល់ ២០០.០០០ (ម្ភៃម៉ឺន) រៀល និងត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារ ពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល។

មាត្រា ៥២.-

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៦ ... នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល និង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ៦ (ប្រាំមួយ) ខែ។ ករណីពុំរាង ចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល។

***ព័ត៌មានលំអិត សូមអាន “ ច្បាប់ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍ (HIV/AIDS)”***

## ឧបសម្ព័ន្ធទី ៤: គោលនយោបាយទូទៅស្តីពីមេរោគអេដស៍ និង ជម្ងឺអេដស៍ នៅកន្លែងធ្វើការ

## គោលនយោបាយ ស្តីអំពីមេរោគអេដស៍ និងជម្ងឺអេដស៍នៅ

*( ឈ្មោះសហគ្រាស គ្រឹះស្ថាន )*

### សេចក្តីផ្តើម

( *សហគ្រាស គ្រឹះស្ថាន...* ) ទទួលស្គាល់ការរីករាលដាលដ៏ធ្ងន់ធ្ងរនៃមេរោគអេដស៍ និងជម្ងឺអេដស៍ និង ផលប៉ះពាល់របស់វាមកលើកន្លែងការងារ ។ ( *សហគ្រាស គ្រឹះស្ថាន*) គាំទ្រដល់ការឆ្លើយតបរបស់ជាតិដើម្បី កាត់បន្ថយ ការរីករាលដាល និងផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍ ។

### គោលបំណង

គោលបំណងនៃគោលនយោបាយនេះ គឺដើម្បីធានាឱ្យមានវិធីសាស្រ្តដ៏ប្រាកដប្រជាមួយ ដើម្បីដោះស្រាយឱ្យ បានជាប់លាប់ជាប្រចាំ និង ស្មើភាពគ្នា ដើម្បីបង្ការមេរោគអេដស៍ក្នុងចំណោម បុគ្គលិក កម្មករនិយោជិត និងលើ ការគ្រប់គ្រងផលវិបាកនៃមេរោគអេដស៍ និងជម្ងឺអេដស៍ ដោយរួមទាំងការថែទាំ និងគាំទ្រដល់បុគ្គលិក កម្មករនិយោជិត ដែលរស់នៅជាមួយមេរោគអេដស៍ និងជម្ងឺអេដស៍ ។ គោលនយោបាយនេះ នឹងជួយ បង្កើនសាមគ្គីភាពរវាងនិយោជក និងកម្មករនិយោជិត និងផលិតភាពការងារផងដែរ ។ គោលនយោបាយនេះ ត្រូវបានបង្កើតឡើង និងអនុវត្ត ដោយមានការពិគ្រោះយោបល់ជាមួយបុគ្គលិកគ្រប់ជាន់ថ្នាក់ ។

### ក្របខណ្ឌគោលនយោបាយ និងគោលការណ៍ទូទៅ

( *សហគ្រាស គ្រឹះស្ថាន*) ទទួលស្គាល់នូវគោលការណ៍ជាគន្លឹះ១០ចំនុច នៃគោលការណ៍អនុវត្តន៍ស្តីពីមេរោគ អេដស៍ និងជម្ងឺអេដស៍ និងពិភពការងារ របស់អង្គការពលកម្មអន្តរជាតិ និង ច្បាប់ស្តីពីការបង្ការ និង ការប្រយុទ្ធ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជម្ងឺអេដស៍ជាមូលដ្ឋាន សម្រាប់ធ្វើសកម្មភាពឆ្លើយតបទៅនឹងមេរោគ អេដស៍ និងជម្ងឺអេដស៍ ។

នៅពេលដែលក្រុមហ៊ុន *(សហគ្រាស គ្រឹះស្ថាន)* ទទួលស្គាល់ថា មានលក្ខខណ្ឌច្បាស់លាស់ដែលនាំឱ្យមានការ ឆ្លងមេរោគអេដស៍ ដូច្នេះគោលនយោបាយនេះបានលើកជាគោលការណ៍ថា មេរោគអេដស៍ និងជម្ងឺអេដស៍ គួរត្រូវបាន ចាត់ទុកដូចជាលក្ខខណ្ឌនៃមេរោគ ឬជម្ងឺធ្ងន់ធ្ងរដ៏ទៃទៀត ដែលអាចប៉ះពាល់ដល់បុគ្គលិក កម្មករនិយោជិតដែរ ។

ជាមួយគ្នានេះ ខ្លួនក៏បានគិតគូរផងដែរពីភាពពិតនៃអ្នកផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ គឺពួកគេអាចរស់នៅបន្តបានយូរឆ្នាំតទៅទៀត បន្ទាប់ពីគេបានឆ្លងមេរោគនេះហើយ។ ការប្តេជ្ញាចិត្តរបស់ *សហគ្រាស គ្រឹះស្ថាន* គឺដើម្បីលើកកំពស់ឱ្យមានបរិយាកាសការងារប្រកបដោយសុខភាព សុវត្ថិភាពល្អសម្រាប់បុគ្គលិក កម្មករនិយោជិតទាំងអស់ផ្អែកលើការ ទទួលស្គាល់ថាមេរោគអេដស៍ និងជម្ងឺអេដស៍មិនឆ្លងតាមការប្រាស្រ័យទាក់ទងធម្មតានោះទេ។

## វិសាលភាពនៃគោលនយោបាយ

គោលនយោបាយនេះ ត្រូវអនុវត្ត សម្រាប់ថ្នាក់ដឹកនាំ និង បុគ្គលិក កម្មករនិយោជិតទាំងអស់។

## ខ្លឹមសារនៃគោលនយោបាយ

### ១. ការការពារប្រឆាំងនឹងការរើសអើង -ការធ្វើឱ្យរងគ្រោះ -ការបៀតបៀន

បុគ្គលិក កម្មករនិយោជិតទាំងអស់ នឹងត្រូវបានទទួលបាននូវការការពារប្រឆាំងនឹងការរើសអើង ការធ្វើឱ្យរងគ្រោះ ការបៀតបៀនផ្សេងៗទោះផ្អែកលើការដឹងច្បាស់ ឬសង្ស័យថាមានផ្ទុកមេរោគអេដស៍ក៏ដោយ។

### ២. ឱកាសក្នុងការងារ និង ការបញ្ឈប់ពីការងារ

គ្មានបុគ្គលិក កម្មករនិយោជិតណាម្នាក់ នឹងត្រូវទទួលរងនូវការឈឺចាប់ពីផលវិបាកដែលកើតមានទោះជាត្រូវបណ្តេញចេញ ឬបដិសេធមិនទទួលឱ្យធ្វើការងារ ដោយសារតែបញ្ហាជាមូលដ្ឋាននៃមេរោគអេដស៍ និងជម្ងឺអេដស៍ទេ។

### ៣. ការធ្វើតេស្ត

ការធ្វើតេស្តឈាមរកមេរោគអេដស៍ នឹងមិនតំរូវឱ្យមានសម្រាប់អ្នកដាក់ពាក្យសុំចូលធ្វើការ ឬសម្រាប់បុគ្គលិក កម្មករនិយោជិតដែលកំពុងបំពេញការងារឡើយ។ ទោះបីជាយ៉ាងនោះក្តី (*សហគ្រាស គ្រឹះស្ថាន*) នឹងលើកទឹកចិត្ត និងផ្តល់ភាពងាយស្រួលដល់បុគ្គលិក កម្មករនិយោជិតគ្រប់រូបឱ្យទៅទទួលសេវាប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។ សេវាប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ត្រូវអនុវត្ត និងអាចទទួលយកបានទៅតាមលក្ខណៈស្តង់ដាជាតិ និងអន្តរជាតិដោយមាននូវការផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្តឈាម ការយល់ព្រមដោយស្ម័គ្រចិត្ត មានការរក្សាការសម្ងាត់ និងការគាំទ្រ។

## ៤ ការថែទាំ និងគាំទ្រ ដល់បុគ្គលិក កម្មករនិយោជិត

ក្រុមហ៊ុន ( *សហគ្រាស គ្រឹះស្ថាន* ) ប្រតិបត្តិចំពោះបុគ្គលិក កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ ឬ រងគ្រោះដោយសារមេរោគអេដស៍ទាំងអស់ដោយការយល់ចិត្ត និង ថែទាំគាំទ្រ។ ក្រុមហ៊ុន ( *សហគ្រាស គ្រឹះស្ថាន*) នឹងផ្តល់ជំនួយឧបត្ថម្ភសមរម្យរួមមានៈ ការផ្តល់ប្រឹក្សាយោបល់ ការផ្តល់ឱកាស ឈប់សម្រាក សម្រាកពេលមានជម្ងឺ និងព័ត៌មានផ្សេងៗទាក់ទងទៅនឹងមេរោគអេដស៍នេះ និង ផលប៉ះពាល់របស់វា។

## ៥ អំពីការបំពេញការងារ

វាគឺជាគោលនយោបាយរបស់ (*សហគ្រាស គ្រឹះស្ថាន*) ដែលឆ្លើយតបទៅនឹងការប្រែប្រួលនូវស្ថានភាពសុខភាពរបស់បុគ្គលិក កម្មករនិយោជិត ដោយផ្តល់ឱ្យនូវកន្លែងការងារសមស្របសម្រាប់អ្នកដែលមានផ្ទុកមេរោគអេដស៍។ បុគ្គលិក កម្មករនិយោជិតទាំងអស់អាចនៅបន្តធ្វើការងារតាមដែលគេអាចធ្វើទៅបាន បើគេនៅតែអាចបំពេញកាតព្វកិច្ចរបស់គេប្រកបដោយសុវត្ថិភាព និង សមស្របទៅនឹងស្តង់ដារការងារដែល(*សហគ្រាស គ្រឹះស្ថាន*) អាចទទួលយកបាន។ ប្រសិនបើក្នុងករណីបុគ្គលិក កម្មករនិយោជិត ដែលមានផ្ទុកមេរោគអេដស៍នោះ ក្លាយទៅជាអ្នកជម្ងឺអេដស៍ ហើយមិនអាចនៅធ្វើការងាររបស់គេបានតទៅទៀតទេ អ្នកគ្រប់គ្រង ឬប្រធានផ្នែកផ្ទាល់ត្រូវដោះស្រាយបញ្ហានេះតាមនិតិវិធីរបស់ក្រុមហ៊ុនដោយយោងទៅលើការបំពេញការងារខ្សោយ ឬមានជម្ងឺ។

## ៦ អត្ថប្រយោជន៍

បុគ្គលិក កម្មករនិយោជិត ដែលរស់នៅជាមួយមេរោគអេដស៍ទាំងអស់ ត្រូវទទួលបាននូវអត្ថប្រយោជន៍ដូចបុគ្គលិកដ៏ទៃទៀតដែលមានជម្ងឺ ឬលក្ខខណ្ឌសុខភាពធ្ងន់ធ្ងរដែរ ដោយរួមនឹងផលប្រយោជន៍តាមលក្ខន្តិកៈការងារ ឬទទួលបានពីក្រុមហ៊ុន (*សហគ្រាស គ្រឹះស្ថាន*) ការផ្តល់សំណងការងារដែលអាចធ្វើទៅបាន និងធនធានផ្សេងៗដែលមាន។

## ៧ ការថែទាំសុខភាព

ក្រុមហ៊ុន (*សហគ្រាស គ្រឹះស្ថាន*) នឹងជួយបុគ្គលិក កម្មករនិយោជិតដែលមានផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍ ដើម្បីឱ្យពួកគេអាចរកសេវាព្យាបាលបានសមស្របនៅក្នុងសហគមន៍របស់ពួកគេ ក៏ដូចជាសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ សេវាថែទាំគាំទ្រពីអ្នកមានវិជ្ជាជីវៈ និងពីក្រុមជួយខ្លួនឯងប្រសិនបើពួកគេត្រូវការ។ ការអនុញ្ញាតឱ្យឈប់សម្រាកដោយសមហេតុផល ដើម្បីឱ្យពួកគេទៅទទួលសេវាផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និង រក្សាការសម្ងាត់ និងការព្យាបាលផ្សេងៗ។

## ៩. ការអនុវត្តន៍ និងការត្រួតពិនិត្យតាមដាន

*សហគ្រាស គ្រឹះស្ថាន* បានបង្កើតឱ្យមានគណៈកម្មការប្រយុទ្ធនឹងជម្ងឺអេដស៍ដើម្បីសំរបសម្រួល និងអនុវត្ត គោលនយោបាយ និងកម្មវិធីអប់រំពីជម្ងឺអេដស៍។ គណៈកម្មការនេះត្រូវមានសមាជិកដែលជាតំណាងពីគ្រប់ផ្នែកនៃកន្លែងការងារមានដូចជាៈ យ៉ាងតិចតំណាងនិយោជក ២នាក់ តំណាងសហជីព ២នាក់ និងអ្នកទទួលខុសត្រូវគិលានដ្ឋាន ១នាក់ ។ ***សូមមើលប្រកាសលេខ ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍ នៅតាមសហគ្រាស គ្រឹះស្ថាន និងការបង្ការទប់ស្កាត់មេរោគអេដស៍ និងជម្ងឺអេដស៍នៅកន្លែងធ្វើការ*** ។

ការអនុវត្តន៍គោលនយោបាយនេះ នឹងបញ្ជាក់អំពីវិន័យជាធម្មតារបស់(*សហគ្រាស គ្រឹះស្ថាន* ) និង និតិវិធីក្នុងការសំដែងសារទុក្ខ។ ការរក្សាការសម្ងាត់នឹងត្រូវធានាអះអាងទៅតាមគ្រប់នីតិវិធីទាំងអស់។

ដើម្បីធ្វើផែនការ និងវាយតម្លៃទៅលើគោលនយោបាយ និងកម្មវិធីស្តីពីជម្ងឺអេដស៍ឱ្យមានប្រសិទ្ធភាព (*សហគ្រាស គ្រឹះស្ថាន...*) នឹងត្រូវធ្វើការអង្កេតមួយដើម្បីបង្កើតទិន្នន័យបឋម និង ការសិក្សាទៅលើការប្រឈមមុខនឹងគ្រោះថ្នាក់ និងលទ្ធផលដែលទទួលបាន។ ការសិក្សានេះនឹងត្រូវធ្វើឡើង ដោយមានការចូលរួម និង ពិគ្រោះពិភាក្សាយោបល់ជាមួយបុគ្គលិក កម្មករនិយោជិត ព្រមទាំងតំណាងរបស់គេក្នុងបែបផែនមួយដែលមានលក្ខណៈសម្ងាត់បំផុត។

គោលនយោបាយ និងព័ត៌មានផ្សេងៗដែលទាក់ទងនឹងមេរោគអេដស៍ និងជម្ងឺអេដស៍នេះនឹងត្រូវផ្សព្វផ្សាយទៅគ្រប់បុគ្គលិក កម្មករនិយោជិតនៅក្នុង (*សហគ្រាស គ្រឹះស្ថាន*) ទាំងអស់ដោយប្រើប្រាស់នូវមធ្យោបាយទំនាក់ទំនង ទូលំទូលាយដែលសមស្របរបស់(*សហគ្រាស គ្រឹះស្ថាន*) ។

គោលនយោបាយនេះនឹងត្រូវពិនិត្យ និងកែសម្រួលជារៀងរាល់ឆ្នាំបើចាំបាច់ ទៅតាមលក្ខខណ្ឌ ដែលមានការផ្លាស់ប្តូរ ឬទៅតាមរបកគំហើញរបស់ការអង្កេត ឬការសិក្សានានា។

**ថ្ងៃទី ខែ ឆ្នាំ**

ហត្ថលេខា
( ឈ្មោះ )
ប្រធាន ( ***សហគ្រាស គ្រឹះស្ថាន*** )

ហត្ថលេខា
( ឈ្មោះ )
( តំណាងបុគ្គលិក កម្មករឬសហជីព)

## ឧបសម្ព័ន្ធទី ៥: បញ្ជីអ្នកផ្តល់សេវាប្រឹក្សា ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ និងអ្នកផ្តល់សេវាព្យាបាលជម្ងឺកាមរោគ និង ព័ត៌មានតាមមូលដ្ឋាន

<table>
<tr><td rowspan="1">មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ (NCHADS) : ផ្នែកផ្តល់ប្រឹក្សាដោយរក្សាការសម្ងាត់ និងធ្វើតេស្តឈាម</td><td>វេជ្ជបណ្ឌិត. ព្រុំ ផានិត<br>ទូរស័ព្ទ: ០១២ ៩៦៧ ៧៥៨ អ៊ីមែល: vcct@nchads.org<br><br>វេជ្ជបណ្ឌិត. សុខ បញ្ញា<br>ទូរស័ព្ទ: ០១៦ ៨៥១ ៥៩៥ អ៊ីមែល: vcct@nchads.org<br><br>វេជ្ជបណ្ឌិត. ជា ចាន់កុសលមុន្នី<br>ទូរស័ព្ទ: ០១៦ ៨៥១ ៥៩៥ អ៊ីមែល: vcct@nchads.org</td></tr>
<tr><td rowspan="3">ទីក្រុងភ្នំពេញ</td><td>គ្លីនិកជាតិកាមរោគ និងសើស្បែក អគារលេខ ២៥៥H ផ្លូវជាតិលេខ៦A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ។<br>ទូរស័ព្ទទំនាក់ទំនង ០២៣-២១៣ ០២៤</td></tr>
<tr><td>មន្ទីរពេទ្យគាំពារមាតា និងទារក<br>អគារលេខ ៨៦ ផ្លូវ ៤៧ ភ្នំពេញ</td></tr>
<tr><td>លេខទូរស័ព្ទឥតខ្សែ ០១២ ៩៩៩ ០០៨<br>០១២ ៩៩៩ ០០៩<br>០៩២ ៩១៤ ១១១<br>មិនគិតប្រាក់សម្រាប់ ០១២ ០៩២ និង ០១៧<br>ការសន្ទនាត្រូវបានរក្សាជាការសម្ងាត់<br><br>→ អ្នកអាចហៅទៅលេខទូរស័ព្ទសមាគមឥតខ្សែ ដើម្បីសាកសួរព័ត៌មាន និងសាកសួរអំពីសេវាបញ្ជូននានា</td></tr>
</table>

| | |
|---|---|
| ខេត្តតាកែវ | មន្ទីរសុខាភិបាល<br>ភូមិផ្សារដង្កោរ ឃុំរកាក្នុង ស្រុកដូនកែវ<br>លោក អ៊ុច សារ៉េត<br>អ្នកផ្តល់ប្រឹក្សា ទូរស័ព្ទ: ០១១ ៦៣៣ ៤៥១ |
| ខេត្តកណ្តាល | មន្ទីពេទ្យបង្អែកជ័យជំនះ<br>ភូមិក្រពើហារ ឃុំព្រែកឬស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល<br>វេជ្ជបណ្ឌិត គង់ ឈុនលី<br>ប្រធានមន្ទីរពេទ្យបង្អែក ទូរស័ព្ទ: ០១២ ៩៧៨ ០៩៩ |
| ខេត្តកំពង់ស្ពឺ | មន្ទីពេទ្យបង្អែកកំពង់ស្ពឺ<br>ភូមិស្នួរ ឃុំ រការធំ ស្រុក ច្បារមន ខេត្តកំពង់ស្ពឺ<br>លោក ហួន ធិន<br>ប្រធានការិយាល័យអេដស៏ខេត្ត (PAO) ទូរស័ព្ទ: ០១៦ ៨៥៦ ៤៩៣ |
| ក្រុងព្រះសីហនុ | មន្ទីពេទ្យបង្អែកក្រុងសីហនុ<br>សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ<br>អ្នកស្រី គីម ស៊ីថា<br>ប្រធាន PAO ទូរស័ព្ទ: ០១៦ ៨៨៨ ១១០ |
| ខេត្តបាត់ដំបង | PAO<br>ឃុំរតនះ ស្រុកបាត់ដំបង<br>វេជ្ជបណ្ឌិត. ឡាយ វិធា<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៨២៣ ០៦៧ |
| ខេត្តសៀមរាប | មណ្ឌលសុខភាពមណ្ឌល ១<br>ភូមិមណ្ឌល ១ ឃុំស្វាយដង្គុំ ស្រុកសៀមរាប<br>វេជ្ជបណ្ឌិត. ក្រូស សារ៉ាត់<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៦៩៥ ៦៧៦ |

| | |
|---|---|
| ខេត្តកំពង់ចាម | គ្លីនិកសុខភាពគ្រួសារ<br>ផ្លូវលេខ ៧ ឃុំកំពង់ចាម ស្រុកកំពង់ចាម<br>វេជ្ជបណ្ឌិត. ឈុន លីពេជ្យ<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៨២៣ ៩២៣ |
| ខេត្តកំពង់ធំ | មន្ទីរពេទ្យបង្អែកកំពង់ធំ<br>ភូមិ ៧ ឃុំកំពង់ធំ ស្រុកស្ទឹងសែន<br>វេជ្ជបណ្ឌិត. យូ ពិសិទ្ធ<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៨៣៨ ៨៨៥ |
| ខេត្តបន្ទាយមានជ័យ | មន្ទីរពេទ្យបង្អែកមង្គលបុរី<br>ភូមិកោះកែវ ឃុំឬស្សីក្រុង ស្រុកមង្គលបុរី<br>អ្នកស្រី ស៊ិន អៀប<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៩៥៣ ២៨៤ |
| ខេត្តព្រៃវែង | VCCT កំពង់លាវ<br>ភូមិ ១ ឃុំកំពង់លាវ ស្រុកកំពង់លាវ<br>អ្នកស្រី ឡៅប វាសនា<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៩៥៦ ០១០ |
| ខេត្តស្វាយរៀង | មន្ទីរពេទ្យបង្អែកស្វាយរៀង<br>ភូមិស្រះវង្ស ឃុំស្វាយរៀង ស្រុកស្វាយរៀង<br>វេជ្ជបណ្ឌិត. អ៊ុង ស៊ិងគង់<br>ប្រធានPAO ទូរស័ព្ទ: ០១២ ២១៣ ៦៥២ |
| ខេត្តកោះកុង | មន្ទីរពេទ្យបង្អែកស្មាច់មានជ័យ<br>ភូមិ១ ឃុំស្មាច់មានជ័យ ស្រុកស្មាច់មានជ័យ<br>វេជ្ជបណ្ឌិត. ឡេង វេងសែ<br>អនុប្រធានមន្ទីរសុខាភិបាល ទូរស័ព្ទ: ០១៦ ៨២៣ ០២១ |

| | |
|---|---|
| ខេត្តកំពត | VCCT កំពត<br>ភូមិ ១ឧសភា ឃុំកំពង់កណ្តាល ស្រុកកំពង់បាយ<br>អ្នកស្រី យូ សាគន្ធ<br>ប្រធានPAO ទូរស័ព្ទ: ០១២ ៧៥២ ០២១ |
| ខេត្តកំពង់ឆ្នាំង | ភូមិកណ្តាល ឃុំកំពង់ឆ្នាំង ស្រុកកំពង់ឆ្នាំង<br>អ្នកស្រី លឹម លាងងួន<br>ប្រធានPAO ទូរស័ព្ទ: ០១៦ ៣៥៦ ០១៦ |
| ខេត្តពោធិសាត់ | មន្ទីពេទ្យបង្អែកសំពៅមាស<br>ភូមិពាលញែក ឃុំផ្គាសព្រៃ ស្រុកសំពៅមាស<br>វេជ្ជបណ្ឌិត. ស ហុង<br>ប្រធានPAO ទូរស័ព្ទ: ០១២ ៩៣១ ៣០២ |
| ខេត្តរតនៈគីរី | មន្ទីពេទ្យបង្អែករតនៈគីរី<br>ភូមិ៤ ឃុំឡាបានសៀក ស្រុកបានលុង<br>វេជ្ជបណ្ឌិត. ឯង គុនវុឌ<br>ប្រធានPAO ទូរស័ព្ទ: ០១១ ៦៩៣ ១៣១ |
| ខេត្តមណ្ឌលគីរី | មន្ទីរពេទ្យសែនមនោរម្យ<br>ភូមិឃុំសែនមនោរម្យ ស្រុកសែនមនោរម្យ<br>អ្នកស្រី គុជ វណ្ណា<br>ប្រធានPAO ទូរស័ព្ទ: ០១២ ៩៩៨ ២៧៦ |
| ខេត្តព្រះវិហារ | មន្ទីរពេទ្យមករា<br>ភូមិឧទម្ពរ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ<br>អ្នកស្រី ឃុន សុផនធារ៉ា<br>ប្រធាន PAO  ទូរស័ព្ទ: ០១២ ៩៥០ ៧២៩ |
| ខេត្តឧត្តរមានជ័យ | មន្ទីរពេទ្យសំរោង<br>ភូមិចុក ឃុំសំរោង ស្រុកសំរោង |

| | |
|---|---|
| | អ្នកស្រី សំ សម្ផស្ស<br>ប្រធាន PAO ទូរស័ព្ទ: ០១១ ៧៣១ ៧៨៨ |
| ខេត្តក្រចេះ | មន្ទីរពេទ្យរកាកណ្តាល<br>ភូមិក្រចេះ ឃុំក្រចេះ ស្រុកក្រចេះ<br>វេជ្ជបណ្ឌិត សាម៉ុត លីម៉ា<br>ប្រធាន PAO ទូរស័ព្ទ: ០១២ ៩១៧ ៥៩២ |
| ខេត្តស្ទឹងត្រែង | មន្ទីពេទ្យស្ទឹងត្រែង<br>ភូមិព្រែក ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង<br>លោក ឯម ឡូន<br>អ្នកផ្តល់ប្រឹក្សា ទូរស័ព្ទ: ០១២ ២០៦ ៦៣១ |

**សេវារបស់សមាគមថែទាំសុខភាពគ្រួសារកម្ពុជា រ៉ាក់ (RHAC)**

(បញ្ជីទទួលបានពីអង្គការរ៉ាក់ភ្នំពេញ ក្នុងខែ មីនា ឆ្នាំ ២០១០)

| | |
|---|---|
| ក្រុងភ្នំពេញ | - ទីស្នាក់ការកណ្តាល: ផ្ទះលេខ ១៤ ផ្លូវ ៣១៧ សង្កាត់បឹងកក់ ១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ អ៊ីមែល: rhac@rhac.org.kh ទូរសារ: ០២៣ ៨៨៥ ០៩៣ ទូរស័ព្ទ: ០២៣ ៨៨៥ ១៣៥-៨៨៣ ០២៧ និង៨៨០ ៨៥០<br>- គ្លីនិកភ្នំពេញ ១: ផ្ទះលេខ ០៦ ផ្លូវ ១៥០ សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា ទូរស័ព្ទ: ០២៣ ៨៨១ ៦២១<br>- គ្លីនិកភ្នំពេញ ២: ផ្ទះលេខ ៤០ ផ្លូវ ៤៣២ សង្កាត់ទួលទំពូង ១ ខ័ណ្ឌចំការមន ភ្នំពេញ ទូរសារ pp2clinic@rhac.org.kh, ទូរស័ព្ទ: ០២៣ ២១៨ ៥០៤<br>- គ្លីនិកភ្នំពេញ ២ plus:ផ្ទះលេខ ៣៨ ផ្លូវ ៤៣២ ទួលទំពូង ១ ខ័ណ្ឌចំការមន ទូរស័ព្ទ: ០២៣ ៧២៦ ៦៥៩<br>- គ្លីនិកកណ្តាល (ភ្នំពេញ): ផ្ទះលេខ ៣៣ ផ្លូវ ១៥៦ សង្កាត់ផ្សារដេប៉ូ ១ ខ័ណ្ឌ ទួលគោក ទូរស័ព្ទ: ០២៣ ៨៨៥ ០៣០<br>- ប៉ុស្តិ៍សុខភាព ចាក់អង្រែក្រោម: ផ្ទះលេខ ១៦០៧ ផ្លូវជាតិលេខ ២ ចាក់អង្រែ |

| | |
|---|---|
| | ក្រោម ខ័ណ្ឌមានជ័យ ទូរស័ព្ទ: ០២៤ ៩៨៥ ០៧៩<br>- ប៉ុស្តិ៍សុខភាព និងមណ្ឌលយុវវ័យ: ស្ទឹងមានជ័យ: ផ្ទះលេខ ១៩, ២០, ២១ ភូមិត្រពាំងផ្លុង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ទូរស័ព្ទ: ០២៣ ៩៨៥ ៧៧៣<br>- ប៉ុស្តិ៍សុខភាព: ទួលសង្កែ: ផ្ទះលេខ ៧AE0 AE1 ផ្លូវជាតិលេខ ៥ ភូមិសាមគ្គី ខ័ណ្ឌឫស្សីកែវ ទូរស័ព្ទ: ០២៣ ៩៩០ ៧៧៣<br>- គ្លីនិកទឹកថ្លា: ផ្ទះលេខG៣៥-G៣៧ ផ្លូវ Goody សង្កាត់ទឹកថ្លា ខ័ណ្ឌឫស្សីកែវ ទូរស័ព្ទ: ០២៣ ៨៨៣ ០២៦<br>- ប៉ុស្តិ៍សុខភាព ទំនប់ថ្មី: ផ្ទះលេខ ៣៩៧ ផ្លូវ ៣៧១ ភូមិត្នោតជ្រុំ បឹងទំពន់ ខ័ណ្ឌមានជ័យ ទូរស័ព្ទ: ០២៣ ៩៩៥ ៤៧៦ |
| ខេត្តបាត់ដំបង | - គ្លីនិក និងមណ្ឌលយុវវ័យ: ផ្ទះលេខ ១៩៤ ក្រុម ៥៩ ភូមិព្រះមហាទេព្យ ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ទូរស័ព្ទ: ០៥៣ ៩៥២ ៦១០<br>- មណ្ឌលយុវវ័យឯកភ្នំ: ផ្ទះលេខ ១៧៨ ក្រុម ១២ ភូមិស្នាពីមុខ ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ទូរស័ព្ទ: ០៩២ ៤៦៩ ១២២<br>- មណ្ឌលយុវវ័យភ្នំសំពៅ ភូមិគោកអំពិល ឃុំភ្នំសំពៅ ស្រុកបាណន់ |
| ក្រុងព្រះសីហនុ | - គ្លីនិក និងការិយាល័យរ៉ាក់: ផ្ទះលេខ ៥៥៥ ផ្លូវឯករាជ្យ ក្រុម ៤ សង្កាត់លេខ ៤ ខ័ណ្ឌមិត្តភាព ទូរស័ព្ទ: ០៣៤ ៩៣៣ ៩៤២<br>- មណ្ឌលយុវវ័យព្រៃនប់: ផ្ទះលេខ ៤៤៩ ផ្លូវជាតិលេខ ៤ ក្រុម ១៨ ភូមិវាលរេញ សង្កាត់វាលរេញ ខ័ណ្ឌព្រៃនប់ ទូរស័ព្ទ: ០១៦ ៥៧២ ៤៨០ |
| ខេត្តកំពង់ចាម | - គ្លីនិក និងការិយាល័យរ៉ាក់: ផ្ទះលេខ ១០ ផ្លូវត្រសក់ផ្អែម ភូមិបឹងកក់ ឃុំកំពង់ចាម ស្រុកកំពង់ចាម ទូរស័ព្ទ: ០៤២ ៩៤១ ៥០២<br>- ប៉ុស្តិ៍សុខភាពសួងៈ ភូមិសួងលិច ឃុំសួង ស្រុកត្បូងឃ្មុំ ទូរស័ព្ទ: ០១៦ ៣០៥ ៥១១<br>- ប៉ុស្តិ៍សុខភាពផ្ការៈ ភូមិផ្ការ ឃុំផ្ការ ស្រុកបាធាយ ទូរស័ព្ទ: ០១២ ៤៤៦ ៨៨១<br>- មណ្ឌលយុវវ័យតំបែៈ ភូមិស្វាយពោរពាស ឃុំតំបែ ស្រុកតំបែ ខេត្តកំពង់ចាម<br>- មណ្ឌលយុវវ័យត្បូងឃ្មុំ: ភូមិសួងលិច ឃុំសួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម<br>- មណ្ឌលយុវវ័យកំពង់សៀម: ភូមិត្រកួន ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម |

| | |
|---|---|
| ខេត្តតាកែវ | - គ្លីនិក និងការិយាល័យរ៉ាក់: ផ្ទះលេខ៩ ផ្លូវលេខ៨ ភូមិឡូរី ឃុំរកាក្នុង ស្រុកដូនកែវ ទូរស័ព្ទ: ០៣២ ៩៣១ ៣៦១<br>- រ៉ាក់ស្រុកប្រតិបត្តិបាទី: ភូមិបូចាម ឃុំចំបក់ ស្រុកបាទី ទូរស័ព្ទ: ០១២ ៨៨៥ ៤៦៥ (វេជ្ជបណ្ឌិត សៀង រតនៈ ប្រធានស្រុកប្រតិបត្តិបាទី<br>- មណ្ឌលយុវវ័យបាទី: ផ្ទះលេខ ២៩២ ផ្លូវជាតិលេខ ២ ភូមិសីហា ឃុំ ចំបក់ ស្រុកបាទី ទូរស័ព្ទ: ០៩២ ៣៨២ ៥០២ |
| ខេត្តសៀមរាប | - គ្លីនិក និងការិយាល័យរ៉ាក់: ភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ទូរស័ព្ទ: ០៦៣ ៩៦៤ ៩៦០<br>- ប៉ុស្តិ៍សុខភាពពួក: ផ្ទះលេខ ១២២៩ ភូមិគោកជាន់ ឃុំពួក ស្រុកពួក ទូរស័ព្ទ: ០៦៣ ៧៦៧ ០១២<br>- មណ្ឌលយុវវ័យពួក: ផ្ទះលេខ ១២២៩ ភូមិគោកជាន់ ឃុំពួក ស្រុកពួក ខេត្តសៀមរាប. ទូរស័ព្ទ: ០១២ ៣០២ ៧៣៦<br>- មណ្ឌលយុវវ័យបន្ទាយស្រី: ភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ទូរស័ព្ទ: ០១២ ៣៦០ ៥៨៤<br>- មណ្ឌលយុវវ័យអង្គរជុំ ភូមិដូនស្វាយ ឃុំចាឈូក ស្រុកអង្គរជុំ ខេត្ត សៀមរាប ទូរស័ព្ទ: ០១២ ៧២៩ ៤៧៩ |
| ខេត្តកំពង់ស្ពឺ | - គ្លីនិក និងការិយាល័យរ៉ាក់: ភូមិស្នោរទេ ១ ឃុំរកាធំ ស្រុកច្បារមន ទូរស័ព្ទ: ០២៥ ៩៨៧ ១៤៥<br>- ការិយាល័យអេដស៍គងពិសី: ភូមិក្រាំងក្នុង ឃុំស្រអាង ស្រុកគងពិសី<br>- ការិយាល័យអប់រំដល់មូលដ្ឋាន: ផ្ទះលេខ ១៩សេ ភូមិមុខវត្ត ឃុំរកាធំ ស្រុកច្បារមន ទូរស័ព្ទ: ០២៥ ៩៨៧ ២៦១ |
| ខេត្តព្រៃវែង | - ការិយាល័យពារាំង និង ផ្នែកអេដស៍: ភូមិស្នាយពូល ឃុំរកា ស្រុកពារាំង |

| | |
|---|---|
| ខេត្តស្វាយរៀង | - គ្លីនិក និង ការិយាល័យរ៉ាក់: ផ្ទះលេខ ៥០ ភូមិបាវិតកណ្តាល ឃុំបាវិតកណ្តាល ស្រុកចន្ទ្រា ទូរស័ព្ទ: ០៤៤ ៩៤៦ ០៦៦<br>- មណ្ឌលយុវវ័យ VG&CHD ស្វាយរៀង ភូមិមេភ្លៀង ឃុំស្វាយរៀង ស្រុកស្វាយរៀង ទូរស័ព្ទ: ០៤៤ ៩៥៤ ៩៣៤<br>- មណ្ឌលយុវវ័យស្វាយជ្រុំ: ភូមិត្របែក ឃុំស្វាយជ្រុំ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទូរស័ព្ទ: ០១២ ៦៣៧ ៩៦០ |
| ខេត្តមណ្ឌលគិរី | - មណ្ឌលយុវវ័យមណ្ឌលគិរី ភូមិចំការតែ ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី<br>ទូរស័ព្ទ: ០១២ ៨២៨ ៩៦៤ |
| ខេត្តប៉ៃលិន | - មន្ទីរសុខាភិបាលប៉ៃលិន<br>ទូរស័ព្ទ: ០១២ ២០៩ ៦៧០ និង០៩២ ៥៦៧ ១៣២ |